ប្រលោមលោក

ពានរង្វាន់ព្រះសីហនុរាជ

លេខ ១




ថ្វាយចំពោះព្រះមហាក្សត្រ
សំរាប់ព្រះអង្គប្រទានដល់ជ័យលាភី
ហ៊ុន សែន. ១៩៩៥

# ពេលពុកមិននៅ

ស៊ុខ_ស៊ុធន

មហោស្រពតែងនិពន្ធអក្សរសិល្ប៍ ១៩៩៥

# មាតិកា

*អត្ថបទ ទំព័រ
១.អភិវាទន៍កថា ........ ១
២.កថាមុខ (បទពាក្យ៧) ........ ២
៣.ពេលពុកមិននៅ (បទភុជង្គលីលា) ........ ៤
៤.បទព្រហ្មគីតិ ........ ៥
៥.បទសុឡាបលួន ........ ៧
៦.បទកង្កែបលោតស្ទាក់ពេជ្រ ........ ៨
៧. បទសីង្ហតោលេងកន្ទុយ ........ ៩
៨.បទអក្សរលួន ........ ១២
៩.គួរ,គេង, គិត, (បទពាក្យ៧) ........ ១៣
១០.មរតកដូនតា (បទគាកគតិ) ........ ១៥
១១.ការពារប្រសើរជាងព្យាបាល (បទពាក្យ៧) ........ ១៩
១២.ទំពាំងស្នងឫស្សី (បទពាក្យ៧) ........ ២៥
១៣.ស្រីល្អត្បិតចរិយា ប្រុសសង្ហាត្បិតវិជ្ជា (បទពាក្យ៧) ........ ៣៣
១៤.ឆ្កួតបី (បទពាក្យ៧) ........ ៤៣
១៥.ដើរមានបី ស្ដីមានបួន (បទពាក្យ៧) ........ ៥១
១៦.កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប (បទពាក្យ៧) ........ ៥៤
១៧.អណ្ដាតជាអាថ៌កន្លង (បទពាក្យ៧) ........ ៥៦
១៨.ទូកទៅកំពង់នៅ (បទពាក្យ៧) ........ ៦០
១៩.ចង់ចេះឱ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឱ្យយកភ្លើងដុតគល់ (បទពាក្យ៧) ........ ៦៧
២០.ចេះពីរៀនមានពីរក (បទពាក្យ៧) ........ ៧២
២១.អវសានកថា (បទពាក្យ៧) ........ ៨១

087201959
895.9321
ល៉ាក.
ឃ.2.

កំណាព្យ

# ពេលពុកមិននៅ

01541
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
បណ្ណាល័យ
Phnom-Penh University
LIBRARY
សាកលវិទ្យាល័យភ្នំពេញ

POETRY

# AS FATHER IS AWAY



## សុខ - សុធន

-កើតថ្ងៃពុធ ទី៩ ខែកក្កដា ឆ្នាំ១៩៥៨ នៅភូមិកណ្ដាល ឃុំ អរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល ។

_ឪពុកនាម : សុខ-លក្ខណ៍ ( សាស្ត្រាចារ្យមហាពុទ្ធិកវិទ្យាល័យ )

_ម្ដាយនាម : យុខ-សាមេធ

## ស្នាដៃកំណាព្យខ្លាតខែខ

_ឆ្នាំ ១៩៨៧ អត្ថបទកំណាព្យរឿង " អ្នកម្ដាយក្រមុំ " បានទទួលជ័យលាភី ចំណាត់ថ្នាក់លេខ១រង្វាន់ពិសេសក្នុងមហោស្រពអក្សរសិល្ប៍ទូទាំងរដ្ឋធានីភ្នំពេញ។

_ឆ្នាំ១៩៨៩ អត្ថបទកំណាព្យរឿង "មាតាអត័ព្វ " ចំណាត់ ថ្នាក់លេខ១រង្វាន់មេដាយមាសមហោស្រពអក្សរសិល្ប៍ទូទាំងប្រទេស ។

_ឆ្នាំ១៩៩៥អត្ថបទកំណាព្យរឿង"ពេលពុកមិននៅ" បានទទួលចំណាត់ថ្នាក់លេខ១ពានរង្វាន់ " ព្រះសីហនុរាជ " មហោស្រពអក្សរសិល្ប៍ប្រទេស ។

# ពេលពុកមិននៅ

**ពាក្យកាព្យ**

សុខ - សុធន

ចំណាត់ថ្នាក់លេខ ១

ពានរង្វាន់អក្សរសិល្ប៍ " ព្រះសីហនុរាជ "


បោះពុម្ពលើកទី ១ : គ.ស ១៩៩៦ / ព.ស ២៥៤០

កុំព្យូទ័រ : ឧបត្ថម្ភដោយអង្គការ " ពន្លក "

បោះពុម្ពផ្សាយ : ឧបត្ថម្ភដោយ HEINRICH BOLL FOUNDATION

ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ

# អារម្ភកថាអ្នកបោះពុម្ពផ្សាយ

មិត្តអ្នកអានជាទីមេត្រី !

សង្គ្រាមក្នុងស្រុកជាងពីរទសវត្ស បានធ្វើឱ្យអរិយធម៌ វប្បធម៌ និង អក្សរសិល្ប៍ខ្មែរ រលុបរលាយបន្តិចម្តងៗ គួរឱ្យព្រួយបារម្ភ ។

ដើម្បីស្តារ និងអភិវឌ្ឍវិស័យនេះឱ្យមានភាពរស់រវើកឡើងវិញ នោះ សមាគមអ្នកនិពន្ធខ្មែរ ដោយបានព្រះរាជានុញ្ញាតពីព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូងព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ជាទីសក្ការៈ បានព្រារព្ធធ្វើមហាស្រពតែងនិពន្ធអក្សរសិល្ប៍បានរង្វាន់ " ព្រះសីហនុរាជ " លើកទីមួយ ដោយ ទទួលបានស្នាដៃចូលរួមយ៉ាងព្រឹនកុះករ ។

ដោយឃើញអត្ថបទកំណាព្យ " ពេលពុកមិននៅ " មានគុណប្រយោជន៍ចំពោះអក្សរសិល្ប៍ជាតិបែបនេះ ទើបមូលនិធិ ហ៊ិន រិច បុល ( The Heinrich-Böll Foundation) បានឧបត្ថម្ភថវិកាសំរាប់ឱ្យសមាគមអ្នកនិពន្ធខ្មែរ បោះពុម្ពផ្សាយជាសាធារណៈ ដើម្បីទុកជាទុនឱ្យ កុលបុត្រ កុលធីតាខ្មែរ ធ្វើការសិក្សា ស្រាវជ្រាវនិងទុកជាកេរមរតកអក្សរសិល្ប៍ជាតិតរៀងទៅ ។

ព្រមជាមួយនេះដែរ យើងសូមលំអោនកាយ រង់ចាំទទួលការរិះគន់គ្រប់បែបយ៉ាងពីមិត្តអ្នកអាន ដើម្បីឱ្យវិស័យអក្សរសិល្ប៍ជាតិកាន់តែមានសន្ទុះឈានឡើង ទាន់អក្សរប្រទេសនានាលើសកលលោក ៕

ភ្នំពេញ ថ្ងៃទី២ វិច្ឆិកា ១៩៩៦

សមាគមអ្នកនិពន្ធខ្មែរ

# ៙ អភិវាទន៍កថា ៙

ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងនូវកិច្ចអភិវន្ទន៍ ថ្វាយបង្គំ និងគោរពដោយស្មោះអស់ពីដួងចិត្ត ចំពោះព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ចំពោះព្រះសង្ឃទាំងពីរគណៈ ចំពោះសម្តេច ទ្រង់ ឯកឧត្តម ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងលោក លោកស្រី គ្រប់ស្រទាប់ជាន់ថ្នាក់ ដែលបានយកព្រះទ័យ និងយកចិត្តទុកដាក់ ចំពោះអក្សរសាស្ត្រនិងអក្សរសិល្ប៍ជាតិរបស់ខ្មែរ ។

ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសស្លាដែថ្វាយ និងជូនចំពោះ វិញ្ញាណក្ខន្ធបុព្វការីជន ប្រាជ្ញ បណ្ឌិត ព្រឹទ្ធកវី ដែលលោកបានធ្វើមរណៈកាលទៅកាន់តពថ្មី និងសូមគារវៈដឹងគុណជានិរន្តរ៍ ចំពោះពលិកម្មគ្រប់បែបយ៉ាងរបស់លោក ក្នុងការលើកស្ទួយវប្បធម៌អរិយធម៌ជាតិ និងបន្សល់ទុកនូវក្បួនច្បាប់ គម្ពីរត្រា សាវតារ ប្រវត្តិសាស្ត្រជាតិសំរាប់កូនចៅជំនាន់ក្រោយ ។

សូមឫទ្ធិបញ្ញាញាណដ៏ឈ្លាសវៃ នៃបុព្វបុរសទាំងឡាយនោះ មកសណ្ឋិតជាប់ក្នុងព្ធដ៏សតិសម្បជញ្ញៈ នៃកុលបុត្រកុលធីតាខ្មែរជាអមតៈ ។

សុខ សុធន

# "កថាមុខ"

(បទពាក្យ ៧)

-បន្ទន់ឱនអង្គផ្ចង់ភាវនា　　បង្គំវន្ទាទាបសិរសី
ផ្ញើភ័ព្វលើកពម្ងប់បារមី　　រតនៈទាំងបីថ្លៃបវរ ។
-ព្រះពុទ្ធ ធម៌ សង្ឃគង់ប្រថាប់　　ច្បងភទ្ទកប្បច្រើនគំណ
តម្កល់ស្រែបុណ្យទុកបន្ត　　បំភ្លឺនិករគ្រប់អង្គា ។
-ជាស្ពានចម្លងសាធុជន　　សន្សំសីលបុណ្យអារាធនា
ភ្ជាប់ភ័ព្វនិស្ស័យព្រះភគវា　　ទាន់ព្រះសិអារ្យដ៏ឧត្តម ។
-សាងបុញ្ញកុសលដោយឆន្ទៈ　　ឱនគារវៈសរណៈគមន៍
ព្រះធម៌នាំមកសុខមនោរម្យ　　ដល់សម្បត្តិធំបីប្រការ ។
-ប្រសព្វឥដ្ឋមនុញ្ញផល　　កុសលដោយកាយចិត្តវាចា
មានសម្បត្តិមនុស្សនិងទេវតា　　សម្បត្តិថ្លៃថ្លានិព្វានផង ។
-នឹកគុណមាតានិងបិតា　　លោកទាំងទ្វេហាធំចំបង
ចិញ្ចឹមថ្នមកាយត្រាយចម្លង　　បីបាច់ត្រកងឆ្លងទុក្ខា ។
-លោកមានគុណធ្ងន់លើជីវិត　　ផ្តល់ពិតមេត្តាករុណា
ទាំងមុទិតាឧបេក្ខា　　ធម៌ព្រហ្មវិហារដ៏ត្រឹមត្រូវ ។
-ឱនកាយគោរពគ្រូឧបជ្ឈាយ៍　　គុណលោកពុះពារពន្យល់ផ្លូវ
បង្ហាត់បង្រៀនប្រៀនតម្រូវ　　ឱ្យចេះចាំនូវផ្លូវបញ្ញា ។
-ឧទ្ទិសព្រលឹងស្មឹងស្មារតី　　បុព្វការីព្រឹទ្ធាចារ្យ
ដែលលោកលាឋានខ័ណ្ឌសីមា　　សូមសោយសុខាក្នុងភពថ្មី ។
-គម្ពីរតម្រាលោកបន្សល់　　កូនចៅតម្កល់ជាសក្ខី
រក្សាកេរកាលថ្នាលវិន័យ　　តពីអតីតស្នងវន្ទា ។

គោរពដឹងគុណធ្ងន់ត្រកាល　　រាជរដ្ឋាភិបាលគ្រងប្រជា
ផ្ដល់ម្ចប់ត្រជាក់មហិមា　　ពលរដ្ឋគ្រប់គ្នាផុតទុក្ខភ័យ ។
សូមសន្តិភាពជាប់ចិរកាល　　លើចក្រវាឡភពផែនដី
រលត់សូន្យសោះជម្លោះក្ដី　　សង្គ្រាមអប្រិយ៍អហោសិកម្ម ។
សូមរីកចំរើនគ្រប់ជីវភាព　　សំបូរពេញព្រៀបជាប្រចាំ
ចាកផុតទុក្ខសោកវិនាសកម្ម　　ទ្វីបលោកទាំងប្រាំរត់ទាន់គ្នា ។
សូមឱ្យព្រលឹងវប្បធម៌ជាតិ　　និរន្តរ៍ឥតឃ្លាតពីប្រជា
រុងរឿងលាន់ឮលើភារា　　ដែនកម្ពុជារាជបូរី ។

* * *

# "ពេលពុកមិននៅ"

## (បទភុជង្គលីលា)

-នេះបទភុជង្គលីលា នឹងចាប់ចងជា ឃ្លោងឃ្លាមួយថ្មី ។
-ថ្វាថ្លៃងតែងតួសេចក្តី ផ្តាំកូនប្រុសស្រី ស្តីតាមទំនុក ។
-ហែស្ងួនកូនមាសឪពុក កូនអើយចាំទុក ទំនុកនេះណា ។
-ពុកផ្តាំតាមតួអក្ខរា ជំនូសវាចា ជាប្រដៅស្តី ។
-ឱស្ងួនពន្លកប្រុសស្រី ឪពុកចូលវ័យ ជរាបៀតបៀន ។
-ថ្ងៃមុខរូបពុកនឹងគ្មាន(១) ពុំបានទូន្មាន ប្រៀនប្រាប់ទៀតឡើយ ។
-នេះពុកក្តួលក្តុកឥតស្បើយ ត្បិតមាសត្រាណត្រើយ សឹងនៅក្មេងខ្ចី ។
-ពុកគ្មានធនធានផងអ្វី ចែកកូនប្រុសស្រី ជាកេរអាករ ។
-មានត្រឹមបណ្តាំស្មោះសរ ជាទ្រព្យបវរ បន្តឱ្យភ្ញា ។
-កូនអើយខំក្រេបវិជ្ជា ស្រឡាញ់ការងារ ទ្រព្យាគង់មាន ។
-បូរាណលោកបាននិទាន ចេះមកពីរៀន មានមកពីរក ។
-ចរណៃគប្បីនឹកភ្នក លោកផ្តាំពន្លក រិះរកព្យាយាម ។
-ទំនុកទុកជាទំនៀម កុំទំនេរស្ងៀម ព្យាយាមឧស្សាហ៍ ។
-ឃ្លាមួយលោកថ្លោយផ្តាំថា កូនដែលច្រើនបា កូននោះនឹងល្អ ។
-ចូរចាំពុកផ្តាំបន្ត កូនឆ្លាតកូនល្អ ត្បិតគ្រូបាច្រើន ។
-តម្រេះចេះចាំចម្រើន ប្រាជ្ញាកើតកើន ដោយដំបូន្មាន ។
-កូនអើយនោះហើយជាស្ពាន ជាទ្រព្យធនធាន ជាយានឆ្លងផ្លូវ ។
-នេះពុកផ្តាំទុកតទៅ ពេលពុកមិននៅ កូនត្រូវចងចាំ ។

***

(១) ថ្ងៃមុខរូបពុកនឹងស្លាប់សូន្យទៅ

# (បទព្រហ្មគីតិ)

ក្មួនអើយនេះព្រហ្មគីតិ ចូរមាសស្និទ្ធចងចំណាំ
បន្សល់មកយូរឆ្នាំ បែបបទផ្ដាំពីដូនតា ។
កវីប្រាជ្ញព្រេងព្រឹទ្ធ លោកស្នេហ៍ស្និទ្ធកាព្យអក្ខរា
ចងក្រងសព្វសារតារ សុទ្ធសឹងចារដោយចុងចូន ។
រាមកេរ្តិ៍វេស្សន្តរ លោកបន្តទុកជាក្បួន
ឃ្លោងឃ្លាជាកាព្យចូន សៀងសំនួនផ្ទួនណែងណង ។
ក្មួនអើយរឿងហង្សយន្ត ព្រះសុធនល្អកន្លង
កំណាព្យកាព្យកម្រង ល្បះដើមដងចងរណ្ដំ ។
សព្វសិទ្ធស័ង្ខសិល្ប៍ជ័យ ពីរោះល្បីថ្លៃស័ក្តិសម
មហោសថឧត្ដម ចង្អូមកែវទិព្វសង្ខា ។
ពុទ្ធិសែននាងកង្រី រឿងកាកីបដាចា
ធនញ្ជ័យន័យពិស្ដារ កែវណាម៉ាអង្គាបុស្ស ។
រឿងមរណៈមាតា ទេពមច្ឆាល្បីសាយសុះ
ទាវទុំផ្ដុំចម្រុះ ចាំទុកចុះច័ន្ទគោរព ។
កេរកាលច្បាប់ប្រុសស្រី ល្បើកចាស់ថ្មីច្រើនលើសលប់
ព្រះធម្មធម៌ត្រៃយ៍ភព ចងក្រងគ្រប់ដោយឃ្លោងឃ្លា ។
ក្មួនអើយយើងជាខ្មែរ ចូរជួយថែកេរព្រឹទ្ធា
កុំបោះបង់កាព្យា ប្រឹងការពារព្រលឹងជាតិ ។
បន្តអក្សរសិល្ប៍ កុំបង្វិលរំកិលឃ្លាត
រក្សាកុំចង្អៀត ខំឆ្វាក់ផ្លៀតប្រឌិតថ្មែ ។

-កុំស្អប់កាព្យសូរសៀង ស័ព្ទសំនៀងមានតម្លៃ
សាយសព្វគ្រប់សម័យ លួងលោមថ្លៃថ្នមចិន្តា ។
-បម្រើយ៉ាងប្រត្យក្ស សព្វសិល្បៈគ្រប់ប្រការ
ចូរចាំណាកូនណា កាព្យអក្សរាដូចពេជ្រថ្លៃ ។
-ឃ្លោងឃ្លាជាអម្រិត បំពេចិត្តមាសចរណៃ
នោះហើយចំណងដៃ ទ្រព្យថ្លាថ្លៃនៃដូនតា ។
-កំណាព្យកាព្យកំណល់ កំណប់ផលពិតពិស្តារ
ឈ្មុយឈ្ងប់សព្វទិសា ដូចបុប្ផាពេញក្រពុំ ។

***

# "បទសុឡាបល្បួន"

-ប្រុងប្រឹងប្រែង តែងតិចតួច ស្តួចស្តើងស្តាប់
សន្សំសព្ទ ចាប់ចុងចួន សួនសក្តិសម
កូនកាយកត់ បទបែបបែង ខែងខិតខំ
ផ្សំផ្សែផ្សំ ចំចូលចិត្ត គិតគយគន់ ។
-រៀនរៀបរាប់ ញាប់ញឹកញយ ឱ្យអង់អាច
ប្រឹងប្រើប្រាជ្ញ ខ្វាចខ្វៅខ្លួន ជួនជោរជន់
ខ្ជិលខ្ជីខ្ជា ងារងងឹត ពិតពេកពន់
សឹងសិយស៊ុន ទន់ទាបទៀត ឃ្លាតឃ្លោងឃ្លា ។
-ចង់ចេះចាំ ផ្តាំផ្តែផ្តាច់ ត្រាច់ត្រាប់ត្រង
ឆ្វាតឆ្វើយឆ្វង គងគួរគិត ពិតពុះពារ
នាងនិស្សនៅ ត្រូវត្រឹមត្រង់ ស្ទង់ស្ទុះស្ទា
ធនធូរធា ជាជួបជុំ កុំកោងកាច ។
-រត់រករៀន មានមុតមាំ ហាំហ៊ុហា
ចេះចរចា ការកិច្ចកើត អើតអង់អាច
ដឹងដិតដល់ ផលផ្ទួរផង់ បង់បោះបាច
កូនកុំកាច ខ្វាចខ្វបខ្វួន ជួនជួបជា ។
-បើបែកបាក់ ដាក់ដាបដុន កុនកិច្ចកល
ខ្វះខ្វាយខ្វល់ សល់សោយសោក រោគរុញរា
ទទួលទុក្ខ លុកលិចលង់ ពង្សពូជពារ
លេងលីលា ពារពានពុះ ខុសខកខាន ។

ដេកដើរដឹង ប្រឹងប្រាយប្រាប់ ចាប់ចរចា
កាន់កិច្ចការ ចាបត់បែរ ប្រែប្រួលប្រាណ
របររមរស់ ឈ្មោះឈ្មុសឈ្មុល ដល់ដើមដាន
ថ្កុំថ្កើងថ្កាន ប្រាណប្រិមប្រិយ លៃលើសលប់ ។

***

## "បទកខ្មែរលោតស្លាក់ពេជ្រ"

ពាក្យទំនុក ពុកទំនាក់ ពាក់ទំនៀម
បើនឹងស្មៀម បៀមនឹងស្ទាត់ ចាត់នឹងស្ទប់
បានសំណោក បោកសំណាត់ បាត់សំណព្វ
សឹងកាយកប់ សព្វកាយកល់ សល់កាយកម្ម ។
ចូរកូនត្រាប់ ចាប់កូនត្រាយ ចាយកូនត្រង
ចារចំណង ចងចំណោទ ចោទចំណាំ
ពុកបណ្ដុះ ពុះបណ្ដូល ពោលបណ្ដាំ
ផ្ដែឱ្យចាំ ផ្ដាំឱ្យចង ផ្ដងឱ្យចេះ ។
ខ្វួនមិនឆៅ ខ្វៅមិនឆាំង ខ្វាំងមិនឆោត
ដកពិសោធ ដោតពិសាល ដាលពិសេស
ប្រឹងខំចាប់ ប្រាប់ខំចុះ ប្រុសខំចេះ
ត្រាប់តម្រេះ ត្រិះតម្រូវ ត្រូវតម្រាយ ។

បានចំណេះ បេះចំណែក បែកចំណង់
ចិត្តឱ្យត្រង់ ចង់ឱ្យត្រាប់ ចាប់ឱ្យត្រាយ
បានប្រឡូក បូកប្រឡែង បែងប្រឡាយ
ត្រូវបេះស្តាយ ត្រាយបេះស្តាប់ ត្រាប់បេះស្តារ ។
ច្នេះគួរផុះ ច្នោះគួរផើង ច្នឹងគួរផាំ
កូនចំណាំ កម្មចំណាយ កាយចំណារ
ចាប់របរ ចររបង ចងរបា
ចេះប៉ុណ្ណា ចារប៉ុណ្ណោះ ចុះប៉ុណ្ណឹង ។

***

# "បនសឹង្ហតោលេចកន្ទុយ"

ចូរកូនចាប់ ស័ព្ទពំនោល ពោលពាក្យពិត
មាសស្នេហ៍ស្និទ្ធ គិតគប្បី ថ្លៃថ្លែងថ្លឹង
ចងចាំជាក់ ភ្ញាក់គំនិត ប្រិតប្រែងប្រឹង
ស្ងួនព្រលឹង ប្រឹងខ្វាយខ្វល់ ផ្តល់ផ្តួចផ្តុំ ។
ដីភពផែន ដែនរដ្ឋា ចារចងចាំ
ផុតក្រញាំ កម្មវេរា ជាជួបជុំ
ដូចឧទ្យាន មានបុប្ផ ផ្កាផ្គូផ្គុំ
ពេញក្រពុំ លំអងអប់ សព្វសុះសាយ ។

-ជាតិខេមរា ថ្លាដូចមាស ពាសពោរពេញ
ផុតទៅម្ទេញ ចេញចាកស្រោម ឆោមឆើតឆាយ
ជីវិតថ្មី ថ្ងៃបវរ កកើតកាយ
ផុតខ្វល់ខ្វាយ ឆ្ងាយពីទុក្ខ សុខសមសួន ។
ស្ងួនប្រុសស្រី ថ្ងៃអើយយល់ ដល់ដើមដាន
ប្រឹងប្រមាណ ប្រាណចាំទុក មុខមាំមួន
ពលរដ្ឋយើង ថ្កើងសុខដុម ជុំជួបជួន
ជាតិមាំមួន ស្ងួនខ្ពង់ខ្ពស់ រស់រីករាយ ។
-កូនអើយស្ដាប់ សព្ទទំនុក ពុកព្រោលពិត
កុំប្រព្រឹត្ត គិតខ្វចខិល ខ្ជិលខ្ជះខ្ជាយ
ការតូចធំ កុំជជុះ រុះរាត់រាយ
ដល់ថ្ងៃនាយ ស្ដាយសោកសៅ ទៅទៀងទាត់ ។
-ត្រូវក្លាហាន ប្រាណឧត្ដម សមស័ក្ដិសិទ្ធ
ញាតិគាប់ចិត្ត ពិតរស់រាន មានមុខមាត់
យល់ចំណេះ ចេះវិជ្ជា វារីវឌ្ឍន៍
ចេះចាំស្ទាត់ ធាត់ធំបាន ប្រាណប្រិមប្រិយ ។
-ប្រាង្គអង្គរ ឈរលើទង់ គង់គួរគាប់
វរិចជាប់ ភ័ព្វលើភព ស្កប់ស្កឹមស្កៃ
ជាដង្ហើម ដើមព្រលឹង សឹងសាក្សី
ខ្មែរប្រុសស្រី សក្ខីតាង សាងសុខសាន្ត ។
-ដូនតាយើង ថ្កើងខ្ពង់ខ្ពស់ ឈ្មោះឈ្មុសឈ្មុល
ប្រឹងខ្វាយខ្វល់ យល់ស័ក្ដិសម ថ្កុំថ្កើងថ្កាន

ដំណាទៅ នៅសុខុម ក្សុំក្សេមក្សាន្ត
ញាតិសន្តាន ប្រាណស្នេហ៍ស្និទ្ធ ពិតពុះពារ ។
ពេលពុកនៅ ពៅធ្លាប់ស្តាប់ ស័ព្ទសូរសៀង
ប្រាប់នូនទាង ប្រៀងប្រឹងព្រួយ ស្ទួយស្ទុះស្ទា
ក្រែងកូនល្វង់ លង់វង្វេង លេងលីលា
ខ្វះវិជ្ជា ងារដូចងោះ រស់រីងរៃ ។
ពុកប្រឹងប្រឹត គិតតិចតួច ផ្តួចផ្តែផ្តាំ
ដូចដំណាំ ផ្សាំបណ្តុះ លុះលូតលៃ
អនាគត ផុតអភ័ព្វ ជួបជោគជ័យ
មាសប្រុសស្រី ថ្ងៃថ្កើងថ្កាន ប្រាណប្រូលប្រែ ។

***

# "បទអក្សរលុន"

**ចុះ**ចាប់ចងចាំចេះចាត់ចែង　　បែបបទបែកបែងបានបំបែរ
ប្រុងប្រៀបប្រឹតប្រៀងប្រឹងប្រូលប្រែ　　កុំកាន់កលកែកាត់កិច្ចការ ។
ត្រូវត្រាច់ត្រាប់ត្រងត្រៀមត្រូសត្រាយ　　ចូកចែវចែកចាយចេះចរចា
សន្សំសុខសាន្តស៊ូសិក្សា　　ហើយហាមហ៊ឺហាហួសហំហួន ។
គួរគេងគិតគួរគាប់គយគន់　　មាសមេមើលមុនមុខមាំមួន
សឹងសោះសង្ស័យសែនសមសួន　　ចងចាប់ចុងចូនចំចូលចិត្ត ។
រិះរេរួសរាន់រត់រករៀន　　ពុះពារពេកពានពោលពាក្យពិត
ដឹងដល់ដើមដានដោយដាមដិត　　បើបែរបាំងបិទបំបង់បាយ
តក់ៗតោងតែតាមតាក់តែង　　ប្រឹតប្រុងប្រឹងប្រែងប្រើប្រាជ្ញប្រាយ
ស៊ើបសួរសាស័ព្ទសព្វសុះសាយ　　កុំកោងកាចកាយកាន់កិច្ចកល ។
ងីងើងប់ងល់ងារងងឹត　　ពោលពាក្យពុំពិតពានពិសពុល
ជួញជិតជាជាងជួបជួសជុល　　យឺតយ៉ាវយង់យល់យំយូរយារ ។
ទទួលទុក្ខទោសទៅទោរទន់　　លួចលាក់លោភលន់លង់លីលា
ស្អាក់ស្ទើរស្ទង់ស្ទាបស្ទួយស្ទុះស្ទា　　មូលមិត្តមឹងមាមិនមានហួង ។
គ្រេវគ្រោធគ្រៀមគ្រំគ្រែងគ្រគ្រី　　ដាំដុះដាស់ដីដឹងដើមដង
ស័ក្តិសមសួរសៀងស័ព្ទសាសង　　ធ្លាក់ធ្លៀតធ្លើយធ្លងធ្លាតធ្លេធ្លា ។
ផ្តួចផ្តើមផ្តែផ្តាំផ្តោតផ្តោះផ្តង　　គេរកាលកត់កងគូនកាន់ការ
បើបែរបែកបាក់បាត់បង់បា　　ពុកពោលពាំពារពឹងពាក្យពិត ។

***

# "គួរ គេង គិត"

## "បទពាក្យ៧"

-**គួរ** អើយគួរគេងគិតរំពៃ    គួរស្គាល់តម្លៃនៃជីវិត
គួរដឹងរាក់ជ្រៅខុសត្រូវពិត    គួរយល់សុចរិតនិងបាបកម្ម ។
-គួរប្រមូលមិត្តកាត់សត្រូវ    គួរដើរតាមផ្លូវកុំចោលស្ដាំ
គួរចៀសវាងឆ្ងាយអបាយកម្ម    គួរត្រាច់ចំណាំមាគ៌ាល្អ ។
-គួរណាស់ស្គាល់ច្បាស់ពីកិច្ចការ    គួរកុំហ៊ឺហាក្រេងនាំក្រ
គួរប្រុងប្រៀបប្រាណឱ្យបានល្អ    គួរកាន់ស្មោះសរធម៌ខន្តី ។
-គួរខំសង្វែកលេខអក្ខរា    គួរគាប់សិក្សាបញ្ញាវៃ
គួរត្រាប់កិច្ចការស្រាលធ្ងន់ក្ដី    គួរកុំខ្ជិលអីប្រឹងឧស្សាហ៍ ។
-គួរកុំចោលម្យៀតឃ្លាតញាតិមិត្ត    គួរកុំទុច្ចរិតចិត្តឫស្យា
គួរកាន់សុចរិតចិត្តកិរិយា    គួរកុំមុសាវាចាស្ដី ។
-គួរកុំកោងកាចកេងប្រវ័ញ្ច    គួរកុំកំណាញ់ខ្វះភក្ដី
គួរកុំបំពានច្បាប់វិន័យ    គួរកុំបំភ្លៃប្រពៃណី ។
-គួរកុំគុំកួនពូនព្យាបាទ    គួរកុំប្រមាថជន្មជីវី
គួរខំសន្សំធម៌សាមគ្គី    គួរស្វែងសំភីបុណ្យបារមី ។

-**គេង**កុំលង់លក់ទ្រមក់ប្រាណ    គេងប្រៀបប្រមាណរឿងវែងខ្លី
គេងពិចារណាការចាស់ថ្មី    គេងនឹករំពៃក្ដីខុសត្រូវ ។
-គេងកុំសន្សំសុបិនល្អ    គេងកុំអង្វរខ្មោចម៉ែឪ
គេងកុំបន់ផ្សងប៉ងខុសផ្លូវ    គេងកុំសុំស្រូវសុំទ្រព្យធន ។

-គេងកុំពឹងផ្អែកជោគវាសី　　គេងខ្ជិលដើរដីបូកទំរន់
គេងពឹងទ្រព្យគេរគង់ស៊ីយស៊ុន　　គេងស្ពឹកស្រពន់ស្ងួនវិនាស ។
-គេងត្រូវស្រណោះពេលវេលា　　គេងស្តាយការងារដែលជាមាស
គេងទឹកប្រយោជន៍ក្រែងនិរាស　　គេងកុំវាងចៀសពីការគិត ។
-គេងកល់ក្នល់ខ្នើយកើយសញ្ជឹង　　គេងគន់ទន្ទឹងភ្ជាក់គំនិត
គេងកុំបង្ខំភ្នែកអោយបិទ　　គេងហើយប្រឹងប្រឹតពិចារណា ។

-គិតគួរឱ្យជាប់គង់គប្បី　　គិតវែងកុំខ្លីទើបពិស្តារ
គិតញាតិឆ្ងាយជិតគិតអាត្មា　　គិតសព្វប្រការឱ្យបានច្បាស់ ។
-គិតរឿងវាសនាអនាគត　　គិតប្រឹងប្រយុទ្ធប្រសើរណាស់
គិតទាន់នៅក្មេងក្រែងស្បើយចាស់　　គិតកុំបីខ្វះគ្រប់កិច្ចការ ។
-គិតស្វែងជំនាញជាត្រីមុខ　　គិតកុំសុំកុកឈ្នះទុក្ខា
គិតសន្សំទានមានមេត្តា　　គិតសាងករុណាប្រាថ្នាធម៌ ។
-គិតរួមស្នេហ៍គ្រស្នោះសង្គ្រោះគ្នា　　គិតកុំពាលានោះនឹងល្អ
គិតជាតិទឹកដីថ្លៃបវរ　　គិតអរិយធម៌អម្បូរខ្មែរ ។
-គិតហើយសឹមគួរណាពុំងា　　គិតអោយគាប់ជាកុំប្រួលប្រែ
គិតជាតិសាសនាវប្បធម៌ខ្មែរ　　គិតសម្បត្តិកេរថែគង់គាប់ ។

***

# (មរតកដូនតា)

## "បទភាគគតិ"

-កូនអើយចាំទុក ពាក្យពេចន៍ទំនុក ឪពុករៀបរាប់
ប្រាង្គប្រាសាទខ្មែរ ជាកេរភោគទ្រព្យ សន្ធឹកសន្ធាប់
ចារជាប់សាវតារ ។

-តម្កល់កេរ្តិ៍ឈ្មោះ រំលេចកិត្តិយស ខ្ពស់លើលោកា
ប្រៀបផ្ទឹមពុំបាន គ្មានអ្វីឧបមា សម្បត្តិដូនតា
លោកបន្សល់នៅ ។

-ពុកចងចាំច្បាស់ ប្រាសាទច្រើនណាស់ ល្អល្អះឆ្ពិនឆ្ពៅ
មួយពាន់ប៉ែតសិប ពុកប្រាប់ពាលពៅ អំណើះតទៅ
កូនត្រូវកុំភ្លេច ។

-កេតនភណ្ឌយើង កិត្តិស័ព្ទរុងរឿង ថ្កុំថ្កើងជានិច្ច
ឆ្លងច្រើនសម័យ ថ្លៃលើសមាសពេជ្រ កូនអើយកុំភ្លេច
ស្នេហ៍ស្មើកែវភ្នែក ។

-ប្រាសាទអង្គរ សម្ផស្សបវរ ធព្វណ្ណភ្ញីផ្អែក
ប្រាសាទបាយ័ន សោភ័ណល្អឯក រចនាគាប់ភ្នែក
លើសពេជ្រចរណៃ ។

-ប្រាសាទពិធូ ល្អដូចគំនូរ គូបន្ទាយស្រី
ប្រាសាទបាគង គ្រងបន្ទាយក្តី ព្រះបាលិលេយ្យ
ថ្មែពីសិលា ។

-ប្រាសាទបាពួន ផ្គុំផ្គុំសមសួន ក្បូនក្បាច់រចនា
ភិមានអាកាស ប្រាសាទវត្តខ្មារ ប្រាង្គបន្ទាយឆ្មា
បន្ទាយសំរ៉ែ ។

-ប្រាសាទព្រះខ័ន ប្រាសាទក្រវ៉ាន់ ចាកានគួរស្នេហ៍
បក្សីចាំក្រុង គង់ឥតប្រួលប្រែ កូនអើយយើងខ្មែរ
ប្រឹងថែការពារ ។

-ចៅស្រីវិបុល សិលាតម្កល់ បន្សល់យូរយារ
ប្រាសាទក្រហម សមបឹងមាលា ប្រាង្គវត្តអធ្វា
ប្រាសាទស្វាយព្រាហ្ម ។

-ប្រាង្គធម្មនន្ទ រងគ្រោះទារុណ ធ្ងន់ដោយសង្គ្រាម
ប្រាសាទទីម៉ែ ខ្មែរភ្ជាប់ទំនៀម កូនអើយស្នាមឈាម
ជិតដាមប្រាង្គប្រា ។

-ប្រាសាទបាខែង ល្អល្អះចិញ្ចែង ព្រៃក្លែងសង្ហា
ប្រាសាទភ្នំបូក គោកពោធិថ្ងៃថ្លា សៅភាពរចនា
សិលាហ្មត់ខៃ ។

-ប្រាសាទអកយំ កណ្តាលព្រៃធំ ពុកយំអាល័យ
ប្រាសាទថ្មដាប់ ខ្ទីងស្លាប់ស្តីមស្តៃ ប្រាសាទឈៃលៃ
ថ្ងៃល្អចំណាន ។

-ប្រាសាទគគីរ តាព្រហ្មរបើរ ទីរមណីយដ្ឋាន
ប្រាសាទតាកែវ នាងខ្មៅថ្កើងថ្កាន ពុកនៅចាំចាន
ឥតស្មានបំភ្លៃ ។

-ប្រាសាទអូរពង ក្បាច់ស្រស់បំព្រង គក់ទ្រូងថ្លាថ្លៃ
ប្រាង្គព្រៃប្រាសាទ ស្អាងស្អាតប្រពៃ ភ្នំដាប្រិមប្រិយ
ដូចដីរគ្រាំង ។

-ប្រាសាទចៅសាយ នាងពៅឆើតឆាយ ឥតថ្វាយកំបាំង
ប្រាង្គភូមិប្រាសាទ លួស្អាតថែងចាំង ដូចប្រាសាទឃ្លាំង
ព្រមទាំងកោះកែ ។

-សំបូរព្រៃគុក កូនអើយចាំទុក ពុកប្រាប់ហូរហែ
ប្រាសាទភ្នំធំ ភ្នំក្រោមផងដែរ កូនអើយស្និទ្ធស្នេហ៍
កុំប្រែក្រឡាស់ ។

-ប្រាសាទអណ្ដែត គយគន់មិនឆ្អែត ក្រឡែតជាក់ច្បាស់
ប្រាង្គដំបងដែក ក្បាច់ប្លែកស្អែកស្កះ ប្រាង្គកំពង់ព្រះ
ស្រឡះសង្ហា ។

-ប្រាង្គភ្នំបាសិត សោភ័ណប្រណីត វិចិត្រភ្លឺថ្លា
ប្រាង្គពូកអារក្ស ប្រាសាទអ្នកតា ចម្លាក់រចនា
ភ្លឺផ្កាចម្រុះ ។

-ប្រាសាទបាណន្ត ប្រាសាទមេបុណ្យ ពន្លឺចាំងឆ្លុះ
ប្រាសាទថ្មឮង គូលេនថ្មផុស កូនអើយចាំចុះ
លួស្រស់ពេកពិត ។

-ប្រាង្គព្រះវិហារ ព្រះគោសោភា ព្រះកែវប្រណីត
ប្រាសាទស្រឡៅ ឈរនៅថេរថិត ជីសូគាប់ចិត្ត
ថិតខ្ពស់អាកាស ។

Phnom-Penh University
LIBRARY

-ប្រាសាទអូរផ្លុង ប្រាង្គត្រពាំងផុង សាងសង់ស្រឡះ
ប្រាង្គដីរក្រាប ផុនដាបចំណាស់ កូនអើយជាម្ចាស់
ខ្ទះខ្មែរជួយថែ ។

-ប្រាង្គព្រលានស្ដេច រោងចិនរំលេច ក្បាច់ក្បូរគួរស្នេហ៍
ប្រាង្គរូបអារក្ស ផ្ទាក់ល្អពូកែ ប្រែរូបផងដែរ
កេរពីដូនតា ។

-ប្រាសាទច្រើនណាស់ ពុកចាំបានខ្លះ ប្រាប់មាសធិតា
កូនអើយចាំជាក់ ស្មោះស្ម័គ្ររក្សា មរតកថ្លៃថ្លា
ដួងព្រលឹងជាតិ ។

-យើងជាតិជាខ្មែរ កូនអើយស្និទ្ធស្នេហ៍ កុំបែរចង្អៀត
បិតិកភណ្ឌ លើអន្តរជាតិ យើងគ្មានអ្វីទៀត
លើសពីប្រាង្គប្រា ។

-កូនអើយអង្គរ ជាឃ្លាំងគំនរ គម្ពីរសាវតារ
សព្វក្បាច់ចម្លាក់ សិល្បៈរចនា បញ្ជាក់ពិស្ដារ
ចារចងប្រវត្តិ ។

-ស្ថាបត្យករ លោកផ្ដាំផ្ទាំងថ្ម បន្តទៀងទាត់
ផ្ញើខេមរបុត្រ កត់ស្នាមប្រវត្តិ ខ្មែរពិតធំធាត់
ល្បីល្បាញពូកែ ។

-ស្ងួនអើយកុំភ្លេច ចូរចាំជានិច្ច កុំគេចកែប្រែ
ស្មោះត្រង់ជាតិយើង ប្រឹងការពារថែ ទ្រព្យមរតកខ្មែរ
កេរពីដូនតា ។

***

Phnom Penh University LIBRARY

# "ការពារប្រសើរជាងព្យាបាល"

## "បទពាក្យ៧"

-**កូន** អើយបុព្វកាលដំណាលមក　　ពន្ទកគួរយកជាតម្រា
ជាតិខ្មែរខ្សែពូជអ្នកឧស្សាហ៍　　សោតទាំងប្រាជ្ញាឆ្លាតវាងវៃ ។
-ចរិតរាបសាតែក្លាហាន　　សាងបានវិមានប្រាសាទថ្លៃ
តម្កល់កេរ្តិ៍ឈ្មោះខ្ពស់ស្កឹមស្កៃ　　និមិត្តស្នាដៃខ្មែរអង្គរ ។
-នោះសក្ខីតាងយ៉ាងប្រត្យក្ស　　កូនអើយជឿជាក់កុំថាភរ
គ្រប់ទីបសកលយល់គាំទ្រ　　ស្ញប់ស្ញែងអង្គរព្រលឹងជាតិ ។
-ប្រវត្តិសាវតារជូនតាយើង　　ល្បីល្បាញរុងរឿងគ្មានវិវាទ
ឈ្នះសព្វបច្ចាអន្តរជាតិ　　ដែលប៉ងជ្រែកជ្រៀតជាតិបូរី ។
-ស្នាដៃបុព្វវីរជន　　ពិតមានគុណធ្ងន់លើទឹកដី
កិត្តិស័ព្ទនោះចាប់ជាសាក្សី　　ស្ងួនមាសប្រុសស្រីចូរចាំទុក ។
-សព្វថ្ងៃស្រុកទេសយើងសាន្តត្រាណ　　គ្មានអ្វីរំខានឱ្យកលិយុគ
ពេញសិទ្ធិសេរីផុតក្តីទុក្ខ　　សព្វកាលទៅមុខសុខសួស្តី ។
-ទន្ទឹមនឹងយើងបានសប្បាយ　　តើកូនគ្រប់កាយត្រូវធ្វើអ្វី ?
ឱ្យសមកុលបុត្រស្នងទឹកដី　　ស្នេហាបូរីកេរជូនតា ។
-កូនកុំភ្លេចខ្លួនពូនស្រណុក　　អាងសម្បត្តិស្តុកផុតទុក្ខា
ភ្លេចជាតិទឹកដីភ្លេចស្រែច្បារ　　ភ្លេចថែវប្បធម៌គ្រាដល់គ្រើយ ។
-ចូរចាំឱ្យជាក់អ្នកនៅក្មេង　　កុំឈ្លោះទាស់ទែងគ្នាឯងឡើយ
ប្រការបែកបាក់នោះឯងហើយ　　នាំជាតិឥតស្បើយរងទុក្ខា ។
-ដែនដីគោកធ្លកជម្រកមាស　　ពោរពាសដោយទ្រព្យសព្វប្រការ
សម្បត្តិសំបូរគួរចេតនា　　គន់គាប់ចិន្តាខ្មែរប្រុសស្រី ។

រ៉ែត្បូងធ្យូងថ្មល្អអនេក ភ្នំដែកភ្នំមាសពាសលើដី
ទន្លេបឹងអូរសំបូរត្រី គីរព្រឹក្សព្រៃសំបូរសត្វ ។

ធម្មជាតិព្រោងព្រាតអំណោយផល ទឹកដីយើងផ្តល់ភោគសម្បត្តិ
ប្រើប្រាស់គ្រប់គ្រាន់មិនមានខ្វាត់ សំបូរពេកក្តាត់សម្បត្តិជាតិ ។

កូនអើយចូរចាំអោយបានជាក់ នាងអ្នកនិត្យនៅត្រូវខ្វីឃ្លាត
ព្យាយាមរក្សាកុំចង្អៀត ថ្ងៃយប់អធ្រាត្រផ្ទៀតគិតគូរ ។

ចាស់ថាប្រហែសនាំបង់បាត់ ប្រឹងប្រែងប្រយ័ត្នប្រយោជន៍យូរ
កូនកុំដើរធ្វេចដេកទទូរ នេះជាគំរូពិចារណា ។

បើសិនបាត់ទ្រព្យកុំស្អប់ចោរ ពាក្យលោកផ្តាំម៉ោជាតម្រា
សម្បត្តិមិនខ្វាត់ត្បិតរក្សា ទ្រព្យបង់ផងណាត្បិតខ្ជីខ្ជា ។

កូនអើយស៊ូស្លាប់ក្រោមកិត្តិយស កុំចង់ដុះពោះព្រោះលោភា
ក្រចុះព្រោះស្មោះជាតិប្រជា កុំឃ្លានទ្រព្យាព្រោះប្រវ័ញ្ច ។

បើឱ្យត់រត់រកអំពកស្រែ កុំប្រែបែរចោលចោលដីខ្វាញ់
កុំស្អប់ខ្មែរជាតិញាតិសម្លាញ់ កុំដៀលផ្ទាលផ្ទាញ់កំណើតខ្លួន ។

ពន្ធកកើតមកត្រកូលខ្មែរ កុំបែរបែកចិត្តគិតគុំកួន
សាមគ្គីជានិច្ចកុំភ្លេចខ្លួន នោះទើបមាសស្ងួនផុតទុក្ខភ័យ ។

ដែនសុវណ្ណភូមិរូមកំណើត ល្អឆើតគ្មានផ្ទឹមលើលោកីយ៍
រំលេចពេជ្រពណ៌ពណ្ណរង្សី ដូចស្រីក្រមុំពេញលក្ខណា ។

ផ្ទៃដីមួយសែនប្រាំបីម៉ឺន មួយពាន់គីឡូម៉ែត្រក្រឡា
មរតកព្រេងព្រឹទ្ធពីដូនតា ចូរជួយរក្សាប្រឹងការពារ ។

កូនអើយទឹកដីជាជីវិត តោងវេញគំនិតដូចព្រឹទ្ធា
តាំងចិត្តធ្វើម្ចាស់ទាំងអស់គ្នា នោះមារមិនហ៊ានមកទ្រាន់ឡើយ ។

ដូច្នេះនាងអ្នកភ្ញាក់រលឹក　　កុំស្រពន់ស្ដីកធ្វើកន្ដើយ
កុំអាងបានស្ពានឈានដល់ត្រើយ　　កូនអើយបែរភ្លេចពីសសរ ។
ថ្ងៃអនាគតយូរអង្វែង　　គោរងកូនគិតក្រែងឱ្យបានល្អ
ស្ពានអាចឈរជាប់រាប់ជំណា　　អាស្រ័យសសរដែលទ្រទ្រង់ ។
ប្រការនេះឯងធំធេងណាស់　　គួរគិតឱ្យច្បាស់មាសធោមយង់
ស្ពានមិនបាក់ស្រុតផុតអន្ទង់　　គង់វង្សដោយសារគ្រឹះមាំមួន ។
រូបកូននេះហើយគ្រឹះសសរ　　ជាអ្នកបន្ដឈរខ្ជាប់ខ្ជួន
រួមចិត្តរួមកាយកុំឆ្ងាយខ្លួន　　នោះទើបមាំមួនគង់គាប់ជា ។
ការពារជាជាងយើងព្យាបាល　　ចាស់លោកដំណាលសមសោភា
ទោះនឹងអាសន្នជាន់គ្រោះគ្រា　　បើបានការពារសឹងផុតភ័យ ។
ឧបម័យមានស្រូវនៅជង្រុក　　សន្សំដាក់ទុកអចិន្ត្រៃយ៍
ទោះគ្រោះទឹកភ្លៀងរាំងជល់ក្ដី　　សឹងឆ្លងផុតភ័យក្ដីអត់ឃ្លាន ។
ម្យ៉ាងសោតបើមានខ្មាំងបច្ចា　　ប៉ុនប៉ងប្រាថ្នាចង់ឈ្លានពាន
ក៏យើងមិនខ្លាចអំណាចព្រាន　　ត្បិតមានវិធានការបំរុង ។
ប្រសិនបើខ្វះប្រុងប្រយ័ត្ន　　ជួនជួបវិបត្តិងងឹតស្លុង
ជំពប់ឧបសគ្គធ្លាក់សូន្យសុង　　គ្រោះព្រោះមិនប្រុងមិនបង្ការ ។
កុំត្រាប់មារយាទដូចសត្វរៃ　　ក្អេងក្អាងប្រពៃខាងរោហារ
សម្បើមធ្មើមឫកស្ដីកអាត្មា　　មិនស្វែងអាហារការពារធី ។
ខែប្រាំងរាំងភ្លៀងច្រៀងឡែៗ　　ក្លាហានពូកែស្នេហ៍សំដី
អាងសម្លេងឯកស្រែកខ្ទរព្រៃ　　តាំងខ្លួនថាល្បីលើសសត្វផង ។
ស៊ីផ្អែតមួយគែរស់មួយថ្ងៃ　　ពុំគិតមមៃថ្ងៃកន្លង
សព្វទាំងជម្រកក៏គ្មានផង　　ហាក់គ្មានទឹកផ្សងដល់ថ្ងៃមុខ ។

-វស្សាមកដល់គេតខ្វល់ខ្វាយ យល់ក្ដីសប្បាយក្លាយជាទុក្ខ
ព្រួយគ្មានអាហារគ្មានសំបុក វងាចាប់ចុករងទុក្ខភ័យ ។
-ភ្លៀងធ្លាក់ជោកជាំច្រើនសន្ទឹក រាងកាយទទឹកធ្លាក់ដល់ដី
ស្រមោចព្រួតគ្នាខាំក្រញី ក្លាយជាចំណីឆ្ងាញ់ពិសា ។
-កូនអើយមើលចុះសត្វស្រមោច ខ្លួនស្ដិតល្អិតល្មោចតែហានក្លា
ព្យាយាមស្វះស្វែងវែងឧស្សាហ៍ រួមសហការណ៍ចិត្តអំណត់ ។
-ពួកគេស្រុះស្រួលបបួលគ្នា សាមគ្គីសាមគ្គាមិនខ្លាចហត់
សន្សំអាហារការពារខ្យល់ ត្រៀមទុកមិនអត់គ្រប់វេលា ។
-កូនអើយត្រាប់តាមស្រមោចចុះ ពិតជាមិនខុសទេពុំងា
ចរិតព្យាយាមរួបរួមគ្នា ប្រឹងប្រែងស្ទុះស្ទាឥតទំរន់ ។
-ទៀតសោតដូចហ្វូងសត្វកណ្ដៀរ ពួកគេសាមគ្គាខ្លាំងពេកពន់
ខ្លួនល្អិតចិត្តធំផ្សំអធន ចរិតទន់ភ្លន់ស្មោះស្នេហ៍ស្និទ ។
-កូនមើលដំបូកធំស្កុកស្កឹង កណ្ដៀរខំប្រឹងច្នៃប្រឌិត
ប្រមូលកូនចៅផៅជីវិត ជញ្ជូនដីល្អិតគ្រាប់ធូលី ។
-នោះឯងសឹងមនុស្សស្មានមិនដល់ គួរកោតគួរឆ្ងល់គួរសំភី
ដំបូកស្កុកស្កឹងសឹងគិរី កើតព្រោះសាមគ្គីនៃសត្វល្អិត ។
-កូនអើយកុំត្រាប់តម្រាប់រៃ នឹងនាំទុក្ខភ័យដល់ជីវិត
តែលតោលឯកោខ្វះញាតិមិត្ត នោះពិតជីវិតឥតរស្មី ។
-ច្នេះហើយរស់នៅត្រូវខិតខំ សង្វាតសន្សំរួមប្រាស្រ័យ
រួមគ្នាការពារជាតិទឹកដី ស្មោះស្ម័គ្រមេត្រីគ្រប់បែបយ៉ាង ។

កូនអើយព្រះមហាឃោសនន្ទ លោកផ្ដែផ្ដាំជនជាភស្ដុតាង
ចរិតខ្មែរល្អដប់មួយយ៉ាង នេះពុកអះអាងឆ្លើយបញ្ជាក់ ។

-ទីមួយខ្មែរយើងមិនតក់ស្លុត ស្មារតីមោះមុតខ្លាំងអនត្ស
លោភៈ ទោសៈ និងមោហៈ ចិត្តខ្មែរពិតជាក់សង្កត់បាន ។

-ទីពីរខ្មែរមានប្ញកសុភាព ទន់ទាបរាបសាល្អចំណាន
ប្រជាប្រិយភាពថ្លៃថ្លើងថ្កាន និងអោយសន្ដានចិត្តជាបុណ្យ ។

-ទីបីខ្មែរមានកតញ្ញូ តបស្នងគុណគ្រូពិតពេកពន់
មាតាបិតាមិនមានស៊ុន គ្រប់អ្នកមានគុណមិនរើសមុខ ។

-ទីបួនខ្មែរកាន់នូវសីលប្រាំ ចងចាំប្រាំបីរក្សាទុក
វាងអកុសលចូលលុយលុក វៀរចាកក្ដីទុក្ខផ្អែកលើធម៌ ។

-ទីប្រាំខ្មែរអ្នកភ្ញាក់រលឹក ព្យាយាមយប់ព្រឹកអំពើល្អ
ខ្លួនទីពឹងខ្លួនសាងស្មោះសរ ប្រព្រឹត្តធម៌ល្អការពារខ្លួន ។

-ប្រាំមួយខ្មែរអ្នកផ្សាយមេត្តា មានករុណាមុទិតាផ្លូន
និងឧបេក្ខាព្រហ្មវិហារបួន ផ្សព្វផ្សាយម៉ាមួនដល់មនុស្សលោក។

-ប្រាំពីរខ្មែរមានចិត្តខន្តី អត់ធនប្រពៃក្ដីយល់យោគ
ពន្ធត់គ្រោះថ្នាក់ភាពទុក្ខសោក ដែលកើតមានមកចំពោះមុខ ។

-ប្រាំបីខ្មែរមានចិត្តអភ័យ សន្ដោសប្រណីផ្ដល់ក្ដីសុខ
មិនចាប់កំហុសធ្វើទោសទុក្ខ គ្រប់កលិយុគសុំសន្ដិភាព ។

-ប្រាំបួនខ្មែរមានសច្ចធម៌ សុចរិតស្មោះសរលើផ្ទៃរាប
មានសីលធម៌មិនខ្ពស់ទាប ឋិតក្នុងសភាពជាកណ្ដាល ។

-ទីដប់ខ្មែរកាន់នូវវប្បធម៌ ប្រពៃណីល្អខ្ពស់ត្រកាល
អាស៊ីអគ្នេយ៍ថ្លៃវិសាល ខ្មែរពិតដុះដាលលើសគេឯង ។

-ខ្មែរចេះទន់ភ្លន់ឱនលំទោន　ភ័ក្ត្រមិនស្រពោនស្រស់ចិញ្ចែង
ញញឹមប្រិមប្រិយដោយឯងៗ　វាចាថ្វាថ្វែងថ្លៃលើសលប់ ។
-ពាក្យពេចន៍ស្រទន់ហើយផ្អែមល្ហែម　ក្រអូបក្រអែមរាល់ថ្ងៃយប់
ជាបុប្ផវាទលាតសាយសព្វ　ឈ្ងុយឈ្ងប់ទៅគ្រប់ទាំងដប់ទិស ។
-ដប់មួយខ្មែរមានធម៌សាមគ្គី　រួបរួមសំភីមូលមិរគ្រឹះ
វេញចូលផ្លុងមួយជាគន្លឹះ　ចាក់គល់ចាក់ឫសរឹងមាំមួន ។
-កូនអើយពូជខ្មែរពូកែល្បី　ប្រុសស្រីពូតដៃឥតគេចពួន
ស្រឡាញ់ជាតិណាស់រៀងៗខ្លួន　ជ្រកកោនក្នុងសួនវប្បធម៌ខ្មែរ ។
-អង្គរជាកេរវប្បធម៌ជាតិ　គង់វង្សឥតឃ្លាតឥតកែប្រែ
ដំណដូនតារក្សាថែ　មិនចាត់បែកបែរទៅណាបាន ✓។
-កូនអើយចូរស្ងួយពុទ្ធសាសនា　ដើម្បីខេមរាសុខក្សេមក្សាន្ត
ពិសេសគ្រួសារយើងថ្កើងថ្កាន　ប្រសព្វសុខសាន្តអង្វែងទៅ ។
-កំណើតជាតិខ្មែរមានតែមួយ　មានពូជមានត្រកូលគង់វង្សនៅ
គ្មានខៀវក្រហមគ្មានសខ្មៅ　ត្រកូលត្រឹមត្រូវគ្មានពីរបី ។
-ខ្មែរគ្មានជើងត្បូងគ្មានលិចកើត　ឈាមជ័រកំណើតរួមប្ញូរ
ខ្មែរគ្មានពណ៌ប្លែកបែកទីទៃ　ប្រសូតិលើដីដែនសុវណ្ណ ។
-ច្នេះហើយយើងខ្មែរគ្រប់អង្គា　ចូររួបរួមគ្នាជាឯកច្ឆ័ន
កូនអើយអាស្វរវិញ្ញាណក្ខន្ធ　ដូនតាដែលកាន់ឋានភពថ្មី ។
-សង្គមធំធាត់ត្បិតគ្រួសារ　ជាកោសិកាជាតិទឹកដី
កិត្យានុភាពជាតិល្បាញល្បី　ត្បិតខ្មែរប្រុសស្រីមិនប្រេះឆា ។

***

# "ទំពាំងស្នងឫស្សី"

(បទពាក្យ៧)

-កូនអើយទំពាំងស្នងឫស្សី ប្រាជ្ញព្រឹទ្ធកវីស្នងតម្រា
ព្រះពុទ្ធ ធម៌ សង្ឃ ស្នងសាសនា អង្គព្រះក្សត្រាស្នងរាជវង្ស ។
-ពន្លកកើតមកជាកូនខ្មែរ ត្រកូលពូកែពីយូរលង់
ច្នេះហើយកូនអើយស្នងពូជពង្ស អម្បូរណ៍ផ្សរផង់ឱ្យគង់គាប់ ។
-រក្សាគុណធម៌ច្បាប់បុរាណ កាន់ខ្ជាប់គ្រប់ប្រាណជាទម្លាប់
បើកូនកែក្លាយឆ្ងាយបង្គាប់ ដូចដុតរំងាប់ច្បាប់បុព្វេ ។
-កូនអើយរក្សាឥរិយាបថ សីលធម៌បរិសុទ្ធណាមាសមេ
សុភាវធម៌នោះជាកេរ្តិ៍ កូនកុំងាករេប្រាសវិន័យ ។
-ជាអាទិដេកដើរឈរអង្គុយ កូនកុំប្រថុយទាំងពោលស្តី
ទោះហូបទំពារនោះផងក្តី គោងកូនរំពៃរំពឹងគិត ។
-ជាតិខ្មែរស្នេហ៍សិទ្ធពុទ្ធសាសនា កាន់ធម៌សាម្មាជានិមិត្ត
តែកូនកុំផ្អែកព្រហ្មលិខិត កម្មផលកម្រិតត្បិតខ្លួនសាង ។
-អំពើដែលល្អផលប្រណីត អំពើទុច្ចរិតខ្វះសំណាង
កម្មផ្តល់ជាផលមានពីរយ៉ាង កុំស្មានទៅខាងព្រេងវាសនា ។
-កុំកាច់បង្ខូចដេរពូជពង្ស ខ្លួនក្រខ្មៅល្ងង់ព្រោះដូនតា
ជៀលសព្ទម៉ែឪសឹងថ្លៃថ្លា បង្កើតកាយាឱ្យគោកយ៉ាក ។
-នាមជាពុកម្តាយអ្នករាល់គ្នា មិនចង់ឱ្យភ្នាខ្លួនលំបាក
ចង់ណាស់ស្រណុកសុខសំរាក ស្អប់ណាស់គោកយ៉ាកទីទ័លក្រ ។

-សក់មួយសរសៃថ្លៃជាងប់ គិតកូនសំណព្វដោយស្មោះសរ
លោកផ្តាច់ពីមាត់ព្រាត់ពីក ចិញ្ចឹមបវរមាសត្រាណត្រើយ ។
-ម្តាយនាងពរពោះប្រាំបួនខែ ទុក្ខលោកឥតល្ហែទម្រាំស្បើយ
បើលោកស្តូប់នាងលោកកន្ត្រើយ នាងទំផ្ទៃហើយអាយប្រហារ ។
-លោកតមចំណីប្រែហីរហើរ អង្គុយដេកដើរសព្វប្រការ
ទោះស្រេកឃ្លានធីអន្ទះសា មិនហ៊ានភោគ្គាសង្កត់ចិត្ត ។
-លុះវេលាកាលសំរាលហើយ លោកផ្សងឆ្លងត្រើយនៃជីវិត
សឹងល្បងស្លាប់រស់ព្រោះវរមិត្ត លោកផ្ញើជីវិតនឹងទេវតា ។
-ពេលកូននៅតូចជាទារក សព្វនោមលាមកផ្គរល់ហត្ថា
ទោះឆ្អើមឆ្អាបឆ្អេះលោកមិនថា ដាក់ចិត្តអាត្មាបំរើស្ងួន ។
-ឈ្លោះសព្វស្រមោចមូសសង្ការ ការពារធិតាថ្នមថែថួន
ហួបមិនត្រង់មាត់ខាតដេកពួន ថ្ងៃយប់ឱបស្ងួនច្រៀងបំពេ ។
-ទម្រាំនាងធំបានដឹងក្តី រយពាន់ទុក្ខភ័យគ្មានទំនេរ
ការខ្នងរងមុខទុក្ខគ្នាន់គ្នេរ នេះសូមមាសមេគិតវែងឆ្ងាយ ។
-កូនអើយកុំដៀលព្រះមានគុណ លោកធ្លាប់វែកពុនធ្លាប់ខ្វល់ខ្វាយ
នឹងខឹងឪពុកទុកមុខម្តាយ ន័យនេះឆោមឆាយពិចារណា ។
-ម៉ែឪជេរទៅលោកហៅមក ទោះខឹងពន្ទកសឹងធម្មតា
បើលោកខុសម្តងឆ្គងម្តេចម្តា កូនកុំផ្តាសាជេរផ្តន្ទា ។
-ទឹកដោះលោកថ្លៃលើជីវិត រំលែកលោហិតចិញ្ចឹមភ្ងា
ច្នេះហើយគួរគិតឱ្យគាប់ជា កាន់ចិត្តមារយា ជាកូនខ្មែរ ។
-បើខ្សត់ប្រឹងរកភ្នកគំនិត កុំផ្តាច់លោហិតចោលឪម៉ែ
ប៉ុណ្ណោះទោះក្រក៏ល្អដែរ ស្គាល់គុណពុកម៉ែទេព្តាជួយ ។

-ម្យ៉ាងទៀតញាតិផងរបងក្បែរ　　អម្បូណ៌ជាខ្មែរឈាមតែមួយ
យោគយល់ដល់គ្នាគ្រាទុក្ខព្រួយ　　មិនលែងថ្ងៃមួយគេជួយវិញ ។
-កុំធ្វើងកន្ទ្រើងព្រឹទ្ធាចារ្យ　　ជួបសួមពិការទុក្ខទោម្នេញ
សំពះសុំហើយជួយបំពេញ　　ទានបានមកវិញដោយកុសល ។
-កូនអើយជាតិមនុស្សគ្រប់អង្គា　　ខ្ពើមណាស់វេទនាក្តីខ្វាយខ្វល់
ប៉ុន្តែធ្វើម្តេចជាកម្មផល　　ត្បិតសាងកុសលមិនដូចគ្នា ។
-ព្រះពុទ្ធឱវាទលោកប្រដៅ　　ផ្តាំអស់កូនចៅគ្រប់វេលា
កាន់ខ្ជាប់សីលទាននិងភាវនា　　ពាក្យទាំងបីឃ្លានោះជាទុន ។
-ឃ្លាមួយកាន់សីលបានន័យថា　　មិនកាប់ប្រហារប្រមាថជន្ទ
ស្អប់អំពើបាបសាងតែបុណ្យ　　នោះហើយហៅជនដែលសីលមាន ។
-ឯឃ្លាទីពីរចូរកូនចាំ　　លោកផ្តាំថាឱ្យសន្សំទាន
នោះពិតសទ្ធាទ្រព្យធនធាន　　បរិច្ចាគពីប្រាណដោយសម្បត្តិ ។
-ទីបីភាវនាគឺការគិត　　ផ្តែកលើគំនិតគិតម៉ឺងម៉ាត់
ស្វែងពិចារណាប្រុងប្រយ័ត្ន　　ចូរប្រណិប័តន៍គ្រប់វេលា ។
-កូនមុនធ្វើអ្វីគប្បីគិត　　យកផ្លូវគំនិតមកពុះពារ
កាន់ខ្ជាប់ឱវាទភាវនា　　នឹងនាំឱ្យភ្ញាយល់ខុសត្រូវ ។
-ដូច្នេះចូរចាំរាល់រូបា　　ឃ្លាបីប្រការនោះជាផ្លូវ
នាំប្រាណឱ្យបានល្អត្រឹមត្រូវ　　បំបាត់បាននូវផ្លូវទុក្ខា ។

-**សច្ចៈ　ខន្តី　កតញ្ញូ**　　ព្រះបរមគ្រូសាស្តាចារ្យ
លោកផ្តាំប្រដៅជាតម្រា　　ឱ្យពិចារណាស្វះស្វែងយល់ ។
-សច្ចៈប្រែថាការទៀងត្រង់　　ចិត្តស្មោះផ្លូវផង់ណានិមល
ប្រកាន់ពាក្យពិតឥតអំពល់　　លោកថ្លែងពន្យល់ន័យពិស្តារ ។

-មិនប្រែក្រឡាស់ផ្លាស់ប្តូរចិត្ត　　មិនមានគំនិតគិតសាវ៉ា
មិនភរកុហកស្តីមុសា　　នោះហើយលោកថាធម៌សច្ចៈ ។
-រីឯខន្តីលោកស្តីថា　　មេត្តាករុណាចិត្តស្មោះស្ម័គ្រ
អំណត់អត់ធនមិនអន់អាក់　　កាន់ចិត្តត្រជាក់អហិង្សា ។
-មានចិត្តប្រណីក្តីសន្តោស　　មានអនុគ្រោះដោះទុក្ខា
កូនអើយនោះហើយហៅមេត្តា　　លោកថាវិរិយៈធម៌ខន្តី ។
-ឯធម៌ម្យ៉ាងទៀតកតញ្ញូ　　ចូរកូនគិតគូរឱ្យគប្បី
ប្រែថាតបស្នងសងគុណថ្លៃ　　ហៃមាសប្រុសស្រីចងចាំទុក ។
-ដូនតាបុរាណបានប្រដៅ　　ប្រាប់អស់កូនចៅជាទំនុក
អ្នកដែលធ្លាប់ជួយចម្លងទុក្ខ　　ផ្តល់ឱ្យក្តីសុខនោះជាគុណោ ។
-បុគ្គលនោះឯងត្រូវតបស្នង　　កូនកុំរំលងនោះស្រាលធ្ងន់
ធម៌កតញ្ញូប្តូរជាបុណ្យ　　ព្រះពុទ្ធផ្តាំជនគ្រប់អាត្មា ។
-ជាអាទិ៍សងគុណឪពុកម្តាយ　　លោកបង្កើតកាយថ្នមរក្សា
សងគុណអ្នកផ្តល់ផលបញ្ញា　　មានគ្រូអាចារ្យជាដើមផង ។
-អាណាព្យាបាលធ្លាប់គាំពារ　　ញាតិមិត្តមីងមាឬប្អូនបង
ធ្លាប់បានសង្គ្រោះគ្រាកន្លង　　កូនអើយតបស្នងកុំបំភ្លេច ។
-ចាស់ថាស្គាល់គុណមិនស្រយុត　　មិនងាយស្រកស្រុតធ្លាក់លង់លិច
ភ័ព្វរាសីរស់ខ្ពស់ជានិច្ច　　នេះជាពាក្យពេចន៍ពីដូនតា ។
-ច្នេះចូរចំណាំធម៌ទាំងបី　　សច្ចៈ ខន្តី ដ៏ថ្លៃថ្លា
ជាមួយនិងកតញ្ញូតា　　ចាំជាប់អាត្មាទាំងប្រុសស្រី ។
-ពុកនឹងរ៉ាយរ៉ាប់ប្រាប់ពុំងា　　ចារចងឃ្លោងឃ្លាជារឿងខ្ចី
ប្រវត្តិនិទានពីអតីត　　បុរាណលោកស្តីន័យពិស្តារ ។

-**ដំណាល**ថាមានមេគោមួយ   រស់រងទុក្ខព្រួយក្នុងព្រឹក្សា
ខែប្រាំងរាំងជល់ខ្វល់អាត្មា   ត្បិតខ្វះអាហារចិញ្ចឹមផ្ទៃ ។
-ថ្ងៃមួយមេគោចរចេញទៅ   ស្វែងក្នុងព្រៃជ្រៅរកស្មៅខ្ចី
បែជឱ្យប្រទះប៉ះខ្លាព្រៃ   ប៉ងចាប់ក្រញីជាអាហារ ។
-មេគោធ្ងត់ស្លុតញាប់ញ័រ   ឱនក្រាបអង្វរសុំពះខ្លា
សូមកុំពិសាច់ផ្តាច់សង្ខារ   ត្បិតខ្លួននោះណាមានកូនខ្ចី ។
-អាសូរដល់កូនស្ងួនតូចណាស់   បើម្ដាយព្រាត់ប្រាស់នោះនឹងក្ស័យ
គ្មានអ្នកបំបៅដល់កូនខ្ចី   ម្ល៉េះរងទុក្ខភ័យលុះមរណា ។
-មេគោអង្វរទ្រហោយំ   ក៏នៅខ្លាធំមិនមេត្តា
គម្រាមទាមទារជាអាហារ   ត្បិតខានភោគាមកយូរថ្ងៃ ។
-ខ្លាចាស់ឃ្លានណាស់ស្ទុះចូលជិត   មេគោដឹងពិតជីវិតក្ស័យ
ក៏លុតជង្គង់ក្រាបដល់ដី   អង្វរខ្លាព្រៃហើយសន្យា ។
-សុំទៅជួបកូនតែមួយភ្លែត   បំបៅឱ្យឆ្អែតវិលវិញរ៉ា
សន្មតរសៀលព្រះសូរិយា   ជូនខ្លួនឱ្យខ្លាប្រហារចុះ ។
-ខ្លាចាស់ស្ដាប់ច្បាស់ក៏មេត្តា   ត្បិតពូវាចាពោលដូច្នោះ
តែខ្លាបញ្ជាក់ដាក់កំហុស   ប្រសិនខកខុសពាក្យសន្យា ។
-ស៊ីទាំងកូនខ្ចីធីទាំងមេ   បើហ៊ានវៀចវេរក្បត់វាចា
នោះនឹងគេចខ្លួនពួនទីណា   គង់តាមប្រហារទាល់តែបាន ។
-មេគោត្រេកអរក្នុងចិន្ដា   ត្បិតខ្លាមេត្តាសន្ដោសប្រាណ
ក៏ស្ទុះបោលទៅលំនៅដ្ឋាន   ខ្លួនស្នាក់ត្រៀមក្សាន្តអចិន្ត្រៃយ៍ ។
-លុះបានជួបកូនបណ្ដូលចិត្ត   មេគោឱនលិទ្ធសព្វជើងដៃ
លួងលោមផ្ដែផ្ដាំកូនថ្លើមថ្លៃ   ឱ្យបៅឆ្អែតផ្ទៃថ្ងៃបង្ហើយ ។

-មេគោឈរយំបំបៅកូន មុនពេលខ្លួនស្លូន្យឃ្លាតព្រាណត្រើយ
រសៀលជ្រៀលជ្រេមេលាហើយ ខានបានកៀកកើយកូនសម្លាញ់ ។
-កូនគោបានស្តាប់ស័ព្ទមេស្តី រន្ធត់ស្មារតីចិត្តខ្វល់ខ្វាញ់
ខឹងខ្លាកំណាចចិត្តកំណាញ់ មិនគួរបំផ្លាញជីវិតម្តាយ ។
-កូនគោថ្ងូចថ្ងូរអាសូរមេ ក៏គិតគ្នាន់គ្នេរកើតខ្វល់ខ្វាយ
ទើបសំរេចចិត្តឥតសោកស្តាយ ប្តូរកាយទៅស្លាប់ជំនួសមេ ។
-កូនគោស្រែករោទ៍ហក់កញ្ជ្រោល ស្ទុះបោលចូលព្រៃមិនទំនេរ
ព្រួយណាស់ខ្លាចខ្លាប្រហារមេ ក្បិតថ្ងៃទន់ទេរជិតមកដល់ ។
-មេឃាត់អង្វរក៏មិនស្តាប់ នាំក្តីឈឺចាប់កើតខ្វាយខ្វល់
មេរត់តាមកូនស្ងួនវិមល រហូតបានដល់ជួបនឹងខ្លា ។
-ខ្លាឃើញមេគោអរអនត្ប ក្បិតកាន់សច្ចៈដូចសន្យា
ប៉ុន្តែខ្លាឆ្ងល់កើតសង្កា ម្តេចគោយាត្រាទាំងកូនផង ។
-ពេលនោះកូនគោឆ្លើយប្រាប់ខ្លា ថាខ្លួននោះណាមានបំណង
ស្លាប់ជំនួសមេឥតមានហ្មង នោះម្តងជូនខ្លួនជាចំណី ។
-អញ្ជើញលោកខ្លាពិសាចុះ ខ្លួនខ្ញុំតូចស្រស់សាច់នៅខ្ចី
ទាំងស្បែកទាំងឆ្អឹងនិងសរសៃ អញ្ជើញលោកធីជំនួសមេ ។
-មេខ្ញុំស្បែកក្រាស់ចាស់សង្វិត សាច់ឈាមនោះពិតមិនឆ្ងាញ់ទេ
សូមលោកពិនិត្យគិតរិះរេ ទុកជីវិតមេកុំប្រហារ ។
-មេគោមិនព្រមមិនសុខចិត្ត មិនឱ្យមាសស្និទ្ធកូនមរណា
ឧទានបញ្ជាក់ពាក្យសន្យា គឺខ្លួននោះណាជាចំណី ។
-ឃើញកាយវិកាគោទាំងពីរ ខ្លាចាស់សំភីគិតរំពៃ
ទើបកើតមានចិត្តត្រាប្រណី ខន្តីមិនធីជាអាហារ ។

ទឹកថាបើស៊ីមេឱ្យស្ងួន អាសូរដល់កូនរស់ឯកា
បើសិនស៊ីកូនខុសសន្យា ណ្ហើយគួរមេត្តាឱ្យរស់ចុះ ។
នេះពុកនិទានសង្ខេបខ្លី ប្រាប់មាសពិសីទាំងស្រីប្រុស
បូរាណប្រឌិតពិតដូច្នោះ បំភ្លឺចាំងច្បះសមហេតុផល ។
សច្ចៈ ខន្តី កតញ្ញូ នោះជាគំរូគួរតម្កល់
ញុំាំងឱ្យជីវិតផុតកង្វល់ ចាត់ជាកុសលដ៏ថ្លៃថ្លា ។
មេគោបង្ហាញភាពសច្ចៈ សន្យាជាក់លាក់ចំពោះខ្លា
កូនគោបង្ហាញកតញ្ញូតា ហ៊ានប្តូរសង្ខារសងគុណម្តាយ ។
ឯខ្លាកំណាចកាចអប្រិយ៍ បង្ហាញខន្តីប្រណីកាយ
រំដោះគ្រោះភ័យក្តីអន្តរាយ ឱ្យចៀសចាកឆ្ងាយពីជីវិត ។
កូនអើយចាំជាប់គ្រប់អាត្មា ធម៌បីប្រការជានិមិត្ត
ប្រសព្វកាយាវាចាចិត្ត នេះពាក្យពេចន៍ពិតពុកបញ្ជាក់ ។

**ក្មួន**កុំប្រមាថមនុស្សដូចគ្នា ទោះនឹងលីលាឆ្កួតពព្រាក់
កុំធ្វើមជិនធ្ងន់មនុស្សខ្វិនខ្វាក់ ក្រែងពៀរពានធ្លាក់ដាក់ដល់ប្រាណ ។
បើមិនសង្គ្រោះកុំស្តោះខាក ឃើញគ្នាគោកយ៉ាកខ្វះសន្តាន
បន្ថោកបន្ទាបប្រៀបតិរច្ឆាន ស្តីមិនប្រមាណប្រមាថហួស ។
បន្តុះបង្អាប់សព្វពូជពង្ស ឃើញពិតល្ងិតល្ងង់សឹងដូចងោះ
ប្រដូចឆ្កែឆ្មាថាជ្រលូស បញ្ចើចបញ្ចោះមនុស្សជាសត្វ ។
ឃើញគ្នាឱនកាយថ្វាយបង្គំ មាត់ហាហើបសុំប្រណមហត្ថ
មិនដាក់ទានទេបែរដេញខ្វាត់ ជេរពីរបីម៉ាត់បន្ថែមទៀត ។

HUN SEN LIBRARY R.U.P.P.

-កូនអើយនោះហើយអសប្បុរស ខ្វះធម៌សន្ដោសដល់មនុស្សជាតិ
កុំភ្លេចថ្ងៃនេះក្រមិនបៀត តែទៅមុខទៀតក្រែងជំពប់ ។
-កុំកោងកំណាញ់ក្រៅតម្រា កុំចោលសាសនាធ្លាប់គោរព
សន្សំសីលទានជាស្ពានម្លប់ ប្រភពសុខសាន្តចាកវេរា ។
-កុំងើបងើយហួសខ្ពស់ខ្លាំងពេក កុំចង់ទូលមេឃឱបចន្ទ្រា
កុំភ្លេចសារជាតិខ្មែរដូចគ្នា ពុកប្រាប់ពុំងាជាបណ្ដាំ ។
-កូនអើយឈើវៀចយកធ្វើកង់ រីឯឈើត្រង់យកធ្វើកាំ
ពាក្យចាស់បុរាណលោកបានផ្ដាំ ឱ្យផ្ចៀតចំណាំពិចារណា ។
-ឈើវៀចលោកអាចធ្វើជាកង់ ប្រៀបមនុស្សខ្វិនខ្វង់ថ្លង់ពិការ
ឈើត្រង់ធ្វើកាំលោកផ្ដាំថា ប្រៀបមនុស្សធម្មតាកាយល្អជា ។
-ដូច្នេះឈើវៀចឬឈើត្រង់ នោះគង់ប្រយោជន៍មានដូចគ្នា
កូនអើយរីមនុស្សគ្រប់អង្គា សឹងថ្លៃដូចគ្នាគ្មានថោកទាប ។
-ខ្វះក្រលៀតល្ងង់គង់រស់បាន គ្រាំគ្រាខ្លួនប្រាណតែមានប្រៀប
អ្នកខ្វះខ្ពស់ណាស់ខ្វះលទ្ធភាព ប្រាជ្ញាទន់ទាបរស់សៅហ្មង ។
-ចាស់ថាអ្នកខ្លាចជារបាំង រីឯអ្នកខ្លាំងជារបង
អ្នកកាចលោកអាចទុកជាខ្នង អ្នកកោងនោះផងទុកជាគ្នា ។
-កូនអើយកាន់ខ្ជាប់សមាធិ ទស្សនៈគតិមិនចងពៀរ
កុំទ្រុស្តប្រទូស្តមនុស្សដូចគ្នា ប្រព្រឹត្តអធ្យាកុំបំពាន ។
-ផ្ចាញ់អំពើបាបដោយសាងបុណ្យ ផ្ចាញ់កំណាញ់ជនដោយធ្វើទាន
ផ្ចាញ់នឹងឆ្មើងឆ្មៃដោយចងស្ពាន ផ្ចាញ់ពលសាមាន្យដោយចងមិត្ត ។
-ផ្ចាញ់នឹងហឹង្សាដោយខន្តី ផ្ចាញ់ព្រានអប្រិយ៍ដោយសុចរិត
ផ្ចាញ់នឹងមានះដោយថ្នមចិត្ត ផ្ចាញ់នឹងទុច្ចរិតដោយចិត្តធម៌ ។

-ផ្ចាញ់នឹងល្ងង់ខ្លៅដោយសិក្សា ផ្ចាញ់នឹងប្រេះឆាដោយស្មោះសរ
ផ្ចាញ់នឹងអាក្រក់ដោយធ្វើល្អ ផ្ចាញ់នឹងក្រីក្រដោយឧស្សាហ៍ ។
-ផ្ចាញ់នឹងកុហកដោយសច្ចៈ ផ្ចាញ់នឹងលោភៈដោយជ្រះថ្លា
ផ្ចាញ់នឹងទោសៈដោយករុណា ផ្ចាញ់នឹងមោហាដោយបំពេ ។
-កូនអើយចូរចាំចំណាំទុក ពាក្យពេចន៍ទំនុកពុករិះរេ
ទំនាក់ទំនងពីបុព្វេ កូនកុំទំនេរវេទំនៀម ។
-រក្សាកេរ្តិ៍ឈ្មោះខ្ពស់សាយសព្វ កុំខ្ជិលធុញថប់ឈប់ឈរស្ងៀម
យកចិត្តទុកដាក់ស្ងៃគ្រព្យាយាម ការពារទំនៀមទម្លាប់ខ្មែរ ។
-កុំដើរខុសផ្លូវគន្លងច្បាប់ ឪពុកប្រៀនប្រាប់ប្រឹងផ្តាំផ្ញើ
ប្រពៃណីជាតិគតឃ្លាតបែរ អាស្រ័យមាសស្នេហ៍ថែរក្សា ។

* * *

## "ស្រីល្អត្បិតចរិយា ប្រុសសង្ហាត្បិតវិជ្ជា"

(បទពាក្យ៧)

-ឱ! ហៃកូនមាសស្ងួនខ្លួនជាស្រី គួរគិតគប្បីពិចារណា
មនុស្សស្រីល្អពិតត្បិតចរិយា ពាក្យចាស់លោកថាដូច្នេះឯង ។
-មារយាទបូកពាជាចម្បង កូនកុំរំលងច្បាប់គាត់តែង
សុភាពទន់ភ្លន់គន់គួរក្រែង ញាតិផងគេថ្លែងថាស្រីល្អ ។
-ទោះសម្បុរស្បផងនួនល្អងខ្មៅ ក៏គង់គេហៅថាបវរ
គេថាខ្មៅចុះឱ្យតែស នោះហើយហៅល្អដោយចរិយា ។

-កូនអើយលក្ខណៈសម្បត្តិស្រី ចំណុចប្រពៃប្រាំប្រការ
សម្បត្តិទីមួយគឺចរិយា មារយាទរាបសាបញ្ញាវៃ ។

-សម្បត្តិទីពីរបានពីកាយ ពុកនឹងបកស្រាយបញ្ជាក់ខ្លី
លោកថាបញ្ចពិតកល្យាណី ស្ងួនអើយគប្បីយល់ពិស្តារ ។

-នោះឯងល្អពណ៌សម្បុរស្បែក ល្អទាំងកែវភ្នែករង់នេត្រា
ល្អបបូរមាត់ធ្មេញផងណា និងល្អកេសានោះផងដែរ ។

-សម្ផស្សធម្មជាតិពិតជាល្អ នោះនឹងខ្មៅសក្ដិកុំកែ
រក្សាលក្ខណៈនារីខ្មែរ នោះមានមន្តស្នេហ៍ហៅល្អគន់ ។

-នឹងត្រាច់យាត្រានោះជិតឆ្ងាយ តុបតែងរាងកាយកុំឱ្យស៊ិន
ពេញភ្នែកញាតិផងស្រស់ស្រទន់ នោះទើបគាប់គន់កាយសម្បត្តិ ។

-កុំតាក់តែងហួសឈ្មោះមិនល្អ ខ្មៅកែជាសក្រែមម្សៅផាត់
កែភ្នែកច្រមុះកោសកោរកាត់ កូនអើយប្រយ័ត្នមិនល្អឡើយ ។

-សម្បត្តិទីបីគឺវាចា ចូរពិចារណាកុំកន្តើយ
វចីសម្បត្តិនោះឯងហើយ ពុកផ្ដាំត្រាណត្រើយនាងជាស្រី ។

-កូនមានកិត្តិយសកេរ្តិ៍ឈ្មោះល្អ អាស្រ័យបវរនាងស្រដី
វាចាពីរោះមានអត្ថន័យ ពាក្យពេចន៍ពោលស្ដីឥតមុសា ។

-មិនស្ដីទ្រគោះឈ្លោះប្រកែក មិនជេរជជែកស្រែកចរចា
មិនចេះចាក់ដោតពីនរណា នោះហើយវាចាជាសម្បត្តិ ។

-ទីបួនពុកផ្ដាំប្រាប់ពុំងា ឱ្យកូនគ្រប់គ្នាប្រឹងប្រយ័ត្ន
ពាក្យចាស់បញ្ជាក់អនុម័ត វិជ្ជាសម្បត្តិប្រាកដច្បាស់ ។

គ្រប់កិច្ចការស្រីអ្វីសព្វផង    មាសស្ងួនទទួលល្អងកុំឱ្យខ្វះ
ថ្ងៃមុខលោកទុកជាមេផ្ទះ    ឈ្មោះស្ងួនឲ្យល្បីរស់ដោយធំ ។
ចេះរក្សាទ្រព្យរៀបទុកដាក់    នឹងចាយមាសប្រាក់ចេះសន្សំ
ចេះជួញលក់ដូរចេះផ្គត់ផ្គង់    គ្រួសារសុខស៊ុមត្បិតមេផ្ទះ ។
វិជ្ជាសម្បត្តិរបស់ស្ត្រី    ពុកពន្យល់ឱ្យបញ្ជាក់ខ្លះ
លក្ខណៈទីបួនស្ងួនចាំច្បាស់    សំខាន់ខ្លាំងណាស់ណាកូនអើយ ។
លក្ខណៈទីប្រាំគុណសម្បត្តិ    កាន់ខ្ជាប់កុំខ្វាត់ណាត្រាណត្រើយ
គ្រប់ការងារស្រីថ្ងៃធ្វើហើយ    កូនអើយបានពីអំពើល្អ ។
មិនដើរខុសឆ្គងគន្លងច្បាប់    ត្រងត្រាប់ប្រព្រឹត្តសុចរិតធម៌
បំពេញលក្ខណ៍ស្រីដោយស្មោះសរ    គោរពសីលធម៌ប្រពៃណី ។
នោះឯងថែងថាគុណសម្បត្តិ    ចូរប្រណិប័តន៍ខំសំភី
សម្បត្តិប្រាំយ៉ាងនៃនារី    កូនត្រូវសំភីពិចារណា ។
កូនអើយពេលនាងនៅលីវពេញភាគ    រក្សាកុំឃ្លាតច្បាប់ដូនតា
ស្ត្រីខ្មែរថែធំលើព្រហ្មចារ    កុំល្មេចលោភក់ការក្បត់ម៉ែឪ ។
នាមជាមាតានិងបិតា    ផ្ចាប់បីរក្សាបុត្រធោមធ្មៅ
មិនចង់ឃើញស្ងួនកូននៅព្រៅ    ន័យនេះនាងត្រូវពិចារណា ។
បើបានម្តាយទុកឪពុកដាក់    បំពេញលក្ខណៈព្រេងណោចារ្យ
ម៉ែពុកមានមុខមានវាសនា    ត្បិតមាសធីតាបានសងគុណ ។
ច្នេះហើយកូនអើយនាងជាស្រី    លោកផ្តល់តម្លៃនាងយ៉ាងធ្ងន់
បើឆ្វេងខុសផ្លូវត្រូវទារុណ    ញាតិសៀវរិះគន់បន្តពូជ ។
បើជាបុរសទោះខុសម្តេច    គេយកមាសពេជ្រមកប្រដូច
បើនាងជាស្រីធ្លោយខុសខូច    គេប្រៀបប្រដូចនឹងភក់ជ្រាំ ។

-ចូរចាំជាក្បួនស្នូនជាស្រី ក្នុងយុវវ័យលោកណែនាំ
ពុកស្ដីប្រដៅម្ដាយថែទាំ ការពារទម្រាំធំដឹងក្ដី ។
-រហូតធ្លងកាលវ័ស្សទាការ សំពះផ្កាស្លាមានស្វាមី
ម៉ែពុកសំរេចភ័ព្វនិស្ស័យ ឱ្យរស់នឹងប្ដីរៀងតទៅ ។
-នោះអនាគតចំពោះមុខ ឃ្លាតចាកបន្ទុកពីម៉ែឪ
ផ្ដើមមានអំរែកវែករកផ្លូវ ស្គាល់ការភាក់ជ្រៅនៃជីវិត ។
-ការស្ដ្រីអ្វីខ្លះគិតច្បាស់ច្បង តាមដោយគន្លងច្បាប់ព្រេងព្រឹទ្ធ
ភារៈសំខាន់ប្រកាន់ចិត្ត រក្សាជាប់ពិតភ្នក់ភ្លើងបី ។
-ភ្លើងមួយបំភ្លឺនៅក្នុងផ្ទះ គោរពឱ្យណាស់ចំពោះប្ដី
កុំឱ្យរលត់ទោះយប់ថ្ងៃ ភ្លើងនោះសក្ដិក្ដីសុខសាន្ត ។
-បើប្ដីនាងខឹងប្រឹងទ្រាំអត់ កាន់ចិត្តអំណត់សង្កត់ប្រាណ
សុខចិត្តចាញ់ចុះស្រស់កល្យាណ ខុសត្រូវប៉ុន្មានថ្នមចិន្ដា ។
-ភ្លើងពីរកុំនាំរឿងអាស្រូវ ពីក្នុងចេញក្រៅប្រាប់នរណា
ទោះប្ដីខូចខុសនោះម្ដេចម្ដា កុំបរិហារស្វាមីឯង ។
-ឯភ្លើងទីបីលោកប្រដៅ កុំនាំភ្លើងក្រៅចូលសម្លេង
ម៉ែឪប្អូនបងធ្លងទាស់ទែង គួរកុំថ្លាថ្លែងប្រាប់ដល់ប្ដី ។
-កូនអើយចូរចាំឱ្យប្រាកដ សំខាន់បំផុតចិត្តខន្តី
បើរក្សាបានភ្នក់ភ្លើងបី នោះទើបប្រពៃស្រីសុខសាន្ត ។
-គោរពស្មើស្មោះកុំលំអៀង ម៉ែពុកសងខាងញាតិសន្ដាន
ប្រជាប្រិយភាពបន្ទាបប្រាណ នោះពិតកល្យាណពេញលក្ខិណា ។
-មុស្លាបារីថ្ងៃយប់ព្រឹក ចំណីបាយទឹកម្ហូបអាហារ
ខោអាវសារស្បៃមុងក្រមា សំអាតគេហាស៍រៀបតុបតែង ។

-គោះជាភារៈនាងជាស្រី     មិនចាំបាច់ប្ដីស្ដីកំហែង

សព្វកិច្ចការស្រោលមិនលីសែង     គួរចេះចាត់ចែងកុំចាំប្ដី ។

-សម្ផ្ញាញ់បានដោយសារគ្រឿង     ស្វាមីរុងរឿងដោយសាស្រី

ឃ្លាមួយបុរាណលោកបានស្ដី     សំណាបយោងដីស្រីយោងប្រុស ។

-កុំ**លើក**ជើងឆ្លងកន្ទងប្ដី     កាន់លេងសិរសីមានកំហុស

ដំ**ណេក**កុំខ្ពស់ហួសគេប្រុស     ប្រមាថជួច្នោះខាតរាសី ។

-ស្រឡាញ់ស្មោះស្ម័គ្រថ្នាក់ថ្នមកាយ     កុំស្មន់សាហាយក្បត់ស្វាមី

ថែប្រពៃណីនាងជាស្រី     កុំចិត្តពីរបីអសោចកេរ្ដិ៍ ។

-ប្រយ័ត្នប្រុសព្រានមានមាសប្រាក់     បញ្ឆោតធ្វើធ្នាក់ទាក់ទាញស្នេហ៍

បាំងភ្នែកស្វាមីស្រីប្រួលប្រែ     លបលួចលក់ស្នេហ៍ផ្សងវាសនា ។

-តូចចិត្តក្បិតប្ដីរូបមិនល្អ     ម្យ៉ាងដោយក្រីក្រមិនហុំហា

តាំងផ្សំរឿងឈ្លោះឱ្យប្រេះឆា     រកកលយ៉ាងណាលែងលះប្ដី ។

-នឹកស្មានថាប្រាណភ័ព្វស្រណុក     សំណាងពូនសុខនិងអ្នកថ្មី

មិនគិតថាព្រានហ៊ានដៀលស្ដី     ហែកកេរ្ដិ៍អប្រីយ៍ស្រីដកទង ។

-អសោចខ្លួនណាស់ណានាងអើយ     បើមានប្ដីហើយកុំឱ្យឆ្គង

តស៊ូទ្រាំរស់ស្មោះគូគ្រង     កុំក្បត់រំលងចិត្តសាវ៉ា ។

-ធ្វើស្រែខុសម្ដងគង់ត្រូវម្ដង     ចាស់លោកចងក្រងជាតម្រា

បើស្រីខុសម្ដងឆ្គងមួយគ្រា     នោះនឹងឃើញផ្សាមួយជីវិត ។

-ច្នេះហើយកូនអើយខ្លួនជាស្រី     កេរ្ដិ៍ឈ្មោះថោកថ្លៃព្រោះគំនិត

មុនពេលរៀបចំគូជីវិត     ម៉ែពុកផ្ដល់សិទ្ធនាងសរេច ។

-ដូច្នេះទោះខុសត្រូវយ៉ាងណា     កូនអើយទេវតាចារមកស្រេច

អាសូរមេបាផ្សាឈាមសាច់     ម្ល៉ោះហើយប្ដូរផ្ដាច់រក្សាគ្នា ។

-កុំលេងឡេះឡោះខុសច្បាប់ស្រី     គ្រែងទាស់ចិត្តប្ដីគេនិន្ទា

កុំដេកផ្សំផ្ទួលដូចមារយា     ស្ងប់ខ្ញើមការងាររំពឹងប្ដី ។

កុំគិតតែម្យ៉ាងស្អាងកាយា    តុបតែងអាត្មាស៊ីវិល័យ
ហ៊ុំហាហួសពេកខុសភ្នែកប្ដី    នាំរឿងអប្រិយ៍ឱ្យខ្វែងចិត្ត ។
កុំប្រច័ណ្ឌហួសក្រែងឈ្លោះគ្នា    នាំខ្មាសមីងមាសពូញាតិមិត្ត
កុំប្រមាថប្ដីស្ដីមិនគិត    ចេះលាក់បាំងបិទចិត្តអធន ។
ប្ដីខុសតិចតួចកុំថ្លួចខឹង    កំហែងកំហឹងរឹងមិនទន់
កុំមុខមិនឱ្យក្រោយមិនគន់    ខុសស្រោលជាធ្ងន់ព្រោះហឹង្សា ។
កុំអួតចំណាប់បង្ក្រាបប្ដី    ឱ្យញាតិប្រុសស្រីស្ទើចរអា
ឃើញប្ដីស្លូតបូតភាពរាបសា    សឹងអញអើអាឥតរឯង ។
កុំជឿគេពេកក្រែងញុះញង់    ដៀលប្ដីឆោតប្វេង់ឃ្លង់សំរែង
ក្រងឹតក្រអេះក្រេះក្រវែង    កើតខ្មាសគេឯងលួចស្អប់ប្ដី ។
បំណាច់សំរេចដាក់កាយចិត្ត    ជាភរិយាពិតកុំគិតខ្វី
គោរពខ្ជាប់ខ្ជួនក្បួនច្បាប់ស្រី    ក្រែងពានសំដីគេបំបែក ។
កូនអើយទុកទៅនៅកំពង់    កុំឱ្យលិចលង់ក្នុងផ្លូវចែក
ញាតិសើចចំអកដូចបកស្បែក    ស្ដីបន្ទោសស្រែកដៀលមេបា ។
ដូច្នេះកូនស្រីគប្បីចាំ    ឪពុកសូមផ្ដាំឱ្យពិចារណ៍
ផ្ចាញ់ប្ដីអាស្រ័យថ្នមចិន្ដា    ការកេរ្ដិ៍មេបាឱ្យថ្នមញាតិ ។
កុំលើកតម្កើងប្ដីខ្ពស់ពេក    ថ្នមសព្វដើរដេកថ្ងៃអធ្រាត្រ
ប្ដីខ្លះបានចិត្តរឹតចោលម្សៀត    ថ្លើងបួកមារយាទប្រមាថនាង ។
ដូច្នេះហើយកូនអើយចំណាំទុក    ពាក្យពេចន៍ទំនុកពុករៀបរៀង
ផ្ទៀតពិចារណាកុំពង្វៀង    ពិនិត្យប្រិតប្រៀងនូវអត្ថន័យ ។
លោកថាភរិយាដែលល្អពិត    គឺឋិតនៅត្រង់ចិត្តភក្ដី
បុត្រល្អត្បិតស្ដាប់ទូន្មានស្ដី    ស្វាមីល្អពិតត្បិតប្រាជ្ញា ។

* * *

-ក្មួនអើយបើស្ទួនខ្លួនជាប្រុស ចាំពាក្យពុកចុះរាល់រូបា
ពាក្យពីបូរាណបានពោលថា មនុស្សប្រុសសង្ហាព្រោះវិជ្ជា ។
-កុំសេពគប់ច្រើនបនភៀនភ្លើ ថ្ងៃដេកយប់ដើរនាំលីលា
កុំចោលសិក្សាភ្លេចការងារ ក្លាយអវិជ្ជាខ្លួនល្ងង់ខ្លៅ ។
-ខំហាត់ពត់ខ្លួនទាន់នៅក្មេង ស្គាល់ស្តាំស្គាល់ឆ្វេងយល់សខ្មៅ
ព្យាយាមធ្វើតាមចាស់ប្រដៅ ប្រយោជន៍ធ្ងន់ធ្ងរដោយប្រាជ្ញា ។
កូនអើយប្រុសទ្រូងប្រាំហត្ថ លោកអនុម័តជាប្រស្នា
និយាន: ចាស់លោកចង់ផ្តាំថា ប្រុសគ្រប់អាត្មាត្រូវក្លាហាន ។
-មិនចាញ់ចុះញ៉មនឹងធម្មជាតិ មិនឱ្យចោលម្សៀតបៀតបៀនប្រាណ
អ្វីសព្វសារពើសឹងធ្វើបាន ក្រៅពីសាមាន្យពាលឫស្សា ។
-កូនអើយសំខាន់គឺចំណេះ បើមានតម្រេះចេះតម្រា
កូនសំរេចអ្វីតាមប្រាថ្នា ឈ្នះសព្វកិច្ចការផងនានា ។
-កើតជាកូនប្រុសឈ្មោះប្រពៃ រស់នៅលើដីក្រោមមេឃា
កុំឱ្យស្រីៗស្តីនិន្ទា ប្រុសអវិជ្ជាគួរអាម៉ាស់ ។
-វ័យយុវភាពត្រូវរាបសា កាយចិត្តវាចាធ្វើឱ្យណាស់
កុំកាន់កោងកាចធ្វើផ្តេសផ្តាស់ នាំគេជេរត្មះពូជឪម៉ែ ។
-កុំលេងសើចច្រើនគ្មានប្រយោជន៍ ប៉ប៉ាច់ប៉ប៉ោចដូចចៅឡែ
ចាស់លោកស្អប់ណាស់មនុស្សផ្កាផ្លែ ស្រូវលើសខ្ទបខែខាតអង្ករ ។
-កុំឱ្យម៉ែឪលោកអាប់មុខ កុំបំពេញទុក្ខនាំឱ្យក្រ
កុំនាំគ្រោះថ្នាក់អសីលធម៌ នាំល្អក់កករអម្បូរផៅ ។
-កូនអើយកុំចោលដំបូន្មាន ឪពុកប្រាប់ប្រៀនស្តីប្រដៅ
កូនមានកិត្តិយសព្រោះមិនខ្លៅ ច្នេះដុតអោយក្តៅទាន់នៅខ្ចី ។

-រក្សាតម្លៃនៃបុរស        កុំលេងឡេះឡោះឈ្លោះនឹងស្រី
ចេះសព្វខ្មាសអៀនមានខន្តី        នឹងដេកដើរស្តីគប្បីគិត ។
-កុំដេកទ្រមក់លក់លុះថ្ងៃ        លោកថាចង្រៃមករួមរឹត
ដេកស្ពឹកស្រពន់កុនគំនិត        រាសីងងឹតឥតពន្លឺ ។
-ចាស់ថាដេកយប់កុំដេកយូរ        កុំដេកទទូរដូចអ្នកឈឺ
ដេកក្រោកមុនព្រឹកកុំចាំភ្លឺ        លោកផ្តាំរន្ធឺជាទម្លាប់ ។
-កុំដេកផ្កាប់មុខឱបទុក្ខព្រួយ        ព្រះលោកមិនជួយនាំអភ័ព្វ
ប្រកបការងារវាមិនគាប់        នឹងស្វែងរកទ្រព្យបានតឹងតែង ។
-ម្យ៉ាងទៀតនឹងត្រាច់ចរយាត្រា        ទៅណាមកណាគួរគិតក្រែង
ប្រយ័ត្នផ្លូវខុសគ្រោះចំបែង        ន័យនេះគួរក្រែងពិចារណា ។
-កូនអើយបង់បោយឱ្យមើលប្រាណ        ដើរហើរប្រមាណដល់អាត្មា
កុំអាងខ្លួនប្រុសខ្វះពិចារ        ក្រែងលង់អាត្មាក្នុងអបាយ ។
-កាន់ឫកមារយាទជាអ្នកជា        កុំសេពពាលាវាអន្តរាយ
ថែកេរ្តិ៍ឪពុកទុកមុខម្តាយ        គេងគិតវែងឆ្ងាយណាប្រុសស្ងួន ។
-នឹងកាន់ការអ្វីឱ្យប្រាកដ        រឹងប៉ឹងមោះមុតចិត្តមាំមួន
ចាស់លោកពោលថាខ្លួនពឹងខ្លួន        ចាំឱ្យខ្ជាប់ខ្ជួនស្ងួនជាប្រុស ។
-កុំលួចបន្លែងល្បែងស្នេហា        ក្បត់ចិត្តមេធាក្រែងខកខុស
ក្លាយឈ្មោះជាព្រានមានកំហុស        ញាតិមិត្តស្រីប្រុសជេរដៀលត្មះ ។
-បើនឹងបំណងប៉ងពេញចិត្ត        បញ្ជាក់ការពិតកុំក្រឡាស់
ប្រាប់ម្តាយឪពុកឱ្យបានច្បាស់        នោះម្តងចាស់ៗពិភាក្សា ។
-លោកចូលតាមផ្លូវទៅតាមច្បាប់        ត្រាប់តាមទម្លាប់ពីដូនតា
ដណ្តឹងចងស្តាន់មានមេបា        ទើបផ្សំរៀបការជាសាក្សី ។

-លុះអនាគតតទៅមុខ កូនមានបន្ទុកគ្រួសារថ្មី
ម៉ែពុកចម្លងបឋមវ័យ ក្លាយជាស្វាមីនៃស្ត្រីម្នាក់ ។
-ពេលនឹមជីវិតខិតមកដល់ កូនត្រូវខ្វាយខ្វល់យល់ជ្រៅរាក់
ការសព្វសារពើកុំស្ទើរស្ទាក់ ធ្វើឱ្យជាក់លាក់អ្នកជាប្រុស ។
-ភារៈជាប្ដីធ្ងន់ធ្ងរណាស់ ព្យាយាមកុំខ្វះជៀសកំហុស
កុំឈ្លោះប្រមាថនាំខាតខុស កាន់ធម៌សន្ដោសដល់ភរិយា ។
-កុំទុកប្រពន្ធស្មើទាសី កុំអើអញ្ញីស្ដីមិនជា
ស្គាល់ទុក្ខធុរៈយល់អធ្យា ស្មោះស្ម័គ្រភរិយាកុំជិនណាយ ។
-កុំយកកំហល់ទល់កំហឹង បំណាច់នឹងខឹងដើរចេញឆ្ងាយ
កុំអាងវាយដំធាក់ច្រំកាយ នាំរឿងខ្វល់ខ្វាយឱ្យប្រេះឆា ។
-កុំកាន់គំនិតគិតក្រខ្វក់ បោកប្រាស់កុហកភរមុសា
មាត់ក្រៅផ្អែមល្ហែមថ្នមស្នេហា ចិត្តក្នុងឫស្យាក្បត់ប្រពន្ធ ។
-លួចលាក់មានស្រីចូលដៃពាល មិនក្រែងដំនៀលញាតិរិះគន់
ប្រកបកិច្ចការស្ដីកស្រពន់ ទំរើសទំរន់ចិត្តអប្រិយ៍ ។
-កូនអើយជាប្រុសចូរអ្នកចាំ កុំមើលបំណាំគ្នាជាស្រី
កម្លាំងទន់ខ្សោយជួយខន្តី មិនដូចយើងប្ដីកាយមាំមួន ។
-កុំមានទម្លាប់ប្រច័ណ្ឌស្រី នាំអាប់រាសីអសោចខ្លួន
ចោលការមកគិតចិត្តគុំកួន ប្រច័ណ្ឌខុសក្បួនខាតការងារ ។
-ធ្វើនេះក៏ខុសនោះក៏ឆ្គង អារម្មណ៍ហ្មហ្មងលើភរិយា
កូនអើយពិនិត្យគិតគាប់ជា កុំចោទផ្ដន្ទាជារឿងស្មាន ។
-ជូនអីស្រីផិតក្បិតពីប្រុស ប្ដីផ្សំកំហុសឈ្លោះរំខាន
បង្ករឿងហេតុមិនដែលក្សាន្ត ស្រីទ្រាំពុំបានកើតខូចចិត្ត ។

-ពាក្យម្យ៉ាងបូរាណចាន់ប្រដៅ    កុំពត់ស្រឡៅជាការពិត
បើស្រីប្រុងខ្វចល្វចក្បត់ជិត    ទោះប្រច័ណ្ឌស្និតគង់ផិតបាន ។
-ធ្វើចិត្តជាប្រុសស្មោះនឹងន    ប្រកាន់ជំហរឱ្យក្លាហាន
កុំឆាប់ច្កូលឆេះប្រេះឆាប្រាណ    ចេះប្រៀបប្រមាណកាន់ចិត្តធ្ងន់ ។
-ជួយផ្តល់តម្លៃឱ្យភរិយា    កុំបន្ទោកគ្នារងទារុណ
ជាប្តីអាស្រ័យយល់ប្រពន្ធ    ខន្តីអធនពិចារណា ។
-មនុស្សស្រីចិត្តស្រាលបណ្តាលខុស    ថ្នោះហើយជាប្រុសកុំហឹង្សា
កាច់ប្រពន្ធកាចដោយករុណា    កុំយកមោហាផាត់ផល់ព្រាណ ។
-ចូរចៀសឱ្យផុតឆ្កួតទាំងបី    បណ្តាំលោកស្តីពីបូរាណ
បើនឹងជ្រុលជ្រួសឈ្មោះតិរច្ឆាន    កូនអើយប្រុសប្រាណប្រឹងរំពៃ ។

* * *

# "ឆ្កួត បី"

(បទពាក្យ៧)

-បុរាណព្រេងព្រឹទ្ធពិតពោលថា ឆ្កួតមួយនោះណាគឺឆ្កួតស្រី
ទីពីរឆ្កួតស្រាកញ្ឆាក្ដី ឯឆ្កួតទីបីគឺឆ្កួតល្បែង ។
-ប្រការទាំងបីគោងជំរះ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែង
ជនសេពអបាយមុខនោះឯង លោកថ្លែងថាតែងតែវិនាស ។
-ជំពូកឆ្កួតស្រីលោកស្ដីថា ជនល្មោភកាមាអាសអាភាស
វង្វេងតណ្ហាស្នេហ៍ពោរពាស រោគនោះគួរចៀសវៀងឱ្យបាន ។
-ធម្មជាតិបណ្ដុះមនុស្សប្រុសស្រី ឱ្យរួមនិស្ស័យតសន្ដាន
តែមនុស្សប្លែកខុសពីតិរច្ឆាន ពោលគឺស្នេហ៍បានតែគូមួយ ។
-ជនខ្លះប្រែផ្លាស់ខុសក្រមក្រិត្យ ល្មោភរោគស្នេហ៍ស្និទ្ធឥតគិតព្រួយ
ប្រពន្ធមានដែរតែមិនស្លួយ មាសប្រាក់ចែកជួយស្រីមួយផ្សេង ។
-ស្រីមួយមិនស្កាំប្រាំមិនស្កប់ ផ្លាស់ប្ដូរមិនចប់ឡប់វង្វេង
ឃើញថ្មីភ្លេចចាស់ផ្លាស់រកក្មេង ស្រីលាបម្សៅប្រេងដូចទេវតា ។
-ឯស្រីល្អពិតចិត្តឥតល្អក់ ដៀលថាអាក្រក់ខ្ពើមរអា
ត្បិតគិតថែស្ងួនកូនធីតា ភ្លេចស្អាងកាយាសំរាប់ប្ដី ។
-ខ្លះទៀតប្រើស្នៀតភរមុសា បំផ្លាញប្រហារព្រហ្មចារស្រី
បំផុតស្នាមួយអំរែកបី នោះនឹងកើតក្ដីមិនចេះចប់ ។
-អាងឫកអាងរាងរូបសង្ហា ប្រាថ្នាសង្សារសឹងប្អូនដប់
លោភលន់តណ្ហាមិនធុញថប់ មិនស្កប់ហ៊ានលបប្រពន្ធគេ ។
-ចាស់ថាលួចបាននោះវាគ្រាន់ បើម្ចាស់គេទាន់ជាន់ទោសទ្វេ
ជ្រុលស្លាប់សឹងច្បាប់មិនគ្នាន់គ្នេរ សិទ្ធិលើប្ដីគេជំរះក្ដី ។

-ខ្លះទៀតនាំមករោគរាតត្បាត បំពានប្រមាថលើ សិរី
អាចឱ្យខ្វាក់ភ្នែកខ្វិនជើងដៃ ជម្ងឺអប្រិយ៍ឆ្លងកូនចៅ ។
-រោគនេះកំណាចកាចឫស្យា ផ្តល់ឱ្យគ្រួសារកើតសោកសៅ
រីងរៃប្រពន្ធកូនដំបៅ ឆ្លងតពូជជៅវង្សគ្រោះភ័យ ។
-ខ្លះអាងមាសប្រាក់បុណ្យស័ក្តិខ្ពស់ លក់សព្វកិត្តិយសព្រោះតែស្រី
ចាត់ទុកភរិយាជាទាសី ឃ្លើសចិត្តជេរស្តីអាងលែងលះ ។
-អាងនាងចើតឆាយរំសាយចិត្ត ដើរដេកភ្លេចគិតឥតចូលផ្ទះ
បិទសិទ្ធិប្រពន្ធមិនឱ្យឈ្នះ វាយដំច្រំទះខ្វះមេត្តា ។
-ជូននាំចើតឆាយមកដល់ផ្ទះ បង្គាប់ឱ្យព្រះសំពះខ្វា
ឱ្យកូនបំរើស្រីពេស្យា បំប៉នអាហារបំពេញចិត្ត ។
-ប្រុសថោកចាញ់ថោកស្រីចើតឆាយ កាន់ក្បាលជេរម្រាយក៏មិនគិត
លុះអស់ប្រាក់កាសនាងផ្លាស់ចិត្ត ចើតឆាយកៀកស្និតសាហាយថ្មី ។
-វិលរកផ្ទាំងចាស់មុខក្រាស់ឃ្នើក ម្ល៉េះព្រះគង់នឹកថាជាប្តី
ត្រកងឱបទៀតដោយខន្តី ស៊ូបន្ទោសស្តីព្រហ្មលិខិត ។
-តម្រាប់បែបនេះកូនមើលចុះ កើតជាបុរសកុំប្រព្រឹត្ត
គួរស្អប់គួរខ្ពើមគួរកុំស្និទ្ធ កូនអើយនោះពិតហៅឆ្កួតស្រី ។

* * *

-ជំពូកទីពីរគឺឆ្កួតស្រា នឹងនាំអាត្មាធ្លាក់អវិចី
ស្រវឹងកាលណាក្លាសំដី ឫកស្មើដីរស្តីចៅខ្សៀ ។
-មើលប្រពន្ធខ្លួនដូចបច្ចា មើលនាងលក់ស្រាដូចព្រះម៉ែ
ដឹងគុណដបស្រាជាងដីស្រែ ស្រឡាញ់អ្នកស្នេហ៍ជាងអ្នកស្និទ្ធ ។

-បានស្រាយចិញ្ចើមសម្បើមយ័ក្ខ    អ្វូតអាងទាត់ធាក់អាងស្បែកស្វិត
មិនខ្លាចពូថៅខ្វែវកាំបិត    មើលអ្នកផងល្អិតប៉ុនមេដៃ ។
-ពេលទទឹកស្វាបផាបអាត្មា    សម្បើមវោហារដូចខ្លាព្រៃ
ចំអាសចំអូមឥតសំចៃ    ពាក្យពេចន៍ព្រៃផ្សែអសោចកេរ្តិ៍ ។
-ឡូឡាឡូកច្រៀងតាមផងផ្លូវ    ញាតិផងមិនសូវចូលចិត្តទេ
អ្នកខ្លះស្អប់ណាស់លបលួចជេរ    ដៀលពូជបាមេបង្កើតកាយ ។
-ពូកែខ្លាំងណាស់ប៉ះរឿងឈ្លោះ    ទោះនឹងស្លាប់រស់ក៏មិនស្តាយ
បើសិនចាញ់ខាងកម្លាំងបាយ    នៅអាងជេរម្រ៉ាយស្តីបញ្ចោរ ។
-ខ្លះស្រវឹងខ្លាំងស្រវាំងអាប់    ស្ទេកស្ទាំងសឹងស្លាប់ភ្នែកស្ទក់ស្ទោ
ប្រមឹកដើរក្អួតដេកចង្អោរ    រប្ញូតអាវខោក៏មិនដឹង ។
-រូសរាយតែមាត់ធាត់តែមុខ    សាច់ដូចឧសពុកស្អុមកំព្រឹង
មុខហើមដូចហែកស្បែកត្រីខ្ជឹង    ប៉ុណ្ណឹងគង់ប្រឹងមិនចុះចាញ់ ។
-មានប្រាក់ត្រើម្រាក់ព្រួតគ្នាផឹ    ផឹកជក់បារីក្លែមសាច់ឆ្ងាញ់
អ្នកផ្ទះលីងបាយលាយកាកខ្លាញ់    ខ្ពស់ណាស់ត្រឹមក្រាញ់យូរៗម្តង ។
-ពេលអស់លុយផឹកទឹកម្លូម៉ៅ    វាយសព្វកូនចៅស្តីជេរផង
ខឹងចិនមិនជឿជំពាក់ម្តង    ក្របីគោផងហ៊ានលក់ផឹក ។
-មានប្រាក់កាលណាថ្វាគំនិត    ប្រមូលញាតិមិត្តហ្វូងប្រមឹក
នាំគ្នាស៊ីក្លែមថែមសន្ធឹក    សើចហោ៊រគគ្រឹកផឹកស្រង់ដើម ។
-បើបានអាមួយស្ទួយសរសើរ    បញ្ចើចបញ្ចើរលើកចិត្តថ្លើម
នោះពួកប្រមឹកប្ញូកីរតឆ្មើម    សប្បាយសម្បើមពុលសុរា ។
-ទោះអស់ប៉ុន្មានក៏មិនគិត    អាមួយឈរជិតសាច់សថ្លា
អរណាស់កូនចិនអង្គែលស្នា    ផឹកដូលត្រៀបត្រាបង្គួតចិន ។

-ប្រាក់មានប៉ុន្មានជូនទាំងអស់ មិនស្ដាយរបស់ត្រូវហោចហិន
ទូទាត់សេសសល់ផ្ញើទុកសិន សំពះចឹកចិនមិនភ្លេចគុណ ។
-ដល់ផ្ទះខំអួតស្រែកក្ដែងៗ ថាន៍ៃ អ៊ើងងកូនប្រពន្ធ
អញផឹកថ្លៃថ្នូរគួរគយគន់ ទោះដាបទោរទន់ដើរខ្លួនឯង ។
-លុះចូលជើងក្រានថ្នាំងទទេ ខឹងណាស់ស្រែកជេរឥតគិតក្រែង
បោកតុទូតាំងថ្នាំងអំបែង យំសើចម្នាក់ឯងរំខានញាតិ ។
-ប្រមឹកអ្នកក្រុងខុសអ្នកស្រែ បនបារញ៉ាំញៀយប់អធ្រាត្រ
ស្រីញីក្តិចខ្វាំចាំព្រោងព្រាត រាំរែកបញ្ញៀតឆ្ងៀតបិចបោច ។
-ស្រាបៀរកំប៉ុងចារាំងចិន បញ្ចុកមាសធ្មិនស្រីអសោច
ផឹកភ្លែមថ្លាល់ស្រីសំដីខ្មោច ទ្រព្យធនហិនហោចបង់អាសា ។
-ប្រពន្ធទូលច្រែងលក់ត្រកូន លោកប្ដីលេងខ្លួនចាយដុល្លារ
កូនខ្វះស្បែកជើងចូលសាលា លោកឪចូលបារជិះរថយន្ត ។
-មិត្តភ័ក្ដិម្រាក់ក្លើដើរផឹកស៊ី ពុលស្រាស្រីញីលក់ទ្រព្យធន
លួចលាក់បញ្ចាំចាយអស់ទុន ក្បត់កូនប្រពន្ធផ្ដាប់ពួកម៉ាក ។
-ចុងក្រោយបង់បោយដើរដូចឆ្កួត អស់អួតមុខស្លូតធ្លាក់តោកយ៉ាក
អស់គេរអស់ផ្ទះអស់មិត្តម៉ាក ញាតិផងស្ដោះខាកខ្ពើមឬកពា ។
-ខកខ្លួនលិចលង់ក្នុងអបាយ អង្គុយនឹកស្ដាយក្លាយលីលា
ផ្ដល់ទុក្ខទារុណកូនភរិយា សោតសឹងប្ដូជាខ្លួនឱ្យក្ស័យ ។
-កូនអើយនោះហើយហៅឆ្កួតស្រា ចាំជាប់ចិន្ដាអចិន្ត្រៃយ៍
បើចៀសវាងបានប្រាណអ្នកថ្លៃ ទើបឈ្មោះប្រពៃពេញជាប្រុស ។
-កុំបន្ថោកពូជបង្ខូចពង្ស នាំខ្លួនលិចលង់ក្នុងកំហុស
មនុស្សថ្លៃជាងស្រាណាកូនប្រុស កុំបន្ទាបឈ្មោះថោកជាងស្រា ។

-កូនអើយសុរាជាឱសថ តាមក្បួនកំណត់គ្រូដូនតា
តែស្រាពិសពុលកាចឫស្យា អាចបែរប្រហារសង្ខារបាន ។
-បើផឹកសន្ទឹកហួសកំណត់ នោះស្រាឱសថថ្នាំបុរាណ
ក្លាយជាអាវុធផុតរោលប្រាណ គ្រោះថ្នាក់សាមាន្យមើលមិនជា ។
-ក្រពះពោះវៀនមានដំបៅ សួតថ្លើមផ្សាក្តៅឈឺគ្រាំគ្រា
ខូចខួរប្រសាទក្លាយលីលា នេះពុកផ្តាំភ្នាជាកូនប្រុស ។

* * *

-៦ល្បួតទីបីល្បែងពាលា អាប៉ោងប៉ោបៀរជាកំហុស
ជនដែលប្រព្រឹត្តពិតជាខុស ចូរចាំទុកចុះប្រុសនិមល ។
-អ្នកចាញ់គេព្រឹកនឹកស្រមៃ សងសឹកពេលថ្ងៃលែងអីជល់
អ្នកឈ្នះចង់លះដល់ឫសគល់ មិនក្រែងលេងជ្រុលចាញ់វិញអី ។
-គេថាសេះដាច់យកសេះតាម មិនខ្លាចរហាមធ្លាក់ក្រក្រី
ចាញ់លុយមិនឱ្យចាញ់ចិត្តអី ពាក្យពួកគេស្តីមិនគួរស្តាប់ ។
-ពួកនោះបើឈ្នះមុខឡើងខ្លាញ់ តែបែរបើចាញ់មុខដូចស្លាប់
បានឈ្នះខំអួតឱ្យគេស្តាប់ បើចាញ់មិនប្រាប់ខ្លាចអាប់មុខ ។
-ជួនពេលព្រលប់ស្រស់ប៉ប្រិម លុះពេលព្រលឹមស្អុយគគ្រុក
ជួនព្រឹករីករាយល្ងាចកើតទុក្ខ អ្នកល្បែងឃើញមុខងាយចំណាំ ។
-ចំណុចម្យ៉ាងទៀតផ្ទៀតសំគាល់ អ្នកលេងរៀងរាល់វាល់ខែឆ្នាំ
កម្រឃើញធាត់សាច់ក្រមាំ ច្រើនរោគរ៉ៃរុំាស្គាំងស្គមប្រាណ ។

-ត្បិតបាយមិនទឹកទឹកមិនស្រេក សោតទាំងដំណេកក៏មិនបាន
ជក់ដៃទោះថ្ងៃយប់ថ្មើរម៉ោន សឹងសូន្យទាំងប្រាណក៏មិនខ្លាច ។

-របរនេះឯងវែងអំពល់ បានឈ្លក់ងប់ងល់ជ្រុលបែកប្រាជ្ញ
ចាញ់បង់លង់ខ្លួនជូនលែងខ្លាច ប្រព្រឹត្តកោងកាចហ៊ានលួចឆក់ ។

-ក្លាយខ្លួនធ្វើចោរចិត្តឫស្យា ហ៊ានកាប់ប្រហារបោកកុហក
ចាញ់ល្បែងឈឺចិត្តគិតខ្វល់ខ្វក់ សាងកម្មអាក្រក់ចិត្តអប្រិយ៍ ។

-ឯអ្នកជើងល្បីលេងល្បែងឈ្នះ កម្រឃើញណាស់ផ្ទះសង់ថ្មី
ឮតែប្រពន្ធដៀលជេរស្តី ជូនអីស្រី។គេសុំលែង ។

-កូនអើយអ្នកល្បែងវែងមុខក្រាស់ ហ៊ានកាត់កេរ្តិ៍ខ្មាសចេះទ្រាំទ្រែង
លួងលោមញាតិមិត្តឥតប្រជែង បើឈ្លោះទាស់ទែងក្រែងខាតលាភ ។

-ហោប៉ៅមានប្រាក់ពាក់មុខខ្លា គ្មានលុយកាលណាមុខសុភាព
សំពះគេឯងវែងថោកទាប ដាក់ខ្លួនដុនដាបដើរបុលខ្ចី ។

-លុះគេទារប្រាក់ស្អាក់ប្រពន្ធ គ្មានសោះទ្រព្យធន់អត់សល់អ្វី
មានតែខ្លួនប្រាណសាច់សខ្ចី សងគេជួសប្តីខ្ចីជំពាក់ ។

-ឯជនជាវែកមិនដឹងខ្យល់ ឃើញគេមកដល់ហៅអាម្រាក់
គេថាអាណិតណាស់មិត្តភក្តិ លុយខ្ចីជំពាក់ឯងកុំភ័យ ។

-អញជួយសង្គ្រោះព្រោះឯងចាញ់ សូមក្លើសម្លាញ់កុំសងអី
វែកឮដូច្នេះអរប្រិមប្រិយ សុំរាប់លុះក្ស័យមិនភ្លេចគុណ ។

-នោះឯងផ្លូតល្បែងវារិនាស ហិនហោចប្រាក់មាសអស់ទ្រព្យធន
ខូចអនាគតកូនប្រពន្ធ ផ្តល់ទុក្ខទោសធ្ងន់កើតខ្វល់ខ្វាយ ។

-កូនអើយឈ្មោះថាល្បែងស៊ីសង គួរដើរកន្លងចៀសឱ្យឆ្ងាយ
គ្រប់ល្បែងល្បងភ្នាល់វាល់អបាយ សុទ្ធសឹងអន្តរាយដល់អាត្មា ។

នេះពុកផ្តាំទុកតរៀងទៅ    ពេលពុកមិននៅឃ្លាតធិតា
កូនកុំបន្ទែងល្បែងស្រីស្រា    ឆ្គួតបីប្រការហៅទុច្ចរិត ។

* * *

**ពុក៖** លើករឿងមួយមកពណ៌នា    ជាតិសាសន៍ឥណ្ឌាបានប្រឌិត
តាមពាក្យដំណាលថារឿងពិត    និងថ្លែងនិមិត្តតាមសាវតារ ។
មានគ្រួសារមួយត្រកូលខ្ពស់    ដើមឡើយគាប់យសសេដ្ឋីមហា
សម្បត្តិភោគទ្រព្យគាប់ចិន្តា    មានប្រាក់ស្រែច្បារមិនខ្វះអ្វី ។
ក្រោយមកក៏ធ្លាក់ដាក់ដុនដាប    ដោយអំពើបាបរបស់ប្តី
សេពគប់ជំពប់មិត្តអប្រិយ៍    ប្រព្រឹត្តស្រាស្រីល្បែងពាលា ។
ហិនហោចសម្បត្តិផ្ទះសម្បែង    គ្រួសារលះលែងខ្វែងចិត្តគ្នា
ប្តីរស់ជាមួយក្រុមចោរមារ    ប្រពន្ធវេទនានិងកូនស្រី ។
រហាមដេកតាមចិញ្ចើមថ្នល់    ទុក្ខព្រួយកង្វល់ហួសស្រដី
ជីវិតម្តាយរស់ព្រោះកូនស្រី    ស្វែងរកកម្រៃធ្វើខ្ញុំគេ ។
ថ្ងៃមួយរូបនាងវងគ្រោះថ្នាក់    ដោយពួកពាលស្ទាក់ចាប់មាសមេ
ស្របម្តាយឈឺធ្ងន់ទុក្ខគ្នាន់គ្នេរ    យំអង្វរគេ  គេមិនស្តាប់ ។
ឃើញពាលរំលោភកូននឹងមុខ    ទ្រូងម្តាយចាប់ចុកដាច់ខ្យល់ស្លាប់
ពាលឥតខ្មាសអៀនគ្មានឈឺចាប់    ប្រញាប់បង្ខំនាំនាងទៅ ។
លុះដល់គ្រឹះស្ថានផ្ទះសំណាក់    ដែលពួកពាលស្នាក់រស់និត្យនៅ
មេចៅហ្វាយធំចិត្តឃោរឃៅ    នឹកស្មានបានស្មៅឆ្ងាញ់ពិសា ។
ស្រាប់តែសម្រែកស្រែកហៅពុក    ទូញសោកនឹងមុខផ្ទាល់នេត្រា
យល់ជាក់ជាកូនស្ងួនធីតា    ទើបស្លុតអាត្មាវិលស្មារតី ។

-គ្រានេះឪពុកទុក្ខទោម្នេញ អារម្មណ៍វង្វេងលែងយល់អ្វី
រន្ធត់តក់ស្លុតផុតប្រក្រតី ឱនឱបកូនស្រីសើចលាយយំ ។
-ស្ទុះទាញអាវុធមកកាន់ក្តាប់ ចាញ់រះសម្លាប់ពាលតូចធំ
ម្តងសើចម្តងហៅខ្ទរព្រៃភ្នំ ម្តងបែរស្រែកយំៗបោកខ្លួន ។
-នោះឯងប្រែកាយក្លាយវិកល ចុកចាប់ខ្សាប់ខ្សល់ផលហុចផ្ទួន
សំពះសុំទោសកូនស្រីស្ងួន ទើបប្រហារខ្លួនដោយខ្លួនឯង ។
-នោះឯងលទ្ធផលបន្សល់ទុក យល់ពិតនឹងមុខឃើញជាក់ស្តែង
ចេញពីប្រភពស្រីស្រាល្បែង ឆ្កួតបីនោះឯងផ្តល់ទុក្ខា ។
-នេះពុកនិទានសង្ខេបខ្លី បញ្ជាក់អត្ថន័យពិតពិស្តារ
ចូរកូនពិនិត្យគិតខ្លឹមសារ និងពិចារណាដល់ជីវិត ។
-កូនអើយស្គាល់ផ្លូវត្រូវនិងខុស កើតមកជាប្រុសកុំភ្លេចគិត
កុំខ្វាត់មារយាទឃ្លាតគំនិត សន្សំសុចរិតកុំខិតឆ្ងាយ ។
-សំខាន់បំផុតការសេពគប់ ប្រយ័ត្នជំពប់ពាលអន្តរាយ
នាំខ្លួនលិចលង់ក្នុងអបាយ គួរគ្រោចផ្លូវត្រោយកុំលុកព្រៃ ។
-មុនដេកភ្នែកបិទគិតគូរនឹក ភ្ញាក់មុនរលឹកទើបប្រពៃ
បើកូនខ្វាចខ្វាខំផ្តារព្រៃ នេះពុកពោលស្តីផ្តាំមាសស្ងួន ។

* * *

# "ដើរមានបី ស្ដីមានបួន"

(បទពាក្យ៧)

កូនអើយចាស់ថាដើរមានបី ប្រើនឹងស្ដីនោះមានបួន
ន័យនេះល្អល្អះណាស់ណាស្ងួន លោកទុកជាក្បួនប្រដៅស្ដី ។
នេះន័យអត្ថបដិរូប ពុកឆ្លើយបង្រួបសង្ខេបខ្លី
ពាក្យដែលលោកថាដើរមានបី ពិតមានអត្ថន័យនិងខ្លឹមសារ ។
ទីមួយមុនពេលចរលីលា មើលពេលវេលាត្រូវយាត្រា
យប់ថ្ងៃមមែប៉ងទៅណា មិនគួរប្រាថ្នាតាមតែចិត្ត ។
ឧបម័យអង្កេតហេតុឆោឡោ ក្រែងជាន់ដានចោរជនឧក្រិដ្ឋ
ដូចអូសសម្រាស់ប៉ះពាក្យពិត ត្រូវពាលទុច្ចរិតចោទតម្រង់ ។
ទីពីរមើលផ្លូវត្រូវដើរហើរ មិនគាប់ប្រសើរគួរបង្អង់
ឃ្លាមួយផ្លូវវៀចកុំបោះបង់ ឯផ្លូវដែលត្រង់កុំដើរហោង ។
ដូច្នេះគួរត្រិះពិចារណា បំណាច់យាត្រាកុំឱ្យហ្មង
គិតដល់ទិសដៅត្រូវត្រាច់ឆ្លង តើផ្លូវណាផងល្អគប្បី ។
ទីបីគួរគិតពិនិត្យជាក់ ចំពោះមិត្តភ័ក្តិក្លើម្រាក់ក្ដី
គួរដើរជាមួយឬកុំអី ចូរស្ងួនប្រុសស្រីរំពៃស្ដាប់ ។
ដើរហើរសេពគប់មិត្តស្មោះសរ នាំខ្លួនឱ្យល្អមិនឱនអាប់
ដើរចូលមិត្តពាលនាំឈឺចាប់ មិត្តផ្ដល់ក្ដីស្លាប់កុំរួមរក្ស ។
ពុកនឹងបកស្រាយន័យម្យ៉ាងទៀត មិនឱ្យហួសឃ្លាតឆ្ងៀតបញ្ជាក់
ពាក្យដើរមានបីស្ដីប្រត្យក្ស បន្តឃ្លាវគ្គចាប់ចុងចូន ។
ទីមួយលោកថាកុំប្រមាថ ជីវិតមនុស្សសត្វណាមាសស្ងួន
អំពើទុច្ចរិតគិតគុំកួន តាមក្បួនបាលីហៅថាណា ៕

-ទីពីរកុំលួចសម្បត្តិគេ ច្បាប់ពីបុព្វេផ្តល់ទោសា
អំពើឆក់ប្លន់ចិត្តឫស្យា ចាលីស្តីថាអទិន្នាទាន ។
-ទីបីកុំក្បត់ប្រពៃណី គួរកូនសំភីខំសូត្ររៀន
កុំកន្លងច្បាប់បូរាណប្រៀន នោះមានកាមេសុមិច្ឆា ។
-នេះពុកផ្តែផ្តាំចាំឱ្យជាក់ ឃ្លាទាំងបីវគ្គមានខ្លឹមសារ
ពាក្យដើរមានបីស្តីពិស្តារ បូរាណចែងចារដូច្នេះឯង ។
-ចំណែកអត្ថន័យស្តីមានបួន លោកទុកជាក្បួនឱ្យគិតក្រែង
លោកចោទប្រស្នាឱ្យខំស្វែង បកស្រាយថ្លឹងថ្លែងលើអត្ថន័យ ។
-ទីមួយកុំស្តីភរកុហក ពោលពាក្យអាក្រក់មិនគប្បី
ភូតចាញ់អាត្មាដូនតាស្តី ចាលីពោលថាមុសាវាទ ។
-ទីពីរកុំស្តីជេរទ្រគោះ បញ្ជោរបញ្ឆោះឈ្លោះមិត្តញាតិ
ចាលីស្តីថាបរុសវាទ ន័យនេះពុកផ្ញៀតប្រាប់ឆោមឆាយ ។
-ទីបីកុំស្តីពាក្យចាក់ដោត ញុះញង់នោះសោតនាំខ្វល់ខ្វាយ
បង្ករជម្លោះប្រទូស្តរាយ ចាលីបកស្រាយបិសុណាវាទ ។
-ទីបួនចូរស្ងួនចាំឱ្យច្បាស់ សំខាន់ខ្លាំងណាស់កុំបីឃ្លាត
ហៅថាសម្ផប្បលាវាទ កូនអើយកុំឃ្លាតផ្ញៀតត្រង់ត្រាប់ ។
-នោះគឺមុនស្តីគប្បីគិត កុំពោលប្រឌិតខុសក្បួនច្បាប់
ពាក្យឥតប្រយោជន៍អាចនាំអាប់ ពោលមិនចំណាប់អាប់អាត្មា ។
-ចូរចាំឱ្យជាក់វគ្គទីបួន មុនស្តីគួរស្ងួនពិចារណា
កុំលេងសើចខុសមាត្រា ពាក្យមិនបានការណានឹមនួន ។
-កូនអើយកាយកម្មនោះមានបី រីឯវចីកម្មមានបួន
ព្រះធម៌លោកចែងជាច្បាប់ក្បួន ដើរបីស្តីបួនដូច្នេះឯង ។

- រួមនិងមនោកម្មមានបី　　គម្ពីរបាលីលោកតាក់តែង
អំពើនៃចិត្តពិតជាក់ស្តែង　　ចេតនានោះឯងផ្តល់វិបត្តិ ។
- ទីមួយកុំក្លួចគន់រំពៃ　　ទ្រព្យអ្នកដទៃត្រូវប្រយ័ត្ន
កុំប៉ងចង់បានគេងបំបាត់　　លោកអនុម័តហៅអភិជ្ឈា ។
- ទីពីរហៅថាព្យាបាទៈ　　កុំកាន់ទោសៈចិត្តយ័ក្ខមារ
កុំចងគំនុំគុំកួនគ្នា　　បន្ទន់ប្ញកពាជាអ្នកល្អ ។
- ទីបីគឺមិច្ឆាទិដ្ឋិ　　នោះជាគតិលោកបន្ត
កុំយល់ខុសឆ្គងគន្លងធម៌　　កាន់ចិត្តស្មោះសរកុំបំភ្លៃ ។
- ច្នេះហើយកូនអើយចូរចំណាំ　　លោកផ្តាំមនោកម្មមានបី
ស្របនិងកាយកម្មក៏មានបី　　រួមនិងវចីកម្មមានបួន ។
- នោះពិតប្រសូតិពីកម្មបទ　　កំណត់មានដប់គ្រប់ចំនួន
គឺកាយវាចាចិត្តណាស្ងួន　　ប្រាកដតាមក្បួនលោកសង្ខេប ។

* * *

# "កុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប"

(បទពាក្យ៧)

-កូនអើយកុំស្លាប់ដូចសត្វពស់ បើរស់កុំដូចសត្វកង្កែប
ពាក្យពីបុរាណមានបទបែប កូនអើយខំក្រេបពិចារណា ។
-ពាក្យថាកុំស្លាប់ដូចសត្វពស់ លោកពន្យល់មនុស្សរាល់រូបា
កុំឱ្យដាក់ខ្លួនឱនអាត្មា គេជាន់សិរសាក៏មិនស្តី ។
-បើរស់រងការកៀបសង្កត់ មិនត្រូវអំណត់ហួសខន្តី
ស្វែងយល់គតិបំភ្លឺភ្លឺ កុំស្លាប់វាហើដូចសត្វពស់ ។
-ធម្មជាតិបង្កើតកាយសរពាង្គ ជីវិតរូបរាងដង្ហើមរស់
មនុស្សសត្វកើតមកប្លែកតែឈ្មោះ ត្រង់ស្លាប់និងរស់មិនខុសអ្វី ។
-អនិច្ចំ ទុក្ខំ អនត្តា កើតស្លាប់ធម្មតាជាប្រក្រតី
តែមនុស្សខុសប្លែកសត្វដទៃ ស្លាប់មានតម្លៃសល់កេរ្តិ៍ឈ្មោះ ។
-ពុកនឹងប្រៀបធៀបន័យមួយទៀត កូនកុំចង្អៀតឆ្ងៀតពិគ្រោះ
លោកថាកុំឱ្យស្លាប់ដូចពស់ ឃ្លានេះពីរោះមានអត្ថន័យ ។
-សត្វពស់ប្រៀបមនុស្សដែលឃោរឃៅ រស់នៅអាស្រូវចិត្តអប្រិយ៍
ប្រព្រឹត្តកោងកាចអន្យត្ថិរ្យ ហ៊ានកាប់ប្រល័យចិត្តឫស្យា ។
-លុះដល់ពេលខ្លួនសូន្យជីវិត អ្នកផងឆ្ងាយជិតគេរអា
សូម្បីសាកសពសូន្យសង្ខារ សឹងគ្មាននរណាហ៊ានចូលជិត ។
-គេត្រេកអរណាស់ទោះចាស់ក្មេង គេលោតកញ្ឆេងលែងភ័យភិត
គេផ្សងបន់ស្រន់ឱ្យសូន្យពិត ស្លាប់ចុះញាតិមិត្តផុតភ័យខ្លាច ។
-នោះហើយហៅស្លាប់ដោយគ្មានន័យ ព្រោះតធ្លាប់អប្រិយ៍ចិត្តកោងកាច
ប្រៀបបានសត្វពស់រឈ្មោះកំណាច ញាតិផងខ្ពើមខ្លាចស្អប់អាត្មា ។

កុំស្លាប់ដូចពស់ដូថ្នោះឯង ភាសិតលោកថ្លែងពិតពិស្តារ
លោកឱ្យកូនចៅពិចារណា កុំឱ្យអាត្មាស្លាប់ដូចពស់ ។

**ម្យ៉ាង**ទៀតកុំរស់ដូចកង្កែប ន័យនេះសង្ខេបមិនបង្អួស
លោកចង់ប្រដៅទៅចំពោះ ផងជនដែលរស់ខ្ពស់សំដី ។
សម្បើមសំបូរដោយវោហារ ព្រោកប្រាជ្ញវាចាអួតខ្លួនល្បី
បើកភ្នែកបើកមាត់បើកសំដី អង្គុយលើល្អីលើកខ្លួនឯង ។
ប៉ាច់ប៉ោចមាត់ស្រួចស្រាវ មិនខ្វះរឿងរ៉ាវស្ដីថ្វាថ្លែង
ក្អេងក្អាងក្អាកក្អាយអួតខែងរ៉ែង មិនខ្លាចរឯងក្រែងចិត្តគេ ។
បំភ្លៃបំផ្លើសថ្កុះចាក់ដោត ភូតភរបញ្ឆោតបញ្ឆោរជេរ
បង្អាច់បង្អួចស្ដីដើមគេ គ្មានផលអ្វីទេជួញគេស្អប់ ។
ប្រៀបនឹងកង្កែបអែបត្រពាំង ប្រឹងស្រែកពួខ្លាំងមិនស្ងៀមស្ងប់
សត្វផងលួចជេរគេធុញថប់ កង្កែបត្រឡប់ជាសប្បាយ ។
ពេលអាសន្នដល់ទល់ជំរក ទើបស្ទុះទៅមកភ្លុកខ្វល់ខ្វាយ
សត្វអត់មារយាទផ្សៀតផ្ញើកាយ រន្ធគេទាំងឡាយកាយទុកស្រាប់ ។
ជួនត្រូវរងគ្រោះអន្តរធាន កង្កែបសាមាន្យនាំក្ដីស្លាប់
ស្រែកអួកព្រានលូកដៃញិចចាប់ ម្ចាស់រន្ធរងស្លាប់ជាមួយដែរ ។
នេះពុកជង្ហោយមិនឱ្យត្រាប់ កង្កែបប្រាជ្ញអាប់មិនពូកែ
បានខាងក្អេងក្អាងស្រែកឡប់ឡែ បើនឹងស្និទ្ធស្នេហ៍គេផ្ដាសា ។
មើលចុះសម្ងំក្រោមដើមឈូក ស្រែកយំអួកៗសោះសោកា
ដេកត្រាំភក់ផុកស្អុយរអា មិនយល់ឈូកផ្កាក្រអូបសាយ ។

រស់នៅបង្អើយក្បែរបង្គិត ចាញ់កន្ទង់ល្អិតហើរពីឆ្ងាយ
ក្រុបរសលំអងឥតជិនណាយ កង្កែបនៅអាយខ្វះគំនិត ។
នេះឯងពុកថ្លែងដោយសង្ខេប កុំត្រាប់កង្កែបល្ងង់ងងឹត
កុំរស់តែមាត់ភ្នែកដូចបិទ ញាតិមិត្តឆ្ងាយជិតពួនប្រមាថ ។

* * *

## "អណ្ដាតជាអាថ៌កន្លង"

(បទពាក្យ៧)

កូនអើយអណ្ដាតអាថ៌កន្លង បានសុខទុក្ខផងព្រោះអណ្ដាត
ចូរកូនចងចាំខំសង្វាត តម្កល់ជាខ្នាតពិចារណា ។
បំណាច់នឹងស្ដីកុំបីស្មាន គោងគិតប្រមាណពាក្យពិស្ដារ
ប្រាកដជាក់ស្ដែងសឹមថ្លែងថ្វា ប្រយោគមុសាគួរវាងចៀស ។
នេះម្ដងទ្វងល្ងងត្រូវរិះគិត សំដីយើងពិតថ្លៃជាងមាស
ពាក្យមិនប្រពៃកុំពោលពាស នាំថោកនិរាសដល់អាត្មា ។
កុំកាច់ត្រកូលមូលត្រគាក កុំពាំនាំពាក្យឥតខ្លឹមសារ
កុំយករឿងគេមកបរិហារ ឃ្លាមួយចាស់ថាពេស្យាមាត់ ។
កុំអួតអុងអាត់មានតែអញ ក្រែងគេស្អប់ខ្ពាញ់លួចវាយវាត់
ចាស់ថាកំភ្លាញស្លាប់ព្រោះមាត់ អ្នកប្រាជ្ញចេះស្ទាត់គង់ភ្លាត់ស្ដី ។
សំដីជាឯកលេខជាទោ អក្សរនមោទុកជាត្រី
មនុស្សខ្លះកើតយសព្រោះសំដី មនុស្សខ្លះអាចក្ស័យព្រោះវាចា ។

-កូនអើយទឹកឃ្មុំផ្អែមឈ្ងុយឆ្ងាញ់ តែគង់នៅចាញ់រសវោហារ
តែបើរបើល្វីងហួសពិសា នោះពិតវាចាលើសគ្រាប់ស្លែង ។
-អាវុធមុតស្រួចគឺវាចា ថាមពលខ្លាំងក្លាគួរកោតក្រែង
វាអាចប្រហារអាត្មាឯង ចេះត្រូវប្រយែងប្រយ័ត្នស្តី ។
-មិនជុះកុំជោមឱ្យផ្អែអរ ឃ្លានេះកំដរលើអត្ថន័យ
គ្រោតគ្រាតមែនពិតតែគប្បី ចូរកូនរំពៃពិចារណា ។
-ចាស់ថាស្ងៀមស្ងៀមជាងស្រដី ទំពាចេកខ្ចីជួសវាចា
អផ្សុកបុកស្រូវច្រៀងសក្រវាទិ ជាជាងថ្លែងថាការមិនពិត ។
-កូនអើយបើចេះឱ្យគេកោត បើឆោតឱ្យគេជួយអាណិត
ច្បាប់គ្រូមុនគួរលោកឱ្យគិត ប្រយ័ត្នកាំបិតចិតដងឯង ។
-កុំបាចអង្កាមបញ្ច្រាសខ្យល់ ពាក្យចាស់តម្កល់យូរអង្វែង
បើស្តោះកុំស្តោះលើទ្រូងឯង កូនអើយមុនថ្លែងកុំភ្លេចថ្លឹង ។
-បើល្ងង់កុំប៉ងធ្វើបណ្ឌិត បើភ្នែកងងឹតកុំសម្លឹង
បើត្រចៀកថ្លង់កុំចង់ដឹង បើគកុំប្រឹងចង់ស្រដី ។
-កុំលេងភូតភរឆរបញ្ឆោត ល្បិចល្បងចាក់ដោតល្បែងបំភ័យ
កុំហកលេងសើចបញ្ចើញស្តី បំផ្លើសបំភ្លៃច្នៃកំសាន្ត ។
-ការពិតចិត្តប៉ងលេងត្រង់ស្មោះ តែគេឯណោះថារំខាន
នាំគេភ័យព្រួយរញ្ជួយប្រាណ សប្បាយក្លាយបានជារឿងក្តី ។
-នោះហើយអណ្តាតអាថ៌កន្លង បូរាណចងក្រងសង្ខេបខ្ចី
អណ្តាតអាចនាំសុខសួស្តី ជូននាំទុក្ខភ័យឱ្យអាត្មា ។

* * *

ពុទ្ធលើករឿងមួយមកបញ្ជាក់　　មានបុរសម្នាក់ល្ងង់ក្រៃណា
ថ្ងៃមួយមិត្តខ្លួនបានពោលថា　　ផ្ទះឯងនោះណាមានកំណប់ ។
នែ៎ ក្លើសម្លាញ់អញប្រាប់ឯង　　យប់មិញអញគេងហើយយល់សប្តិ
ឃើញច្បាស់មានមាសមួយប្រអប់　　ព្រះឥន្ទ្រលាក់កប់ទុកក្រោមផ្ទះ ។
ឯបុរសល្ងង់បានឮភ្លាម　　ទាំងព្រឹកព្រហាមស្ទុះរូតរះ
រំភើបញាប់ញ័រអរខ្លាំងណាស់　　រត់ទៅសំពះតាហោរា ។
ពឹងឱ្យទស្សន៍ទាយរាយជើងលេខ　　មានប្រាក់មានចេកពពិសការ
តើពិតមិនពិតពាក្យមិត្តថា　　ផ្ទះខ្លួននោះណាមានកំណប់ ។
តាហោរាឮសួរពាក្យនោះភ្លាម　　មិននៅស្ងាត់ស្ងៀមឥតធុញថប់
សាកសួរខែឆ្នាំរាប់គ្រប់សព្វ　　ទើបឆ្លើយកំណប់ពិតជាមាន ។
បុរសនោះអរឥតឧបមា　　នឹកថាទេព្តាពិតប្រទាន
ក៏ផ្តើមចាយវាយទ្រព្យធនធាន　　ព្រោះដឹងថាមានមាសមិនខ្វះ ។
លុះចាយអស់ទ្រព្យទើបខ្វល់ខ្វាយ　　កាប់គាស់កកាយដីក្រោមផ្ទះ
ជីកទាំងយប់ថ្ងៃថ្មើរួតរះ　　មិនពើបប្រទះកំណប់សោះ ។
ជីកកាន់តែជ្រៅទៅរឹតឆ្ងាយ　　កក្លូរកកាយសព្វកៀនកោះ
នៅតែមិនជួបទ្រព្យរបស់　　រហូតផ្ទះនោះរលំគ្រេង ។
ក្រោយមកបុរសជាមិត្តភ័ក្តិ　　បញ្ជាក់ថាខ្លួននិយាយលេង
ក៏កើតជម្លោះឈ្លោះវង្វេង　　ប្តឹងផ្តល់ប្រជែងកើតប្រេះឆា ។
នោះហើយតម្រេះផិះកឯង　　ភូតភរបន្លែងលេងមុសា
បំផុតបង់ទ្រព្យជួយសាងស្ពារ　　នោះពិតវាចាប្រហារប្រាណ ។
ចំណែកមួយទៀតតាហោរា　　គួសវាសលើក្ការឆ្លើយថាស្មាន
គេជេរជៀលត្មះចាស់សាមាន្យ　　ព្រោះតែប្រថានប្រថុយស្តី ។

-កូនអើយកើតឈ្មោះព្រោះកុហក ផលនោះអាក្រក់មិនគប្បី
អណ្តាតពិសពុលយល់ទុក្ខភ័យ ដោយសារសំដីស្តីមិនគាប់ ។
-មួយម៉ាត់ចំណេញមួយម៉ាត់ខាត កុំពោលខុសខ្នាតឃ្លាតទម្លាប់
ក្រែងខាតប្រយោជន៍ខូចទាំងទ្រព្យ ប្រយ័ត្នឱ្យជាប់ពាក្យសំដី ។
-ឃ្លាមួយចាស់ថាស្គរកោកៗ សឹកមាត់ត្រដោកឆ្អែតពោះក្របី
ជាសុភាសិតព្រឹទ្ធកវី ផ្តាំស្នូនប្រុសស្រីពិចារណា ។
-បំណាច់នឹងស្តីអោយគេស្តាប់ ឱ្យគេត្រង់ត្រាប់ចាប់ជាការ
ចៀសវាងសឹកមាត់ហត់អាត្មា ព្រោះតែវាចាពោលឥតន័យ ។
-នោះឯងប្រៀបបានស្គរត្រដោក កោកៗបណ្តោកកក្របី
ពោះគេគង់ឆ្អែតដោយស្មៅខ្ចី ត្រដោកបំភ្លៃសឹកមាត់ឯង ។
-កូនអើយសំដីផ្សំប្រាជ្ញា នោះទើបពិស្តារគេកោតក្រែង
កុំយកវាចាចាត់ជាល្បែង គប្បីថ្លឹងថ្លែងក្រែងភ្លាំងភ្លាត់ ។
-មុនចាប់ដើងក្រានប្រមាណធ្នាំង តូចទាបកុំតាំងជាធំធាត់
ស្ពាក់ស្ពើរកុំធ្វើជាអ្នកស្ទាត់ ភ្លេចភ្លាំងនាំភ្លាត់មុខមាត់អាប់ ។
-មុនចាប់ច្រវាសម្លឹងត្រើយ ពាក្យពេចន៍ពោលហើយឱ្យគេត្រាប់
កុំឱ្យសឹកមាត់អួតចំណាប់ នេះពុកប្រៀនប្រាប់ទុកបន្ត ។

* * *

# "ទូកទៅកំពង់នៅ"

(បទពាក្យ៧)

**កូន**អើយទូកទៅកំពង់នៅ ចាស់លោកប្រដៅច្រើនដំណា
សាងអំពើបាបផលមិនល្អ សាងបុណ្យស្មោះសរល្អពូជផៅ ។
ពេជ្រមិនទាន់ច្នៃថ្លៃមិនខ្ពស់ មនុស្សអាប់កេរ្តិ៍ឈ្មោះព្រោះល្ងង់ខ្លៅ
ដាវដែលមុខមុតព្រោះដុតក្តៅ មនុស្សចេះឆ្លៃឆ្លៅព្រោះសិក្សា ។
ប្រាជ្ញពឹងតំរេះចេះក្បួនច្បាប់ ជរាពឹងស្វាប់ពាលពឹងក្លា (១)
ទារកពឹងយំឃ្មុំពឹងផ្កា វិស័ត្វវាចាពឹងទំនុក ។
កុំពុសខ្លឹមឈើធ្វើជាខ្នួច ហើយកុំសម្រួចឈើដែលពុក
ធ្វើស្រែមើលស្មៅជាត្រីយ៍មុខ កូនចៅដាក់ទុកមើលសន្តាន ។
កូនអើយកុំធ្វើស្រែប្រវាស់ កុំនៅរួមផ្ទះរួមជើងក្រាន
ជង្រុករលស់រង្គោះចាន វណ្តំបែកបានមិនខានទេ ។
គ្រូកាចអាចនាំឱ្យសិស្សខូច មារយាទសរពូជណាមាសមេ
សំដីសរជាតិមិនឃ្លាតទេ ចេះឯងក្រែងគេចូរប្រយ័ត្ន ។
ទំពក់វាទៅទើបព្នៅមក ទឹកមានរលកព្រោះខ្យល់ផាត់
សាងល្អផលល្អពួមិនស្វាត់ សាងទោសវិបត្តិស្អុយកេរ្តិ៍ឈ្មោះ ។
នោះហើយទូកទៅនៅកំពង់ ន័យនេះតម្រង់លើកិត្តិយស
មនុស្សជាតិឃ្លាតទៅសល់កេរ្តិ៍ឈ្មោះ ពាក្យនេះពីរោះកូនអើយស្តាប់ ។
លោកថាសន្ទៀមកុំបំបោល ក្រែងពានពុំដល់គោលប្រញាប់
លឿនណាស់ប៉ះគ្រោះមិនបានប្រាប់ នោះកិច្ចការធ្លាប់ក្លាយជាយូរ ។
លោកថាតក់ៗពេញបំពង់ ពាក្យពីយូរលង់ជាគំរូ
តក់ៗទឹកស្រក់បង្អក់យូរ តែគង់ហៀរហូរពេញបំពង់ ។

-ឪពុកផ្ដាំស្ងួនកូនប្រុសស្រី មុនគិតការអ្វីថ្ងៃស្អាបស្អង់
កុំស៊ីតាមឃ្លានហ៊ានតាមចង់ ច្បាប់លោកតម្រង់ប្រដៅស្ដី ។
-បើខ្លួនទាបតូចស៊ីដូចមូស គួរកុំខំផុះតាមដំរី
ពិចារណាចុះមាសប្រុសស្រី ចាស់លោកស្រដីជាបណ្ដាំ ។
-កុំឃើញអ្នកមានមកចងមិត្ត ខ្លាចគេមិនស្និទ្ធជាប់យូរឆ្នាំ
ខ្លួនក្រត្រដររខ្វីបញ្ចាំ លក់ច្បារដំណាំបង្គួតមិត្ត ។
-បញ្ចោរអ្នកមានថាខ្លួនល្អ ក្លើអើយអញក្រទ្រព្យមែនពិត
តែទោះអស់អ្វីអញមិនគិត បានឯងជាមិត្តអញមានមុខ ។
-ទូកតូចកុំផ្ដួចរកក្ដោងធំ ខ្យល់បក់រលំកលិយុគ
មើលមាឌមើលរាងនាងចាំទុក នឹងឈានទៅមុខនឹកដានក្រោយ ។
-ទឹកហូរពីទួលទៅទំនាប ប្រុងប្រៀបរៀបប្រាណមុនបង់ពោយ
ចូលស្ទឹងតាមបត់ពិតមិនធ្លោយ នេះពុកដង្ហោយឱ្យគិតក្រែង ។
-កូនអើយបើក្រឱ្យទល់គ្រប បើរំណួកន្ទបឱ្យហៀរកែង
ខ្សត់ខ្សោយកុំឱ្យខ្វះសំបែង ខ្ទមឯងដេកស្រួលជាងជួលស្នាក់ ។
-កុំត្រាប់សេដ្ឋីមានពន់ពេក សំបូរអនេកសព្វមាសប្រាក់
ផ្ទះធំមិនដេកខ្លាចប្រឡាក់ ស៊ូអាស្រ័យស្នាក់ក្រោលក្របី ។
-សម្បត្តិហៀរហូរសំបូរណាស់ តែគង់មកខ្វាសអ្នកក្រក្រី
សព្វអម្បែងបែកចោលដោយដី សេដ្ឋីហាខ្វីឥតខ្មាសអៀន ។
-បំណាច់នឹងក្រឱ្យប្រពៃ កុំស៊ូលើកដៃដើរសុំទាន
មានយសកុំរស់ដូចអត់ឃ្លាន ដូនតាទូន្មានជាទម្លាប់ ។
-កូនអើយខិតខំកុំឱ្យខក លោកថាងើយស្កកឱនដាក់គ្រាប់
ទោរទន់ធ្ងន់ធ្ងរទ្រដោយទ្រព្យ ឈរងើតអើតជាប់ដោយសំដី ។

-ឧបម័យនឹងមនុស្សខ្ពស់ខែងវែង អួតអាងខ្លួនឯងប្រជាប្រិយ
ពើងទ្រូងប្ញមាត់បត់អុំដៃ សម្បើមសំដីខ្វះសន្តាន ។
-រីមនុស្សទោរទន់គន់សុភាព កាយចិត្តបន្ទាបរាបសាប្រាណ
ចេះផ្តាប់គោរពគ្រប់សន្តាន ប្រៀបបានឱបធ្ងន់ដោយធនធាន ។
-មនុស្សខ្វះសម្បើមធ្មើមសំបក ដូចស្រូវដែលស្កកអង្ករគ្មាន
ងើបងើយខ្ពស់ពេកឥតខ្មាសអៀន ចាស់លោកនិទានថាគ្មានផល ។
-លោកប្រដូចទៅស្រូវសំដី ប្រៀបជនប្រុសស្រីលើសកល
បួកខ្ពស់ហួសខ្នាតខាតលាភផល ញាតិផងមិនខ្វល់មិនស្និទ្ធស្នេហ៍ ។
-គេខ្ពើមអំណាចខ្លាចអំនួត ក្បិតធ្លាប់តែអួតអាងភ្លូកែ
លុះកាលទល់ច្រកបកមកស្នេហ៍ ទោះខំត្អូញត្អែរគ្មានគេស្និទ្ធ ។
-បើធ្លាប់ឱនទាបសុភាពប្រាណ ញាតិមិត្តរាប់អានចោមចូលចិត្ត
អាសន្នអន់ក្រគេអាណិត ឱនដាក់គ្រាប់ពិតដូចនិទាន ។
-កូនអើយខ្មៅចុះឱ្យតែស បើក្រៗចុះឱ្យតែមាន
ពាក្យពីបូរាណបានប្រាប់ប្រៀន ទូន្មានអោយហ៊ានពិចារណា ។
-ពាក្យខ្មៅហៅផ្ទុយពីពាក្យស អាក្រក់ផ្ទុយល្អពិតពិស្តារ
ខ្មៅចុះឱ្យសបានន័យថា អាក្រក់កាយាឱ្យល្អចិត្ត ។
-ឯពាក្យក្រចុះឱ្យតែមាន ចាស់លោកនិទានងាយរិះគិត
ន័យថាក្រចុះទ្រព្យព្រេងព្រឹទ្ធ តែសូមមានពិតត្រង់កិត្តិយស ។
-មានញាតិសន្តានមានមិត្តល្អ មានចិត្តស្មោះសរមានកេរ្តិ៍ឈ្មោះ
មានប្រាជ្ញាវៃស្តីពីរោះ ប៉ុណ្ណោះទោះក្រក៏គប្បី ។

* * *

(១) ភ្លូ = ភ្លូហាន-កាប់ចាក់

-**ក្មួន** អើយចូរចាំចំណាំទុក ទំនុកពុកផ្ដាំមាសប្រុសស្រី
មនុស្សមានអៀនខ្មាសព្រះប្រណី មនុស្សទ្រុស្ដវិន័យព្រះផ្ដាសា ។
-លោកថាស្លៀកស្បង់មិនកោរសក់ នឹងថ្ពុះកញ្ចក់ធ្វេចនេត្រា
ពាក្យសុភាសិតបណ្ឌិតចារ្យ ចោទជាប្រស្នាឱ្យស្វែងយល់ ។
-ហៃស្ងួននាងអ្នកខេមរបុត្រ គួរគិតហ្មត់ចត់ដល់ឫសគល់
បុរាណព្រឹទ្ធព្រេងថ្លែងពន្យល់ ឱ្យអស់និមលពិចារណា ។
-ពាក្យថាស្លៀកស្បង់មិនកោរសក់ ន័យថាអាក្រក់ហួសធម្មតា
អ្នកស្លៀកពាក់ស្បង់ផ្ទង់ធម៌អាថ៌ នោះម្ដងកេសាលោកជំរុះ ។
-បើគ្រងស្បង់ហើយមិនកោរសក់ តាមន័យជាតកថាអមនុស្ស
ពិតជាបុគ្គលយល់ផ្លូវខុស នោះគឺប្រទុស្តច្បាប់វិន័យ ។
-ប្រដូចទៅនឹងពាលអបលក្ខណ៍ សេពសាងគ្រោះថ្នាក់ទោសអប្រិយ៍
បន្ទំក្លែងក្លាយកាយប្រពៃ វិស័យខ្វាព្រៃលាក់គ្រចក ។
-ខាងក្នុងអសោចដូចផ្លែល្វា ល្អគន់គាប់ជាតែសំបក
បើនឹងប្រតិព័ទ្ធប្រាកដខក ប្រៀបសត្វចចកចិត្តមិនគាប់ ។
-ដូចកាលសម័យប្រល័យសាសន៍ អ្នកផងក្មេងចាស់នៅចាំជាប់
ដំបូងនឹកស្មានថាមានភ័ព្វ គោរពបង្គាប់ម៉ែឪថ្មី ។
-ឱនកាយបន្ទាបក្រាបសំពះ នឹកថាគេជះលោកប្រពៃ
ព្បិតលោកជួយជាតិជួយទឹកដី រំដោះគ្រោះភ័យឱ្យប្រជា ។
-លោករៀបចំច្បាប់ប្លែកអស្ចារ្យ មិត្តយាយមិត្តតាមិត្តមីងមា
រៀនអត់រៀនឃ្លានរៀនវេទនា រៀនគ្រប់ការងាររៀនកុំធី ។
-រៀនទ្រាំនៀយហាត់ឥតឈប់ឈរ រៀនធ្វើថ្លង់គរៀនកុំស្ដី
រៀនឈឺចុកចាប់រៀនខន្តី រៀនដេកផ្ទាល់ដីដូចសុនខ ។

-នោះហើយសត្វក្អែកពាក់ស្បែកហង្ស ប្រៀបមនុស្សស្លៀកស្បង់មិនកោរសក់
សាបព្រោះឧក្រិដ្ឋចិត្តអាក្រក់ បោកប្រាស់កុហកដល់ញាតិផង ។
-ចិត្តជាទេវទត្តមាត់ទេវតា ទន្ទេញសាម្នាកាន់ដំបង
អំពើទុច្ចរិតលាក់ក្រោយខ្នង ខាងមុខនោះផងត្រងសីលទាន ។
-ប្រព្រឹត្តបាបកម្មឥតគិតក្រែង តែខ្លាចគេថ្លែងថាជាព្រាន
នឹងផ្ទះកញ្ចក់ទឹកខ្វាសអៀន ម៉្លោះហើយមិនហ៊ានបើកនេត្រា ។
-ថ្នោះហើយស្លៀកស្បង់មិនកោរសក់ គឺជនអាក្រក់ប្រែកាឡា
ប្រឹងផ្ទះកញ្ចក់ធ្មេចនេត្រា បិទបាំងអាត្មាខ្មៅងងឹត ។
-មនុស្សលោកគគោកច្រើនកុះករ មានអាក្រក់ល្អច្រើនពេកពិត
ថ្នោះហើយកូនអើយចូរពិនិត្យ មុនស្ម័គ្រស្នេហ៍ស្និទ្ធគិតកុំឃ្លាត ។
-កូនអើយឈើកោងវល្លិរុំព័ទ្ធ រីមនុស្សខ្វាត់ភ្វាត់កុំឱ្យបៀត
ខិតខំចំណាំកុំបីឃ្លាត ត្បិតជាឱវាទល្អប្រពៃ ។
-ធម្មតាឈើកោងវល្លិតោងព័ទ្ធ នោះពិតប្រាកដខ្វះតម្លៃ
ឈើនោះសឹងហួសនឹងកែច្នៃ ទោះប្រើប្រាស់ក្តីខ្វះប្រយោជន៍ ។
-ប្រៀបមនុស្សរសាត់ហៅខ្វាត់ភ្វាត់ បើនឹងប្រតិព័ទ្ធក្រែងមិនខ្មោច
ប៉ះពានជនពាលពិតអសោច ម៉្លេះសមហិនហោចបង់អាសា ។
-អ្នកខ្វះសាងទានសន្សំបុណ្យ ជួយទុរគតជនឆ្លងទុក្ខា
បំផុតធ្វើគុណបានទោសា ត្រូវពាលឫស្យាផ្តល់នូវទុក្ខ ។
-នោះឯងឈើកោងដែលវល្លិព័ទ្ធ ដូចមនុស្សខ្វាត់ភ្វាត់លាក់មាត់មុខ
ទូលកញ្ចើរដើរចោលភូមិស្រុក ត្បិតនៅមិនសុខព្រោះរឿងក្តី ។
-បានជួបអ្នកល្អអង្វរសុំ ស៊ីឈ្នួលធ្វើខ្ញុំសុំបាយធី
លុះបានក្សាន្តចិត្តផុតទុក្ខភ័យ ពាលពុតអប្រិយ៍មិនលះបង់ ។

ដូច្នេះត្រិះរិះពិចារណា មុនស្និទ្ធស្នេហាគិតផ្ចិតផ្ចង់
កុំឃើញឈើកោងប៉ងតម្រង់ ក្រែងប្រាក់ក៏បង់ថង់ក៏ដាច ។
ធម្មតាខ្លាក្រាបដូចសំពះ កុំល្បងប៉ងឈ្នះធ្វើអង់អាច
អុងអាត់បង្ហាត់ឱ្យខ្លាខ្លាច កុំភ្លេចខ្លាកាចស៊ីសាច់ស្រស់ ។
កុំរាប់ក្រពើធ្វើមិត្តល្អ កុំលេងល្ងកលកាន់កពស់
ទន្សាយវៃឆ្លាតគង់ខាតយស សព្វខ្យងតូចងោះគង់ឈ្នះក្តី ។
កុំយកជ័រព្នៅទៅត្បៀតក្បៀក នេះជាពេចន៍ពាក្យបុរាណស្តី
ធ្វើទានត្រូវហ៊ានរលាស់ដៃ កុំឱ្យបុលខ្ចីជាប់ជំពាក់ ។
ពូជបញ្ញើរក្អែកមិនប្លែកទេ ផ្ញើកាយនឹងគេអាស្រ័យស្នាក់
ដំបូងសុំរស់ផុតគ្រោះថ្នាក់ ក្រោយមកត្រចាក់សម្លាប់ម្ចាស់ ។
កូនអើយប្រយ័ត្នមុនប្រតិព័ទ្ធ មនុស្សដែលខ្វាត់ភ្វាត់ស្គាល់មិនច្បាស់
កុំចាប់ទុកចិត្តស្និទ្ធរហ័ស ក្រែងពានទៅប៉ះពាលមានពុត ។
នោះនឹងគ្រោះថ្នាក់ដាក់ដល់ប្រាណ នាំក្តីវិនាសព្រួយរន្ធត់
រលាយសម្បត្តិទ្រព្យរលត់ ព្បិតពាលទុរគតចិត្តសាមាន្យ ។
នោះឯងសាងបុណ្យខុសបន្ទាត់ លើមនុស្សខ្វាត់ភ្វាត់វង្វេងឋាន
បំផុតនាំទុក្ខទោសដល់ប្រាណ ន័យនេះបុរាណបានប្រដៅ ។

* * *

**ម្យ៉ាង**ទៀតអ្នកមានរក្សាខ្សត់ នោះដូចសំពត់ព័ទ្ធពីក្រៅ
រីឯអ្នកប្រាជ្ញរក្សាខ្លៅ នោះដូចសំពៅនូវសំប៉ាន ។
ពាក្យថាអ្នកមានរក្សាខ្សត់ ន័យលោកសន្មតឱ្យស្តាប់បាន
អ្នកមានពឹងក្រកំដរប្រាណ សន្សំសុខសាន្តបានយប់ថ្ងៃ ។

-ជាអ្នកការពារជាជំនួយ　　បិទបាំងភ័យព្រួយជួយកែច្នៃ
ជាភ្នែកត្រចៀកប្រសើរក្រៃ　　ជំនួសជើងដៃសព្វកិច្ចការ ។
-នោះប្រៀបសំពត់ព័ទ្ធពីក្រៅ　　រាំងកាយកក់ក្ដៅប្រាណហ៊ុំហា
អ្នកមានគាប់យសខ្ពស់ថ្លៃថ្លា　　អាស្រ័យដោយសាររក្សាខ្សត់ ។
-ឯន័យមួយទៀតធៀតនិទាន　　ចំពោះអ្នកមានពិតប្រាកដ
រមែងភ័យខ្លាចភាពក្រខ្សត់　　នោះហើយសន្មតរក្សាក្រ ។
-ដូច្នេះអ្នកមានរក្សាខ្សត់　　ឪពុកលើកបទឧទាហរណ៍
តាមពាក្យដូនតាថាបន្ត　　ផ្ដាំមាសបវរជាតម្រា ។
-រីឯអ្នកប្រាជ្ញរក្សាខ្លៅ　　ព្រេងព្រឹទ្ធប្រដៅពិតុពិស្ដារ
អ្នកប្រាជ្ញល្បីឈ្មោះខ្ពស់បញ្ញា　　នោះព្រោះឧស្សាហ៍ចែកចំណេះ ។
-ប្រសិនអ្នកប្រាជ្ញស្អប់អ្នកខ្លៅ　　មិនជួយប្រដៅផ្ដល់ឱ្យចេះ
វិជ្ជាដូចខ្ទប់កប់តំរេះ　　ថ្ងៃមុខចំណេះម៉េះបាត់បង់ ។
-ថ្មោះហើយអ្នកប្រាជ្ញរក្សាខ្លៅ　　ព្យាយាមប្រដៅប្រៀនតម្រង់
ប្រយោជន៍កេរ្តិ៍ឈ្មោះមិនបាត់បង់　　ត្រចះត្រចង់សព្វទីស្ថាន ។
-ច្នេះហើយកូនអើយលោកតម្រូវ　　ប្រៀបដូចសំពៅនូវសំប៉ាន
ពាក្យពេចន៍លេចពិតពីបូរាណ　　សំប៉ានប្រៀបបានកូននាវា ។
-ទោះនឹងសំពៅទៅទីណា　　សំប៉ានយាត្រាជាមួយគ្នា
សំពៅខូចខកលើជលធា　　អាចឆ្លងគ្រោះគ្រាដោយសំប៉ាន ។
-ន័យនេះដូនតាលោកចងក្រង　　ងាយយល់កន្លងមិនព្រួយស្មាន
ប្រៀបធៀបគង់ជ្រាបដល់ដើមដាន　　ចូរស្ងួនគ្រប់ប្រាណចាំឃ្លោងឃ្លា ។
-សរុបដោយខ្លីន័យតែមួយ　　លោកឱ្យលើកស្ទួយជួយគ្នីគ្នា
ធ្វើអ្វីម្នាក់ឯងក្រែងមិនជា　　ចាំបាច់រួមគ្នាទើបមាំមួន ។

-លោកថាអ្នកចេះរបេះក្បាច់ នោះព្រោះសំរេចខុសច្បាប់ក្បួន
កុំគិតឯកោគ្រដល់ខ្លួន សម្ងំលាក់ពួនខាតប្រយោជន៍ ។
-កុំលាក់គំនូចក្ងួចកំណាញ់ កុំអាងតែអញវាមិនខ្វោច
ចាស់ថាខ្លាំងពេកអាចនឹងខ្វោច នោះនាំហិនហោចខូចកិច្ចការ ។
-កូនអើយបូរាណបានពោលច្បាស់ ធ្វើស្រែកុំស្រះព័ទ្ធបន្ទា
ចូលព្រៃហ៊ានអារសាច់ឱ្យខ្លា នោះទើបអាត្មាផុតអំពល់ ។

* * *

## "ចង់ចេះឱ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឱ្យយកភ្លើងដុតគល់"
## (បទពាក្យ៧)

-ចង់ចេះឱ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឱ្យដុតគល់
ពាក្យចាស់បូរាណបានពន្យល់ ឱ្យស្ងួនមិនមលពិចារណា ។
-ម្តេចឡើយចាស់លោកពោលដូច្នេះ ចង់ចេះឱ្យសម្លាប់អាចារ្យ
រីឯបើចង់បានផ្លែផ្កា សន្យាយកភ្លើងដុតគល់វិញ ? ។
-កូនអើយនោះហើយសុភាសិត លោកឱ្យរិះគិតកុំទោម្ទេញ
ន័យនេះប្រៀបធៀបទើបចំណេញ នោះពិតពោរពេញដោយខ្លឹមសារ ។
-ឧទាទបំភ្លឺគឺគ្រូម្នាក់ នោះពិតបញ្ជាក់ជាអាចារ្យ
បូរាណលោកហៅថាគ្រូបា នោះហើយអាចារ្យថាមិនស្មាន ។
-បើយើងចង់ចេះត្រូវសម្លាប់ ពុំមែនចាក់កាប់ឱ្យស្លាប់ប្រាណ
សម្លាប់អាចារ្យលោកប្រមាណ គឺសម្លាប់បាននូវចិត្តលោក ។

-នោះគ្រូកោងកាចចិត្តកំណាញ់ កូនកុំស្អប់ខ្នាញ់ត្រូវខិនឈ្លោក
ព្យាយាមកៀកកិតថ្នមចិត្តលោក ចំណេះគគោកលោកមិនលាក់ ។
-ចេះផ្គាប់រាប់រកលោកអាណិត តំរេះលោកពិតលែងព័ន្ធពាក់
បូជាឱ្យមកលោកមិនលាក់ នោះហើយបញ្ជាក់ថាសម្លាប់ ។
-ឯន័យម្យ៉ាងទៀតធ្មៀតសំគាល់ គឺខ្លួនយើងផ្ទាល់ចូរត្រងត្រាប់
អាចារ្យដែលយើងត្រូវសម្លាប់ របីស្គីតាមច្បាប់ថាមានបី ។
-ទិដ្ឋិ មានះ និងតណ្ហា នោះជាប្រការធំប្រពៃ
សម្លាប់អាចារ្យនោះទាំងបី កុំឱ្យរស់អីនាំរំខាន ។
-ន័យនេះរិះគិតពិតនឹងយល់ ត្បិតជាពិសពុលឋិតជាប់ប្រាណ
បើយើងសម្លាប់ឱ្យស្លាប់បាន នោះនឹងនាំប្រាណឱ្យយល់ដឹង ។
-ដូច្នេះចូរស្ងួនឱនកាយចិត្ត បើចង់ចេះពិតត្រូវប្រឹតប្រឹង
កំចាត់ទិដ្ឋិមានះរឹង បំផ្លាញឱ្យឈឹងទាំងតណ្ហា ។
-នោះហើយលោកថាអាចារ្យបី ជាអរូបីយ៍ជាប់អាត្មា
បើសម្លាប់បានប្រាណថ្លៃថ្លា ទើបនឹងសិក្សាចេះចាំធាប់ ។

-**ឯឃ្លា**មួយទៀតនិទានថា ចង់បានផ្លែផ្កាឱ្យប្រញាប់
យកភ្លើងដុតគល់ទើបចំណាប់ កូនអើយចូរស្តាប់ហើយគិតក្រែង ។
-ពាក្យថាយកភ្លើងទៅដុតគល់ នោះគឺឈ្នួសឈ្នួលខំប្រឹងប្រែង
គល់គឺកំណើតពិតជាក់ស្តែង លោកឱ្យខ្នះខ្នែងស្វែងខាងដើម ។
-ប្រៀបនឹងដំណាំសព្វសារពើ មុនដាំត្រូវធ្វើឱ្យបានធ្មើម
ដាស់ដីផ្សំជីជាដង្ហើម នោះទើបដងដើមធាប់ល្អបាន ។

ប្រឹងកាប់គាស់កាយខំខ្វាយខ្វល់ បំប៉នឫសគល់ថែប្រមាណ
នោះពិតផ្លែផ្កាភោគផលបាន ន័យនេះមិនស្មានជាការពិត ។
ដូច្នេះពាក្យថាឱ្យដុតគល់ លោកពិតពន្យល់ឱ្យកូនគិត
មុនបាប់ភោគផលនៃជីវិត ខំរៀនរិះគិតកុំទំរន់ ។
ដុតដៃដុតជើងយើងស្ទុះស្ទា ប្រយុទ្ធការងារពិតពេកពន់
ព្យាយាមអំណត់ទ្រាំអត់ធន ថ្ងៃមុខគាប់គន់ដោយផ្លែផ្កា ។
កូនអើយចូរចាំពាក្យចងក្រង ឪពុកសាកល្បងស្រាយប្រស្នា
ធម្មតាភាសិតលោកចងចារ ន័យច្រើនប្រការប្លែកៗគ្នា ។
នេះពុកវែកញែកតែមួយផ្លូវ ប្រៀបធៀបតម្រូវតាមឃ្លោងឃ្លា
ពន្យល់ដល់កូនស្ងួនពុំងា គេងគិតគ្រប់គ្នាណានិមល ។
ចង់ចេះត្រូវសម្លាប់អាចារ្យ ចង់បានផ្លែផ្កាត្រូវដុតគល់
ច្នេះការប្រឹងប្រែងស្វែងឈ្មុសឈ្មុល រមែងបានយល់ផលទ្រព្យា ។

* * *

កុំកាប់បំពង់រង់ចាំភ្លៀង ពាក្យពេចន៍សំនៀងលោកចងឃ្លា
លោកផ្តាំប្រដៅរាល់វេលា ឱ្យពិចារណាផ្លូវជីវិត ។
កុំដេករង់ចាំព្រេងវាសនា កុំចោលកិច្ចការពឹងលាភពិត
កុំធោតវង្វេងវង្វេងគំនិត ចោលការមកគិតផ្សងសំណាង ។
កុំពួផ្គរលាន់រួសរាន់អរ ចាក់ចោលឈូរធទឹកក្នុងអាង
ចាំត្រងទឹកថ្មីដាក់ចោតពាង គ្រោះកាចគ្រាប់ភ្លៀងរាំងមិនធ្លាក់ ។

-នោះឯងរមែងខូចប្រយោជន៍ ទ្រព្យផងហិនហោចព្រោះជឿជាក់
ផ្គរភ្លៀងមិនទៀងទេនាងអ្នក ពាក្យពុកបញ្ជាក់មិនលាក់ភរ ។
-យើងធ្វើស្រែច្បារប្រាថ្នាទឹក កុំសង្ឃឹមទឹកពឹងភ្លៀងផ្គរ
ការពាររាំងជល់កុំឈប់ឈរ ទើបផលកើនគរជាក់ជាបាន ។
-កុំទីពឹងមេឃក្រែងខាតខក ស្រូវស្រែបែរស្អកនាំរំខាន
មានវិធានការទើបថាថ្កាន កុំខឹងជើងក្រានបើបាយឆៅ ។
-ធ្វើស្រែនឹងទឹកសឹកនឹងស្បៀង ពាក្យពីរបីព្យាង្គលោកប្រដៅ
ផ្សងព្រេងប្រវាស់ច្បាស់ជាខ្លៅ ក្រែងពូជមួយតៅនៅមួយក្តាប់ ។
-កូនអើយកុំផ្ញើកអំរែកគេ កុំស្ងៀមទំនេរចាំផលស្រាប់
កុំបានគេជួយលែងព្រួយយ៉ាប់ រីករាយចំណាប់ភ្លេចកិច្ចការ ។
-ជួនជាថ្ងៃក្រោយគេមិនគាប់ ចាយវាយអស់ទ្រព្យទើបឆ្ងេឆ្ងា
បន្ទោសថាព្រោះព្រេងវាសនា ខ្វះក្តីមេត្តាដល់ជីវិត ។
-នោះឯងប្រៀបបាននឹងភ្លៀងផ្គរ មិនអាចនឹងនទេវមិត្ត
ខ្លួនត្រូវពឹងខ្លួនស្ងួនគួរគិត នោះទើបជីវិតមានរស្មី ។

* * *

-**លោកថា**បើដុតៗឱ្យខ្លោច នោះជាប្រយោជន៍ល្អប្រពៃ
បញ្ជាក់ថាអ្នកនឹងធ្វើអ្វី លូកឱ្យកប់ដៃចូលឱ្យជ្រៅ ។
-ឧបម័យបំណងប៉ងប្រាថ្នា បង្កើតផល្វាច្បារស្រែស្រូវ
តោងប្រឹងឈ្មុសឈ្មុលរុលឱ្យជ្រៅ ទោះត្រជាក់ក្តៅត្រូវពុះពារ ។

ចង់បានជាប្រាជ្ញជាបណ្ឌិត    គប្បីរិះគិតស្វែងវិជ្ជា
ចេះចាំធ្មិនខ្ជោចច្បាប់នានា    នោះទើបក្លាយងារជាអ្នកចេះ ។

ប្រៀបបានពិសោធសព្វដំណាំ    អាស្រ័យសកម្មទើបបានបេះ
ដាំចោលមិនខ្វល់ផលមិនផេះ    ដើមស្វិតផ្លែក្រេះត្បិតស្មើរភ្លើង ។

នោះហើយន័យថាផុតឱ្យខ្ជោច    លោកផ្តាំប៉ប៉ោចចំពោះយើង
ការប្រឹងស្ទុះស្ទានោះជាភ្លើង    ឃ្លានេះគួរយើងគិតរំពៃ ។

ម្យ៉ាងទៀតពុកធ្លៀតប្រៀបប្រដូច    ពាក្យថាផុតខ្ជោចគឺសំដី
បំណាច់ចោទឆ្លើយចម្លើយក្តី    គប្បីស្រដីឱ្យម៉ឺងម៉ាត់ ។

ពោលពាក្យហ្មត់ចត់សង្កត់ច្បាស់    ហេតុផលឱ្យណាស់ចូរប្រយ័ត្ន
បើផុតមិនខ្ជោចអសោចក្តាត់    ម៉្លេះបង់សម្បត្តិត្បិតភ្លើងស្មើរ ។

នេះន័យអត្ថបដិរូប    កូនអើយគង់ជួបដោយអន្ទើ
ពាក្យផុតឱ្យខ្ជោចជាទង្វើ    អ្វីសព្វសារពើធ្វើឱ្យណាស់ ។

ម្យ៉ាងទៀតលោកថារោចឱ្យឆៅ    ពាក្យពោលប្រដៅភ្ញីស្រឡះ
លោកផ្តាំកូនចៅទាំងក្មេងចាស់    ឱ្យយល់ជាក់ច្បាស់លើអត្ថន័យ ។

កូនអើយបើរោចៗឱ្យឆៅ    លោកបំភ្លឺផ្លូវស្នូនប្រុសស្រី
ដកខ្លួនឱ្យឆ្ងាយភាពអប្រិយ៍    កុំចូលជិតអីថ្ងៃព្រលឹង ។

ឧទាហរណ៍ខ្ទីស្តីពីចោរ    ក្រខ្វះអាវខោតែវាប្រឹង
លបលួចធរធក់ភ្នែកស្លក់ស្លឹង    ភំព្វល្អក្រមឹងក្លាយជាមាន ។

របរនោះឯងផ្សងព្រេងស្លាប់    ជូនភ្លាត់ចំណាប់អន្តរធាន
ប្រព្រឹត្តទុច្ចរិតចិត្តបំពាន    តើគួរស្ទូត្ររៀនឬគួរកុំ ? ។

របរឥតដើមកុំប្រថុយ    ក្រែងរាសីស្ពុយវាស៊ិយធំ
បើត្រាប់តាមច្បាប់លោកថាកុំ    នាំទុក្ខទោសធំដល់ជីវិត ។

-កូនអើយនោះហើយរោចឱ្យចៅ ពុកផ្ដាំប្រដៅមិនត្រូវស្និទ្ធ
ល្ងង់នឹងខិលខូចញាតិអាណិត ចៅនឹងទុច្ចរិតពិតល្អកាយ ។
-ពាក្យរោចប្រដូចថាផកចេញ រីពាក្យផុតវិញខំខ្វល់ខ្វាយ
ដូច្នោះចៅចុះព្រោះអបាយ បើកាប់គាស់កាយឱ្យខ្មោចចុះ ។
-ចូរចាំជានិច្ចកុំភ្លេចឡើយ ពាក្យចាស់ផ្ដាំហើយមិនសូវខុស
ប្រៀបបានប្រទីបបំភ្លឺផ្ទះ ប្រាប់ផ្លូវត្រូវខុសដល់ពុំងា ។

* * *

# "ចេះពីរៀន មានពីរក"

(បទពាក្យ៧)

-ចេះមកពីរៀនមានពីរក ហៃស្ងួនពន្លកគ្រប់អង្គា
ពាក្យចាស់ពន្យល់រាល់វេលា ឱ្យកូនគ្រប់គ្នាចងចាំទុក ។
-លោកថាចំណេះបានពីរៀន នេះជំបូន្មានចំពោះមុខ
ចំណេះជួយឆ្លងចម្លងទុក្ខ ចូរចាំទំនុកលោកស្រដី ។
-វិជ្ជាគឺជាឃ្លាំងសម្បត្តិ ចាយមិនចេះខ្វាត់ទេពិសី
ចោរលួចមិនបាត់ទោះយប់ថ្ងៃ ចរណៃចំណាំគឺវិជ្ជា ។
-ចំណេះអាចស្គាល់ពន្យល់ផ្លូវ ស្គាល់ហេតុខុសត្រូវសព្វការងារ
បើមានចន្ទះខ្វះវិជ្ជា ធ្វើអ្វីនានាច្រើនសៅហ្មង ។
-អវិជ្ជាងងឹតពិតដូចខ្វាក់ យល់ក្ដីគ្រោះថ្នាក់ច្រើនកន្លង
សូន្យសុងលង់លិចភ្លេចផ្ដាំផ្ដង សឹងសោកគប់ផងដោយបាបកម្ម ។

ពាក្យពីបូរាណចាន់ចងចារ ដំណាំជូនតាជាបណ្ដាំ
ហៃមាសស្ងួនអើយចូរកូនចាំ លោកផ្ដាំភ្លើងភ្លឺគិប្រាជ្ញា ។
កកើតចំណេះគិតខិតខំ សន្សំសង្វាតធ្លាតសិក្សា
ប្រមូលតក់ៗឆក់តម្រា មានលេខអក្ខរាជាប្រភព ។
ចេះចាំកាលណាភ្លឺកាលនោះ នាំខ្លួនផុតគ្រោះលែងធុញថប់
ភ្លឺអចិន្ត្រៃយ៍ទាំងថ្ងៃយប់ ឧបសគ្គសព្វគ្រប់ឈប់អំពល់ ។
ពុកពោលរួចហើយឃ្លាមួយថា ចង់បានផ្លែផ្កាឱ្យដុតគល់
កូនអើយប្រឹងរៀនហ៊ានឈ្នះឈ្នួល ថ្ងៃមុខគង់យល់ដោយសម្បត្តិ ។
កំណប់មាសប្រាក់គឺសាលា ត្រូវកាយកាប់ធ្លាកុំស្ទៀមស្ងាត់
កូនចេះចាំហើយស្បើយវិបត្តិ ទុកព្រួយខ្វាយខ្វាត់ពីអាត្មា ។

**ក** អ៊ើយកកើតជារូបកាយ កូនកុំកាត់ឆ្ងាយពីកិច្ចការ
កាប់គាស់កុះកររល្អកាយា កេរកាលផ្ដាំថាកុំកោងកាច ។

**ខ** អ៊ើយខខំកុំខ្វះខិល ខកខានប្រាណខ្ជិលរិលទាល់ប្រាជ្ញ
ខែងរែងក្រែងខុសឈ្មោះខូចកាច ខិតខំខ្លបខ្លាចអាចសុខា ។

**គ** អ៊ើយគគួរចេះគិតគួរ ចេះគាប់គុណគ្រូកុំគេចចា
កុំកួចគុំកួនកាន់មោហា គេងគិតកិច្ចការគង់គប្បី ។

**ឃ** អ៊ើយឃឃើញភាពឃោរឃៅ កុំទៅឃុបឃិតជិតគេអី
ជួយឃាត់មនុស្សឃាតឱ្យឃ្លាតភ័យ កើតក្ដីឃុំឃាំងទាំងអ្នកជួយ ។

ង អ៊ើយងងឹតពិតដូចងោះ	ងប់ងុលជ្រុលជ្រួសព្រោះខ្វះព្រួយ
ងីងើងំៗយំរងួយ	ងើបងើយផុតត្រួយឆ្ងោយការងារ ។

ច អ៊ើយចចាប់ចេះចាត់ចែង	ចាស់ៗលោកថ្លែងថាចិត្តជា
ចូលចិត្តចោទស្រាយចែកចាយគ្នា	ចាំចុះអ្នកជាចេះចចារ ។

ឆ អ៊ើយឆឆោមកុំឆើតឆាយ	ឆុងឆាំងនាំកាយក្លាយប្រេះឆា
ឆិនឆៃដៃឆៅឆាប់ឈឺផ្សា	កុំឆោតអាត្មាឆាបឆួលឆេះ ។

ជ អ៊ើយជជួបជោគជយា	ជនជាតិអ្នកជាល្អពិសេស
មិនជេរជជែកស្រែកចចេស	ជួយជាតិប្រទេសមិនជិះជាន់ ។

ឈ អ៊ើយឈឈានឱយលឿនឆាប់	ឈួចរប្រញាប់ឈោងឱយទាន់
កុំឈៀងឈរឈប់ចង់ទប់ឈ្នាន់	ខំប្រឹងរួសរាន់ទាន់ឈឺចាប់ ។

ញ អ៊ើយញញឹមកុំញញើត	កុំញាក់ញ័រព្រើតប្រឹងប្រញាប់
ញុះញង់ញឹកញាប់គាប់កុំត្រាប់	ញ៉េះញ៉ោះខុសច្បាប់នាំញាតិស្អប់ ។

ដ អ៊ើយដដឹងដល់ដើមដាន	ដេកដើរប្រមាណដានប្រសព្វ
ដាំដុះដេរដាស់អស់ធុញថប់	ដូចដឹងដល់ដប់ឈប់ដុនដាប ។

ឋ អ៊ើយឋឋិតក្នុងឋានសុខ	បឋមស្តម្ភស្តុករៀងដរាប
ឋានៈខ្ពង់ខ្ពស់ព្រោះគ្មានបាប	សាងបុណ្យឱនក្រាបជួបសួគ៌ឋាន ។

ឱអើយឱឱញប្រឱត ដៀមដាមញាតិមិត្តពិតរំខាន
ឱកដានឱដងសៅហ្មងប្រាណ ដៀលខុសដើមដានគេផ្គន្ទា ។

ឲអើយលធំជួបជុំញាតិ ឡែនភាពភាពជាតិឃ្លាតវេរា
ចាកផុតទុក្ខទោសព្យុះព្យាមា ឆ្លងកាលវឡែនាអភិវឡែន៍ ។

ឳអើយណាណាស់ប៉ះអ្នកណា ដំណាងជូនតាចារទៀងទាត់
ដំណឹងដំណតប្រវត្តិ ដំណើរធំធាត់ដំណែលកេរ្តិ៍ ។

ឥអើយតតូចនៅតេះតះ តោងតាមតាចាស់ណាមាសមេ
តូចតាចកុំតាំងខ្លាំងជាងគេ តក់ៗគង់តែតាមគេទាន់ ។

ថអើយថថាឱ្យថែថូន ថោកដៃថ្លៃខ្លួនលោកថាគ្រាន់
ថែកេរ្តិ៍ថេរថិតគិតគ្នេរគ្នាន់ កុំថប់ធុញទ្រាន់ថេះថែមថយ ។

ទអើយទទៅឱ្យទៀងទាត់ ទន្ទេញចាំមាត់ទើបមិនស៊យ
ទិសទីទើសទាល់កុំទៅញយ ទាស់ទែងនាំឱ្យទុក្ខទោសា ។

ធអើយធធនធានធូរធារ ធំធាត់សោភាសមប្រាថ្នា
សន្ទឹកសន្ទាប់គាប់ចិន្តា សន្សំធម៌អាថ៌កុំធុញថប់ ។

នអើយនគាងកុំទំនេរ  និក្សនៅរិះរេវៀនឱ្យចប់
នោះទើបនឹមនូនមានកំណប់  ន័យនេះជាទ្រព្យណានួនភ្ញា ។

បអើយបពោះបងឱ្យបាន  បែបបទសាមាន្យធ្វើបាបគ្នា
កុំបែកបែរបុណ្យគុណបុព្វជា  បីបមបុត្រភ្ញាជាប្រចាំ ។

ផអើយផផុសផុះផល្លា  បំផុតផ្លែផ្កាព្រោះប្រឹងផាំ
ភោគផលផ្លូវផង់ផ្ចង់ផ្សែផ្សាំ  ផ្គងផាងពឹកញាំផលមិនផេះ ។

ពអើយពពោលពាក្យឱ្យពិត  ដូចពេជ្រប្រណីតពេញពិសេស
កុំពានពូកពាលពុតមិនខ្មេះ  ពាក់ព័ន្ធពូកនេះខូចពូជពង្ស ។

ភអើយភវភូតនាំអភ័ព្វ  ភាន់ភាំងបង់ទ្រព្យមិនគាប់គង់
ភិតភ័យភោគផលផ្តល់លិចលង់  ពិភពល្បិតល្បង់កុំសុំភី ។

មអើយមមានមិត្តចិត្តមួយ  មាំមួនមិនព្រួយមួយជីវី
មាសមេមើលមុខមុនមានពីរ  មោះមុតមូលមីរឱ្យម៉ឺងម៉ាត់ ។

យអើយយយានស្ពានយិតយោង  យាងយាត្រកុំឃ្លោងយើងប្រយ័ត្ន
ប្រយោជន៍យឺនយូរគួរយាមស្កាត់  ប្រយែងប្រយ័ត្នយល់គ្រប់យ៉ាង ។

រអើយររស់រត់រករៀន  រិះរេរាប់អានញាតិជិតខាង
រូតរះរួសរាន់ទាន់សំណាង  រឹងរូសរ៉ូងរ៉ាងរែងរិចរិល ។

ឈ អើយលលេងកុំលីលា　　លូកលាន់ចោបៀវខូចខិល
លោកលន់លួចលាក់ធ្លាក់មន្ទិល　　លិចលង់ខូចខិលគួរលះលែង ។

វ អើយវាងវៀងវិបត្តិ　　វៀចវេរប្រយ័ត្នគេវាស់វែង
វានឹងវិលវល់យល់ទាស់ទែង　　វឹកវរវង្វេងគេវាត់វិញ ។

ស អើយសសួនសូនសុខសាន្ត　　ញាតិសរសើរប្រាណសាយសព្វពេញ
សន្សំសិក្សាសូត្រទន្ទេញ　　សោកសៅទោម្នេញសឹងសូន្យសោះ ។

ហ អើយហហាត់ឱ្យហាំហួន　　ហើយហាមមាសសួនកុំហើរហោះ
ហួងហែងហួសហេតុអសុរស　　ហិនហោចរបស់អស់ហ៊ុហា ។

ឡ អើយឡឡើងកុំឡប់ឡែ　　ឡេះឡោះចែប្រែឡកឡូឡា
ឡឹកឡក់ឡេឡឹមិនធ្វើការ　　លោកថាឡប់ឡិនមិនល្អឡើយ ។

អ អើយអអោបចិត្តអង់អាច　　កុំអាងអំណាចឥតគោះត្រើយ
អែបអបអញឯងក្រែងមិនស៊ើយ　　កុំអួតអ្នកអើយចេះឱនអត់ ។

សាមសិបបីតួនេះឯងហើយ　　មាសសួនកូនអើយលោកកំណត់
ប្រៀបបានប្រទីបពិតប្រាកដ　　ភ្លឺច្បាស់បំផុតទាំងយប់ថ្ងៃ ។
កូនអើយខំរៀនឱ្យសកម្ម　　រៀនផ្សំផ្សែផ្សាំពិសោធថ្លៃ
រៀនបូកគុណគួររៀនយប់ថ្ងៃ　　រៀនកុំសំចៃរៀនធ្វើការ ។

-រៀនបណ្ដុះដាំផំណាំគ្រប់ រៀនកុំធុញថប់គ្រប់សញ្ញា
រៀនលីសែងរែកបែកប្រាជ្ញា រៀនសព្វស្រែច្បាររៀនសាងសង់ ។
-រៀនគូរចាំងឆ្លាក់វិចិត្រករ រៀនត្រាច់បើកបររៀនផ្ចិតផ្ចង់
រៀនសាងសីលទានរៀនស្មោះត្រង់ រៀនបំបាត់បង់នូវបាបកម្ម ។
-រៀនសរសេរស័ព្ទចាប់ចុងចួន រៀនហាត់ពត់ខ្លួនជាប្រចាំ
រៀនសព្វកីឡាកាយវប្បកម្ម រៀនតស៊ូទ្រាំរៀនរកស៊ី ។
-រៀនហើយរៀនទៀតរៀនសព្វមុខ រៀនរកទំនុករៀនសំភី
រៀនរៀបរៀនរាប់គ្រប់នាទី រៀនរួមសាមគ្គីរៀនសុចរិត ។
-រៀនហើយគង់ចេះតម្រេះបាន រៀនចប់កល្យាណបានផលពិត
ចេះចាំជាថ្នាំដ៏ស័ក្តិសិទ្ធ ចាស់ៗចូលចិត្តអ្នកចេះការ ។
-ចេះបានជាប្រាជ្ញជាបណ្ឌិត ចេះបានជាព្រឹទ្ធជាគ្រូបា
ចេះដេកដើរស្តីពិចារណា ចេះនាំអាត្មាយល់ផ្លូវល្អ ។
-ចេះជួសចេះជុលចេះធ្វើជាង ចេះភ្លេងចេះច្រៀងសិល្បករ
ចេះច្បាប់វិន័យចេះសីលធម៌ ចេះសព្វអក្សរគ្រប់ភាសា ។
-កូនអើយឪពុកទុកបណ្ដាំ ចូរស្ដួនចំណាំរាល់វូបា
កុំរៀនវិជ្ជាក្រៅតម្រា ជាអាទិស្រីស្រាល្បែងអបាយ ។
-កុំរៀនធ្វើចោរចេះលួចឆក់ ចេះភរកុហកបោកប្រាស់ប្រាយ
ចេះហ៊ុហាហួសឈ្មោះអន្តរាយ ពុកផ្ដាំធោមធាយកុំឱ្យរៀន ។
-កូនអើយចំណេះពិសេសផុត នោះគឺប្រាកដចេះខ្មាសអៀន
សូវខ្វះសម្បត្តិទ្រព្យធនធាន តែត្រង់ខ្មាសអៀនកុំខ្វះអី ។

* * *

ឯឃ្លាមួយទៀតគួរនឹកភ្នក    មានមកពីរកលោកស្រដី
កុំស្អកស្រពន់ស្ងួនប្រុសស្រី    ដេកដើរយប់ថ្ងៃរំពៃគិត ។
បើរពិសដៃទើបផ្ទៃផ្អែត    នោះជាបុញ្ញហេតុថ្ងៃប្រឌិត
ត្រូវស្នេហ៍កិច្ចការស្មើជីវិត    នោះទើបវរមិត្តពិតមានបាន ។
ឧស្សាហ៍ព្យាយាមកុំទំនេរ    ប្រឹងប្រែងគ្នាន់គ្នេរគង់ស្រាកស្រាន្ត
របរសុចរិតឥតសាមាន្យ    បង់ចោយមើលប្រាណស្មានកម្លាំង ។
រកស៊ីផ្សែផ្សំសន្សំទ្រព្យ    រិះរឱ្យជាប់កុំធុងធាំង
កុំលោភលាភផលលើសកម្លាំង    ប្រមាណចានឆ្នាំងជាទម្លាប់ ។
កុំដេកផ្សងព្រេងពឹងវាសនា    រង់ចាំទេវតាផ្តល់ភោគភ័ព្វ
សង្ឃឹមរាសីមមៃទ្រព្យ    សំណាងមិនគាប់អភ័ព្វខ្លួន ។
ចង់ធ្វាញ់ខំស្វែងរកអន្ទក់    ស្ទុះស្ទាកុំស្ទក់ទើបមាំមួន
ចង់ស្បើយកុំគិតនឿយហត់ខ្លួន    នោះជាច្បាប់ក្បួនលោកស្រដី ។
ប្រឹងរកនាំមកនូវភោគផល    បើខ្វះខ្វាយខ្វល់នាំក្រក្រី
ទាល់ណាស់គាស់កាយធរណីដី    ម្ល៉េះគង់បានធីខ្លួនរស់បាន ។
មានជើងមានដៃសព្វទាំងទ្វេ    កុំសុំទានគេអាប់ឱនប្រាណ
សឹងស៊ីឈ្នួលគេក៏រស់បាន    កុំត្រាច់សព្វឋានសុំពះគេ ។
ចេះចាយធោមឆាយត្រូវចេះរក    ពុកផ្តាំពន្លកស្ងួនមាសមេ
ក្រខ្សត់អត់ឃ្លានព្រោះទំនេរ    ទ្រព្យធនមានទ្វេព្រោះឧស្សាហ៍ ។
ឃ្លានេះរិះគិតពិនិត្យចុះ    ចូរស្ងួនស្រីប្រុសពិចារណា
ចំណេះចេះបានពីសិក្សា    សម្បត្តិទ្រព្យាបានពីរក ។
ដូច្នេះពាក្យថាចេះពីរៀន    ជាដំបូន្មានត្រូវចាប់យក
ធនធានកើតមានព្រោះប្រឹងរក    ពន្លកគួរយកជាតម្រា ។

**សំណាង**កូនណាស់កើតជាខ្មែរ មិនថាក្រុងស្រែឬចំការ
ឱ្យតែមានចិត្តមានប្រាជ្ញា មិនខ្វះមុខការប្រកបឡើយ ។
ខ្លាចម្យ៉ាងតែខាងខ្ជិលទ្រមក់ ស្ពឹកស្រពន់ស្អក់ធ្វើកន្តើយ
បើនឹងឧស្សាហ៍ព្យាយាមហើយ ជីវិតនឹងស្បើយដល់ត្រើយសុខ ។
ធម្មជាតិស្រុកយើងអំណោយផល ទឹកដីយើងផ្តល់សម្បត្តិស្តុក
កូនអើយខំរកកុំសំកុក ក្តីសុខស្រណុកត្បិតឧស្សាហ៍ ។
**នេះ**បទទំនុកឪពុកផ្តាំ ពន្លកចូរចាំណាកូនណា
ពាក្យពុកផ្ញើទុកនឹងអក្ខរា ផ្តល់ឱ្យធីតាសំណព្វចិត្ត ។
កូនអើយវិជ្ជាជាទ្រព្យធន ប្រាជ្ញាជាទុននៃគំនិត
កេរ្តិ៍ឈ្មោះជាយសនៃជីវិត ន័យនេះគេងគិតកុំកន្តើយ ។
ពាក្យពុកផ្តាំទុកប៉ុណ្ណេះហោង បញ្ចប់ចងក្រងប៉ុណ្ណឹងហើយ
សូមសួនសំរេចត្រាច់ដល់ត្រើយ អនាគតស្បើយឃ្លាតទុក្ខភ័យ ។
សូមជីវិតកូនភ្លឺត្រចះ ដូចដួងច័ន្ទរះពេញបូណ៌មី
ប្រសព្វសុខសាន្តប្រាណប្រិមប្រិយ ប្រកបជោគជ័យតរៀងទៅ ។
**ពេល**អត់ពីពុកកូនកុំភ្លេច ពិនិត្យទឹកប៊ិចក្នុងសៀវភៅ
អក្ខរាចារចូនផ្ញើស្ងួនពៅ ពេលពុកមិននៅត្រូវគេងគិត ។

* * *

# "អវសានកថា"

(បទពាក្យ៧)

នាម៉អ្នកនិពន្ធសុជនខ្ញុំ　　លើកហត្ថប្រណមផ្គុំប្រណិត
បន្ទន់កាយាវាចាចិត្ត　　លាលោកញាតិមិត្តទាំងអាល័យៗ
ខ្ញុំសូមបន់ផ្សងប៉ងសច្ចា　　លោហិតសាច់សាត្អាប់និស្ស័យ
ជាមួយញោមញាតិគ្រប់ជាតិថ្មី　　កើតស្លាប់លើដីបុរីខ្មែរ ៗ
ខ្ញុំអ្នកកវីខ្ចីបញ្ញា　　ម្ដាយអ្នកចំការឪអ្នកស្រែ
ប្រាជ្ញខ្លាបប្រៀបតិចមិនពូកែ　　តែចិត្តស្និទ្ធស្នេហ៍កាព្យអក្សរ ៗ
កំណើតឪពុកស្រុកស៊ុធរ　　តួមិន្ទលពាងពិតពិស្ដារ
នាមលោកសុខឈក្ខណ៍អ្នករាជការ　　ជាសាស្ត្រាចារ្យថ្នាក់បាលី ៗ
ឃុំអរិយក្សត្រកំណើតម្ដាយ　　និងបង្កើតកាយខ្ញុំនេះណី
លោកផ្ដល់ក្ដីសុខផុតទុក្ខភ័យ　　ល្ងាចព្រឹកដឹកដៃឱ្យសិក្សា ៗ
ខ្ញុំស្រឡាញ់ណាស់កាព្យស្មុះសៀង　　ត្បិតជាសំនៀងកេរដូនតា
ម្លោះហើយប្រឹងព្រួយជួយរក្សា　　មរតកថ្លៃថ្លាព្រលឹងជាតិ ៗ
អវសានសុំទោសអស់លោកអ្នក　　បើឆ្គងឃ្លាវគ្គនាំឱ្យឃ្លាត
សូមលោកសន្ដោសកុំចង្អៀត　　និងសូមឆ្លាក់ឆ្លៀតជួយលំអ ៗ
ខ្ញុំសូមទទួលទុកជាមុន　　នូវការរិះគន់ដោយស្មោះសរ
ពិសេសសូមថ្លែងនូវអំណរ　　លោកអ្នកគាំទ្រស្ថាបនា ៗ
សូមលើកគុណរតនត្រ័យ　　ប្រទានពរជ័យប្រាំប្រការ
ជូនដល់លោកអ្នកគ្រប់អាត្មា　　ប្រសព្វសុខានិរន្តរ៍ហោង ៗ។

# ចប់

ពេលពុកមននៅ បានបញ្ចប់ដោយបរិបូណ៌
ថ្ងៃពុធ ទី៩ ខែកក្កដា ឆ្នាំ ១៩៩៥ ត្រូវនឹងថ្ងៃ ១៣ កើត ខែ
អាសាឍ ឆ្នាំកុរ សប្តស័ក ព.ស ២៥៣៩

រក្សាសិទ្ធិ

# * សុខ សុធន *

មន្ត្រីនាយកដ្ឋាន អភិវឌ្ឍន៍ វប្បធម៌
ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ



បោះពុម្ពនៅរោងពុម្ពរណសិរ្ស ២ ធ្នូ